ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨
របស់
# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



ឆ្នាំ២០១៤

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យដោយសម្រេចបានសមិទ្ធផលធំៗជាច្រើន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានដាក់ចេញនូវយុទ្ធសាស្ត្រ៥យ៉ាង និងកម្មវិធីការងារ ៦ចំណុចជំហានទី២ (២០០៨-២០១៣) ដើម្បីរួមចំណែកគាំទ្រ និងជំរុញល្បឿននៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីII។ តាមរយៈយុទ្ធសាស្ត្រ និងកម្មវិធីការងារខាងលើនេះ ក្រសួងសម្រេចបាននូវជោគជ័យធំៗគួរជាទីមោទនៈក្នុងការផ្តល់សេវាសុខុមាលភាពសង្គមដល់ជនរងគ្រោះ និងងាយរងគ្រោះ។ ក្រសួងបានបង្កើតប្រព័ន្ធសន្តិសុខសង្គម និងកម្មវិធីពាក់ព័ន្ធដើម្បីលើកកម្ពស់សុខុមាលភាពរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន រួមទាំងបានបង្កើតមូលនិធិជនពិការ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាននេះ ក៏នៅមានបញ្ហាប្រឈមជាច្រើនដែលក្រសួងត្រូវបន្តដោះស្រាយនៅពេលអនាគត។ សម្រាប់ឆ្នាំ២០១៤-២០១៨ ក្រសួងបានដាក់ចេញយុទ្ធសាស្ត្រចំនួន៣ និងកម្មវិធីអាទិភាពចំនួន៨ ដែលមានសង្គតិភាពជាមួយៈ (១).កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ (២).យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីIII (៣).ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (៤).គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (៥).យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះឆ្នាំ ២០១១-២០១៥ និងឯកសារពាក់ព័ន្ធនានា។

ជាការពិតផែនការយុទ្ធសាស្ត្រនេះគឺជាឯកសាររស់ ជាឯកសារដ៏សំខាន់ ជារបៀបវារៈការងារ និងជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកសកម្មភាពពិតប្រាកដ សមស្រប និងត្រឹមត្រូវ។ ចំពោះមុខនេះ ក្រសួងនឹងបន្តខិតខំប្រឹងប្រែងថែមទៀតក្នុងគោលដៅបង្កើនគុណភាពផ្តល់សេវាឲ្យមានតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងបង្កិតសេវាសុខុមាលភាពសង្គមឲ្យជិតកៀកជនរងគ្រោះ ងាយរងគ្រោះ និងពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និងពង្រឹងកិច្ចគាំពារសង្គម។ ក្នុងន័យនេះខ្ញុំសូមធ្វើការអំពាវនាវដល់ផ្នែកពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ទាំងអស់បន្តរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយស្មារតីទទួលខុសត្រូវ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងអង្គការដៃគូដែលមានការពាក់ព័ន្ធទាំងអស់រួមសហការគ្នាអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

វង សូត

# មាតិកា

**អារម្ភកថា**....................................................................................................... i
**មាតិកា** ........................................................................................................... iii
**អក្សរកាត់** ........................................................................................................ v
**សេចក្តីផ្តើម**....................................................................................................... 1

**ជំពូកទី១**
**ស្ថានភាពវិស័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ....................................... 3
១.១. សេវាសុខុមាលភាពសម្រាប់ជនក្រីក្ររងគ្រោះ និងងាយរងគ្រោះ ..................................... 3
១.២. សេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា.................................................... 4
១.៣. សេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម ......................................... 5
១.៤. របបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ .................. 6
១.៥. របបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន ........................................... 7
១.៦. សមត្ថភាពស្ថាប័ន ភាពជាដៃគូ កៀរគរប្រភពធនធាន បង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច..................... 8

**ជំពូកទី២**
**ក្របខ័ណ្ឌយុទ្ធសាស្ត្រ**............................................................................................ 11
២.១. ចក្ខុវិស័យ ....................................................................................................... 12
២.២. បេសកកម្ម......................................................................................................... 13
២.៣. យុទ្ធសាស្ត្រជាអាទិភាព ........................................................................................ 13
យុទ្ធសាស្ត្រទី១: បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម.............................................13
យុទ្ធសាស្ត្រទី២: ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម...................................................13
យុទ្ធសាស្ត្រទី៣: ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ..13
២.៤. ស្ថាប័ន និងការសម្របសម្រួល.................................................................................. 13
២.៥. កម្មវិធីអាទិភាព និងវិធានការអនុវត្ត ............................................................................ 14
២.៥.១. អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ.......................14
២.៥.២. អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា..........................................................14
២.៥.៣. អភិវឌ្ឍសុខុមាលភាពជនពិការ...................................................................................16
២.៥.៤. អភិវឌ្ឍសុខុមាលភាពមនុស្សចាស់...............................................................................16
២.៥.៥. អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល...................................................17
២.៥.៦. អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន...............................................................................18

២.៥.៧. សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា ........ 18
២.៥.៨. អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ ........ 19
**ជំពូកទី៣**
**គម្រោងការធនធាន** ........ 20
**ជំពូកទី៤**
**ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ........ 21
**សេចក្តីសន្និដ្ឋាន** ........ 22

**ឧបសម្ព័ន្ធ** ........ 22
**ក-តារាងសូចនាករ និងចំណុចដៅ** ........ 22

# អក្សរកាត់

| | |
|---|---|
| ក.ជ.ក. | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ក.ជ.ក.រ. | ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ |
| ក.ស.ជ. | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ប.ជ.ស. | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ប.ជ.អ. | បេឡាជាតិអតីតយុទ្ធជន |
| ប.ម.ស. | បេឡាមរណសង្គ្រោះ |
| ម.ជ.ព. | មូលនិធិជនពិការ |
| វ.ជ.ស. | វិទ្យាស្ថានជាតិសង្គមកិច្ច |
| ស.អ.ក. | សមាគមអតីតយុទ្ធជនកម្ពុជា |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| រ.ស.អ. | រដ្ឋបាលសុំកូនអន្តរប្រទេស |
| គ.ម.ច. | គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ |

# សេចក្តីផ្តើម

១. ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិមានសន្តិភាព និងមានការអភិវឌ្ឍលើគ្រប់វិស័យព្រមទាំងសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ បានរៀបរាប់យ៉ាងលម្អិតពីគោលនយោបាយជាអាទិភាពដើម្បីអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលសំដៅលើកកម្ពស់សមត្ថភាពស្ថាប័នរដ្ឋ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងបង្កើតបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគពីប្រភពខាងក្នុងនិងពីក្រៅប្រទេស ក្នុងទិសដៅបង្កើនកាលានុវត្តភាពការងារសម្រាប់ប្រជាជន កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ។ ដើម្បីជានាសង្គតិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន២០០៩-២០១៣ សម្រាប់ឲ្យក្រសួងស្ថាប័ននានាខិតខំប្រឹងប្រែងរួមគ្នាអនុវត្តក្នុងអាណត្តិរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា។

២. ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ.)បានដាក់ចេញនូវយុទ្ធសាស្ត្រ៥យ៉ាង និងកម្មវិធីការងារអាទិភាព៦ចំណុចជំហានទី២ ដោយមានការប្តេជ្ញាចិត្តខ្ពស់ដើម្បីរួមចំណែកលើកស្ទួយឱ្យកាន់តែល្អប្រសើរលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ យុទ្ធសាស្ត្រ៥ យ៉ាងគឺះ (i).ប្រែក្លាយការផ្តល់សេវាសង្គមកិច្ចជាលក្ខណៈជំនួយមនុស្សធម៌ទៅជារបបធានារ៉ាប់រងសង្គមជាបណ្តើរៗ (ii).រៀបចំប្រព័ន្ធច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រង តម្រង់ទិសសេវាសង្គមកិច្ចឱ្យស្របតាមគោលនយោបាយជាតិ (iii).បញ្ជ្រាបសេវាសង្គមកិច្ចទៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិនៅគ្រប់កម្រិត (iv).បង្កើនភាពជាដៃគូជាមួយកាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល គៀរគរប្រភពធនធានក្នុងការងារមនុស្សធម៌ឱ្យកាន់តែទូលំទូលាយថែមទៀត និង(v).បង្កើនសមត្ថភាពស្ថាប័ន អភិបាលកិច្ចល្អ និងបង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច។ កម្មវិធីការងារអាទិភាព៦ចំណុចជំហានទី២ គឺះ (១).ពង្រឹងពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ជនក្រីក្រងាយរងគ្រោះ (២).ពង្រឹងពង្រីកសេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា (៣).ពង្រឹងពង្រីកសុខុមាលភាពជនពិការ និងសេវាស្តារលទ្ធភាពពលកម្ម (៤).ពង្រឹងពង្រីករបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សុខុមាលភាពមនុស្សចាស់ និងប្រជាជនទូទៅ (៥).ពង្រឹងពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន និង(៦).ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូ គៀរគរប្រភពធនធានបង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច។[1]

៣. ជាលទ្ធផលក្រសួង ស.អ.យ. ចូលរួមលើកកម្ពស់សុខុមាលភាពជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទនៅក្នុងសង្គមទាំងសម្ភារៈស្មារតី ព្រមទាំងបង្កលក្ខណៈផ្តល់សេវាសង្គមកិច្ចទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ដោយបានបង្កើតឲ្យមានគោលនយោបាយ យន្តការ កម្មវិធីនានា ដើម្បីផ្តល់សេវាសង្គមកិច្ចជួយឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះ និងងាយរងគ្រោះរួមមានះ ជនក្រីក្ររងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ ជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ ចាស់ជរាគ្មានទីពឹង ជនអនាថា

[1] យុទ្ធសាស្ត្រ និងកម្មវិធីអាទិភាពមានចែងយ៉ាងលម្អិតនៅក្នុងសៀវភៅកម្មវិធីការងារក្រសួង ស.អ.យ. សម្រាប់ឆ្នាំ២០០៨-២០១៣។

ជនពិការ កុមារនៃគ្រួសារក្រីក្រ កុមារកំព្រា កុមារប្រព្រឹត្តបទល្មើស ជនរងគ្រោះដោយសារធាតុញៀន ជនរងគ្រោះដោយជំងឺកាចសាហាវផ្សេងៗ និងដោយអំពើជួញដូរមនុស្ស។ល។ ខិតខំទប់ស្កាត់ទុរគតភាព និងភាពងាយរងគ្រោះនៅក្នុងសង្គម ការរំលោភបំពាន លើកស្ទួយសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដើម្បីបង្កើតឡើងនូវស្ថានភាពរីកចម្រើនព្រមៗគ្នាក្នុងសហគមន៍។ រៀបចំ និងអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងកម្មវិធីដើម្បីលើកកម្ពស់តួនាទី និងសុខុមាលភាពរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ ទន្ទឹមនឹងការកសាងសមត្ថភាពនាយកដ្ឋាន និងអង្គភាពចំណុះ ក្រសួងបានយកចិត្តទុកដាក់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិទ្វេភាគី ពហុភាគីក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក។ ក្រសួងបានអនុវត្តគោលនយោបាយលើកទឹកចិត្តដោយបង្កលក្ខណៈងាយស្រួលដល់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានាដើម្បីអនុវត្តសកម្មភាពរបស់ខ្លួនពាក់ព័ន្ធនឹងការងារក្រសួង។ គិតពីឆ្នាំ២០១១-២០១៣ នេះក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ១៧៦ ដែលមានថវិកាគម្រោងសរុបចំនួន ១៧២.៣០៨.៨៦៤,២៦ដុល្លារអាមេរិក បើគិតក្នុងមួយឆ្នាំប្រមាណ ៥៧.៤៣៦.២៨៨,០៩ដុល្លារអាមេរិកដែលបានរួមចំណែកសម្រាលបន្ទុកថវិកាជាតិ ព្រមទាំងប្រមូលបាននូវធនធានមនុស្ស បច្ចេកទេស និងបទពិសោធន៍ល្អៗជាច្រើនសម្រាប់វិស័យសង្គមកិច្ច។

៤. ក្នុងការអនុវត្តយុទ្ធសាស្ត្រទាំង៥ និងកម្មវិធីអាទិភាព៦ចំណុច រយៈពេល ៥ឆ្នាំកន្លងមក ក្រសួងទទួលបានសមិទ្ធផលធំៗជាច្រើនទាំងការកសាងលិខិតបទដ្ឋានគតិយុត្ត និងផ្តល់សេវាសុខុមាលភាពសង្គមដល់ជនរងគ្រោះ និងងាយរងគ្រោះទូទាំងប្រទេស ព្រមទាំងទទួលបាននូវបទពិសោធន៍ជាច្រើន ទន្ទឹមនឹងសមិទ្ធផលទាំងនេះ ក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដែលនឹងត្រូវដោះស្រាយបន្តសម្រាប់អាណត្តិថ្មីនេះ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ ក្រសួងបានធ្វើកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថ្មីរបស់ក្រសួង ស.អ.យ. សម្រាប់ឆ្នាំ ២០១៤-២០១៨ ក្នុងគោលបំណងចូលរួមធានារ៉ាប់រងសង្គម និងកិច្ចគាំពារសង្គម ដោយកំណត់នូវយុទ្ធសាស្ត្រចំនួន ៣សំខាន់គឺ៖ (i).បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម (ii).ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម (iii).ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនិងកម្មវិធីជាអាទិភាពចំនួន ៨គឺ៖ (១).អភិវឌ្ឍសុខុមាលភាពជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ (២).អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា (៣).អភិវឌ្ឍសុខុមាលភាពជនពិការ (៤).អភិវឌ្ឍសុខុមាលភាពមនុស្សចាស់ (៥).អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (៦).អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន (៧).សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា (៨).អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ។

# ជំពូកទី១
# ស្ថានភាពវិស័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ១.១. សេវាសុខុមាលភាពសម្រាប់ជនក្រីក្រងាយរងគ្រោះ និងងាយរងគ្រោះ

ក្រសួង ស.អ.យ. បានបង្កើត និងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ដើម្បីជួយដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយជាយថាហេតុផ្សេងៗដោយមិនទុកឲ្យប្រជាជនណាម្នាក់រងគ្រោះដោយមិនបានជួយយកចិត្តទុកដាក់ពីស្ថាប័នមានសមត្ថកិច្ចឡើយ។ តាមរយៈកម្មវិធីនេះបានជួយជនក្រីក្រ ទុរគតជន ជនចំណាកស្រុក ជនអនាថា ជនវិកលចរិក ជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗប្រមាណរាប់ម៉ឺនគ្រួសារក្នុងមួយឆ្នាំៗ។ បានទប់ស្កាត់ និងកាត់បន្ថយការធ្វើចំណាកស្រុក បង្កលក្ខណសម្បត្តិសម្រាប់ការស្តារជីវភាពឡើងវិញ និងការធ្វើសមាហរណកម្មទៅតាមសហគមន៍។ បានរៀបចំគោលនយោបាយ និងយន្តការសម្រាប់ជួយជនអនាថាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជួយដោះស្រាយបញ្ហាជនអនាថាប្រកបដោយមនុស្សធម៌ និងការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ។ ជនអនាថាប្រមាណមួយពាន់គ្រួសារក្នុងមួយឆ្នាំៗត្រូវបានជួយសង្គ្រោះ និងផ្តល់សេវាស្តារនីតិសម្បទា ការថែទាំសុខភាព ការអប់រំផ្លូវចិត្ត ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសមាហរណកម្មទៅតាមសហគមន៍វិញ។ កម្មវិធីជួយជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗតាមរយៈការបណ្តុះបណ្តាល និងផ្តល់សេវាថែទាំ និងសមាហរណកម្មទៅសហគមន៍។ ទន្ទឹមនឹងនេះក្រសួងបានបង្កើតក្រុមការងារយេនឌ័ររបស់ក្រសួង ហើយតាមរយៈក្រុមការងារនេះក្រសួងបានផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ និងបញ្ជ្រាបការងារយេនឌ័រដល់មន្រ្តីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រសួងបានរៀបចំគោលនយោបាយ បទដ្ឋានអប្បបរមា[2] និងកម្មវិធីនានាសម្រាប់ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សសំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។ បានបង្កើតឲ្យមានកិច្ចព្រមព្រៀងទ្វេភាគី ជាមួយប្រទេសជិតខាងនៅក្នុងតំបន់[3] ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះ។ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានសង្គ្រោះ និងផ្តល់សេវាដូចជា៖ ការស្វែងរកគ្រួសារ ប៉ាន់ប្រមាណគ្រួសារ ទទួលស្នាក់នៅរយៈពេលខ្លីវែង បញ្ជូនបន្ត សមាហរណកម្មមាតុភូមិនិវត្តន៍ និងតាមដានជាដើម។ កម្ពុជាបានទទួលការវាយតម្លៃនៅក្នុងកម្រិតទី២ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លើយតបការខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល។ បានបង្កើត និងអនុវត្តកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្ត ការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ រៀបចំទិវាជាតិ និងអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា និងទិវាប្រឆាំងនឹងអំពើជួញដូមនុស្ស ១២ធ្នូ ជារៀងរាល់ឆ្នាំ។ គ្រួសារជាច្រើនបានរក្សាប្រពៃណីទំនៀមទំលាប់ល្អ រស់នៅប្រកបដោយសុភមង្គលក្នុងសង្គមដែលមានសុខសន្តិភាព និងការអភិវឌ្ឍ។

---

[2] បទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូមនុស្ស និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល។

[3] ប្រទេសវៀតណាម និងប្រទេសថៃ

## ១.២. សេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា

ក្រសួង ស.អ.យ. បានធ្វើការផ្សព្វផ្សាយ និងអនុវត្តយ៉ាងទូលំទូលាយនូវសិទ្ធិជាមូលដ្ឋានទាំង៤ របស់កុមារ ដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមាររួមមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួម។ កម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដែលពាក់ព័ន្ធទៅនឹងវិស័យកុមាររួមមានការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ការអប់រំ ការបង្កើនអត្រាចូលរៀនរបស់សិស្ស និងគុណភាពអប់រំ។ល។ ព្រមទាំងបានដាក់ចេញ និងអនុវត្តប្រកបដោយផ្លែផ្កានូវប្រព័ន្ធសុខុមាលភាពកុមារ។ បានបង្កើតគោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមសហគមន៍។ ក្រសួងបានធ្វើប្រតិភូកម្មមុខងារលើវិស័យសុខុមាលភាពកុមារតាមប្រព័ន្ធវិសហមជ្ឈការឲ្យទៅក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ/សង្កាត់។ ពង្រឹងគុណភាពការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការធ្វើអធិការកិច្ច ការកាត់បន្ថយចំនួនមណ្ឌលដែលមិនសមស្រប ការបង្រួបបង្រួមគ្រួសារកុមារ តាមគោលការណ៍ផ្តល់អាទិភាពឲ្យកុមារទទួលបានការអភិវឌ្ឍក្នុងក្របខ័ណ្ឌគ្រួសារ គួបផ្សំនឹងការអនុវត្តកម្មវិធីគ្រួសារធម៌ គ្រួសារចិញ្ចឹមក្នុងស្រុក និងអន្តរប្រទេសសម្រាប់កុមារនៅតាមមណ្ឌលនានា និងសហគមន៍ ដែលត្រួតពិនិត្យដោយក្រសួង ស.អ.យ. ដើម្បីជួយដល់កុមារដែលក្រីក្រ និងងាយរងគ្រោះ។ បានរៀបរៀងច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុម័តនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ និងបានរៀបចំប្រកាសស្តីពីការប្រព្រឹត្តិទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបាលសុំកូនអន្តរប្រទេស។ បានរៀបចំកសាងលិខិតបទដ្ឋាន និងរៀបចំសារាចរដើម្បីជំរុញអនុវត្តច្បាប់ស្តីពីការសុំកូនអន្តរប្រទេសស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ បានពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធតាមរយៈការបើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

ក្រសួងបានជំរុញការងារយុវនីតិសម្បទាដោយបង្កើត និងអនុវត្តនូវកម្មវិធីយុត្តិធម៌អនីតិជនដើម្បីផ្តល់សេវាការពារកុមារតាមផ្លូវច្បាប់ចំពោះអនីតិជនប្រព្រឹត្តល្មើសនៅតាមសហគមន៍ និងក្នុងពន្ធនាគារ។ បានរៀបចំសេចក្តីសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីការពារសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន។ រៀបចំគោលនយោបាយ និងបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាសម្រាប់ជួយដល់ជនរងគ្រោះដែលប្រើប្រាស់បំពានគ្រឿងញៀន ព្រមជាមួយនោះ បានជំរុញគោលនយោបាយលើកទឹកចិត្ត ការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានគ្រឿងញៀននៅតាមសហគមន៍។ បានចុះធ្វើអធិការកិច្ចជនរងគ្រោះដោយសារប្រើប្រាស់សារធាតុញៀនដើម្បីបើកផ្តល់របបឧបត្ថម្ភរបស់រដ្ឋ ជូនដល់ជនរងគ្រោះ ដែលកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា។ រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដែលផ្អែកលើកិច្ចព្រមព្រៀងនៃអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន អេដស៍ និងពេស្យាចារនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

អនុវត្តកាតព្វកិច្ចជាសមាជិកនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំ និងផ្ញើរបាយការណ៍ជាតិលើកទី២ លើកទី៣ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ របាយការណ៍ជាតិលើកទី១ និង

លើកទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសរបស់កុមារ របាយការណ៍ការអនុវត្តសេចក្តីសម្រេចលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិស្តីពីការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធម៌កុមារ របាយការណ៍ស្តីពីអំពើហឹង្សាលើកុមារ របាយការណ៍ស្ថានភាពកុមារ និងរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារពាក់ព័ន្ធផ្សេងៗទៀតជូនអង្គការសហប្រជាជាតិបានទាន់ពេលវេលា។ បានចងក្រងសូចនាករសិទ្ធិកុមារចំនួន ៦២សូចនាករ ចែកជា ៤ផ្នែកៈ (i)-ផ្នែកអប់រំមាន ១០សូចនាករ (ii)-ផ្នែកសុខភាព និងអាហារូបត្ថម្ភមាន ២៤សូចនាករ (iii)-ផ្នែកអភិបាលកិច្ចល្អមាន ១៧សូចនាករ និង (iv)-ផ្នែកសង្គមមាន ១១សូចនាករ។ ពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារតាមរយៈបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័នចំនួន ៩ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅថ្នាក់រាជធានី ខេត្តទាំង២៥។ បានចេញគោលការណ៍ណែនាំ ស្តីពីការអនុវត្តអនុសាសន៍គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបានផ្សព្វផ្សាយដល់ក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធព្រមទាំងបានធ្វើការបណ្តុះបណ្តាលច្បាប់ គោលនយោបាយពាក់ព័ន្ធទៅនឹងការការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរដល់មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ក្រោមជាតិចំនួន ១២ខេត្ត។

រៀបចំគោលការណ៍ស្តីពីការចូលរួមរបស់កុមារ ការសិក្សាស្រាវជ្រាវ ការវិភាគចំណុចខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធការការពារកុមារ ចងក្រងច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា រៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២មិថុនា ដែលមានអ្នកចូលរួម និងកុមារប្រមាណ ៣០០០នាក់ជារៀងរាល់ឆ្នាំ។ រៀបចំព្រឹត្តិប័ត្រស្ថានភាពកុមារ ព្រឹត្តិប័ត្រព័ត៌មានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គេហទំព័រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ផលិតកម្មវិធីពិភាក្សាតុមូល វេទិកាកុមារ កម្មវិធីប្រឡងនិពន្ធ អត្ថបទខ្លីពាក់ព័ន្ធនឹងសិទ្ធិកុមារ វីដេអូអប់រំខ្លី សិល្បៈកុមារតាមទូរទស្សន៍ និងសៀវភៅផ្ទត់ពាក់ព័ន្ធនឹងសិទ្ធិកុមារ។

## ១.៣. សុខុមាលភាពជនពិការ និងសេវាស្តារលទ្ធភាពពលកម្ម

ក្រសួងបានបង្កើតច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការស្របតាមគោលនយោបាយជាតិស្តីពីជនពិការ។ តាមរយៈច្បាប់នេះគោលនយោបាយស្តីពីការពារលើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងប្រកបដោយផ្លែផ្កាព្រមទាំងបង្កឱកាសឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម។ ក្រសួងបានបង្កើតយន្តការមួយចំនួនដូចជាក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីធ្វើការសម្របសម្រួលតាមដានត្រួតពិនិត្យវិស័យពិការភាព និងមូលនិធិជនពិការដែលមានភារកិច្ចរកចំណូល និងផ្តល់សេវាជូនជនពិការស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ក្រសួងបានសហការជាមួយអង្គការដៃគូ[4] បានផលិតឧបករណ៍ទ្រទ្រង់រាងកាយ អវៈយវៈសិប្បនិម្មិត និងរណប និងគ្រឿងជំនួយការដើរវទេះរុញ ផ្តល់សេវាព្យាបាលដោយចលនា និងសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រជូនជនពិការដោយឥតគិតថ្លៃ និងបានបន្តនិរន្តរភាពកម្មវិធីផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាដល់ជនពិការប្រមាណជាង២០.០០០នាក់

[4] មានអង្គការដៃគូមួយចំនួនបានគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ១១ និងរោងជាង៣ ប៉ុន្តែបច្ចុប្បន្នកាត់បន្ថយជាបន្តបន្ទាប់ ដោយបានផ្ទេរការទទួលខុសត្រូវឲ្យក្រសួងបន្តនិរន្តរភាពក្នុងការផ្តល់សេវា ។

ក្នុងមួយឆ្នាំៗដោយឥតគិតថ្លៃរួមទាំងការផ្តល់សោហ៊ុយធ្វើដំណើរ ការស្នាក់នៅ និងការហូបចុក។ បង្កើតរបបគោលនយោបាយស្តីពីការជួយឧបត្ថម្ភជនពិការក្រីក្រនៅតាមសហគមន៍។

ក្រសួងក៏បានរៀបចំ និងអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍សម្រាប់ជនពិការ ការផ្តល់សេវាស្តារលទ្ធភាពពលកម្ម ការបង្កើតក្រុមជួយខ្លួនឯង ការអភិវឌ្ឍមុខរបរខ្នាតតូច។ លើកទឹកចិត្តឲ្យបង្កើតអង្គការរបស់ជនពិការដែលដឹកនាំដោយជនពិការផ្ទាល់ដូចជា៖ សមាគមជនពិការភ្នែកកម្ពុជា អង្គការជនពិការកម្ពុជា មជ្ឈមណ្ឌលជាតិនៃជនពិការ និងក្រុមជួយខ្លួនឯងរបស់ជនពិការនៅតាមសហគមន៍បានចំនួន ១.៩៥០ក្រុម ព្រមទាំងផ្តល់ឱកាសការងារដល់ជនពិការ តាមរយៈការកំណត់អត្រាជ្រើសរើសជនពិការឲ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋចំនួន ២ភាគរយ និងគ្រឹះស្ថានឯកជនចំនួន ១ភាគរយ។

បង្កើតកម្មវិធីផ្តល់សេវាឲ្យកុមារពិការភ្នែក កុមារគថ្លង់ និងកុមារពិការខ្សោយសតិបញ្ញា តាមរយៈការបង្កើតឲ្យមានមណ្ឌលផ្តល់នូវសេវាពិសេសជូនដល់ប្រភេទកុមារពិការនិមួយៗ និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍ដោយមិនមានការរើសអើង។ លើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការបន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់។ ចូលរួមកសាងនិងអនុម័តទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក២០១៣-២០២២ និងផែនការយុទ្ធសាស្ត្រអ៊ីនឈាន់ “ធ្វើឱ្យសិទ្ធិក្លាយជាការពិត” ។

## ១.៤. របបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ

ក្រសួងបានបង្កើត និងអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់។ អត្រាមនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅមាន៦ភាគរយនៃប្រជាពលរដ្ឋទាំងអស់។ អត្រានេះអាចមាននិន្នាការកើនឡើងជាបន្តបន្ទាប់ស្របតាមលក្ខណៈប្រជាសាស្ត្រ ការរីកចម្រើននៃវិស័យសុខុមាលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ បានបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងយន្តការថ្នាក់ក្រោមជាតិដើម្បីអនុវត្តគោលនយោបាយចំពោះមនុស្សចាស់ និងបានរៀបចំទិវាមនុស្សចាស់ ១តុលា ជារៀងរាល់ឆ្នាំ។ បាននឹងកំពុងអនុវត្តនូវកម្មវិធីពីរសំខាន់គឺ៖ ទី១-កម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងទី២-កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ។ បានបង្កើតសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់ប្រមាណ ៥៦៩សមាគម ដែលតាមរយៈសកម្មភាពនៃសមាគមទាំងនេះបានបង្កើតឲ្យមានកម្មវិធីថែទាំសុខភាព ធនាគារស្រូវ ធនាគារគោ ឥណទានខ្នាតតូច បេឡាមរណសង្គ្រោះ និងការសាមគ្គីជួយគ្នាទៅវិញទៅមករវាងមនុស្សចាស់ដូចគ្នានៅក្នុងសហគមន៍។ កម្មវិធីទាំងនេះបានជួយមនុស្សចាស់ថែទាំសុខភាព និងមានអាយុវែងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។ ទន្ទឹមនឹងនេះក្រសួងបានជំរុញកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារតាមរយៈការផ្សព្វផ្សាយលើកកម្ពស់ប្រពៃណីទំនៀមទម្លាប់ល្អរបស់គ្រួសារខ្មែរក្នុងការគោរពដឹងគុណចំពោះមនុស្សចាស់រួមមានឪពុកម្តាយ ជីដូនជីតា។ ជំរុញកម្មវិធីលើកទឹកចិត្តដល់សហគមន៍ វត្តអារាមសាសនា ជាពិសេសព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ដើម្បីជួយដល់សាសនិកដែលជាជនចាស់ជរាបានជ្រកកោននៅតាមទីអារាម។ សប្បុរជនមួយចំនួនបានបង្កើតនូវកម្មវិធីមនុស្សធម៌ដើម្បីជួយដល់ចាស់ជរា ដូចជាកម្មវិធីផ្ទះទេវតារបស់ស្ថានីយ៍ទូរទស្សន៍បាយ័នបានជួយសាងសង់ផ្ទះទេវតារាប់រយខ្នងជូនជនចាស់ជរាក្រីក្រនៅតាមសហគមន៍។ បានសិក្សាស្រាវជ្រាវដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបប

សន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជាទូទៅ និងពិនិត្យឡើងវិញដើម្បីសុំគោលការណ៍អនុវត្តចាប់ពីឆ្នាំ២០១៤-២០១៨។

ក្រសួង ស.អ.យ. បានអនុវត្តគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិល ដោយដឹងគុណចំពោះគុណបំណាច់របស់អតីតមន្ត្រីរាជការស៊ីវិលដែលបានរួមចំណែកក្នុងបុព្វហេតុនៃការអភិវឌ្ឍប្រទេសជាតិ ហើយបានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗសម្រាប់ជំនាន់ក្រោយៗទៀត។ បានផ្តល់នូវការលើកទឹកចិត្តតាមរយៈការផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូរ និងការផ្តល់នូវរបបសន្តិសុខសង្គមដោយមានការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។ រៀបចំ និងដាក់ឲ្យដំណើរការនូវរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលមានតារកាលិក ៦មុខរួមមានៈ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវបានដំឡើងជារៀងរាល់ឆ្នាំស្របតាមការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល។ បានបង្កើត និងដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដើម្បីអនុវត្តការបើកផ្តល់របបសន្តិសុខសង្គមឲ្យទាន់ពេលវេលាស្របតាមគោលនយោបាយនៃការផ្តល់សេវាសាធារណៈ និងយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ រហូតមកដល់បច្ចុប្បន្នបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលបានអនុវត្តការបើកផ្តល់ប្រាក់សោធនតាមប្រព័ន្ធធនាគារ នៅរាជធានីភ្នំពេញ និងខេត្តចំនួន ១៤ និងបន្តអនុវត្តនៅទូទាំងប្រទេសនៅដើមឆ្នាំ២០១៤ ខាងមុខដែលមានសិទ្ធិវន្តជានិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបប្រហែល ៤៥,០០០នាក់។

## ១.៨. របបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការងារអតីតយុទ្ធជន និងបានអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន ដោយការគោរពនូវគុណូបការៈដ៏ថ្លៃថ្លារបស់បងប្អូនអតីតយុទ្ធជនចំពោះជាតិមាតុភូមិ និងប្រជាជនជាមួយនឹងការយកចិត្តទុកដាក់ដោះស្រាយជីវភាពទាំងសម្ភារៈ និងថវិកាជាបន្តបន្ទាប់ព្រមទាំងផ្តល់កិត្តិយស ការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរជូនអតីតយុទ្ធជន។ បានយកចិត្តទុកដាក់កែសម្រួលបន្ថែមរបបឧបត្ថម្ភជូនអតីតយុទ្ធជនជាបន្តបន្ទាប់ស្របតាមសភាពការណ៍ជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចជាតិ (គិតមកដល់ឆ្នាំ២០១៣ ប្រាក់បង្កើនភាគរយបានកើនឡើងដល់ ២៣៥ ភាគរយនៃបៀវត្សឋានន្តរស័ក្តិ)។[5] បាននឹងកំពុងជំរុញដំណើរការធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជនដើម្បីគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា និងបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនតាមប្រព័ន្ធធនាគារសំដៅបង្កើនប្រសិទ្ធភាពការបើកផ្តល់ប្រាក់របបគោលនយោបាយជូនអតីតយុទ្ធជន និងគ្រួសារ។ រហូតមកដល់ដំណាច់ឆ្នាំ២០១៣នេះ អតីត

[5] របបឧបត្ថម្ភកូនជនពលី និងមរណៈបានតម្លើងពី ៤.០០០៛ ទៅ ៨.០០០៛ និងប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារជនមរណៈដែលមានឪពុកម្តាយ ឬអាណាព្យាបាល ប្រពន្ធឬប្តី ៣.២០០៛ ម្នាក់/ខែ។ កែសម្រួលបន្ថែមប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ឬប្តីជនពលី និងមរណៈពី ៣.២០០៛ ទៅ ៦.០០០៛ និងប្រពន្ធឬប្តីរបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការពី ៣០០០៛ ទៅ ៦០០០៛ ព្រមទាំងកូន ២.៥០០៛ ដល់៥.០០០៛។ គិតមកដល់ចុងឆ្នាំ២០១៣ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារដែលទទួលរបបសន្តិសុខសង្គមពីរដ្ឋមាន ៩១.៨១៣គ្រួសារ។ រាជរដ្ឋាភិបាលបានចំណាយថវិកាមានចំនួន ១៤.៥៨៣.៧៥១.៦៤០៛/ខែ សម្រាប់អនុវត្តរបបនេះ ។

យុទ្ធជន និងគ្រួសារអតីតយុទ្ធជនចំនួន ២០[6] រាជធានីខេត្ត បានបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែតាមប្រព័ន្ធធនាគារ និងអនុវត្តទាំងស្រុងនៅឆមាសទី១ ឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ ក្រសួងបានអនុវត្តនូវគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ព្រមទាំងបានបង្កើតគម្រោងជាច្រើនដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។[7]

បានបង្កើតសមាគមអតីតយុទ្ធជនកម្ពុជាកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧ នៅពេលធ្វើមហាសន្និបាតសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស និងចូលជាសមាជិកនៃសម្ព័ន្ធអតីតយុទ្ធជនអាស៊ាននៅក្នុងមហាសន្និបាតសម្ព័ន្ធអតីតយុទ្ធជនអាស៊ានលើកទី១៣ ដែលប្រព្រឹត្តទៅពីថ្ងៃទី២៥-២៨ ខែមេសា ឆ្នាំ២០១០ នៅហ្សាកាតានៃប្រទេសឥណ្ឌូនេស៊ី។ កន្លងមកនេះ សមាគមអតីតយុទ្ធជនកម្ពុជាសម្រេចបាននូវជោគជ័យជាច្រើនគួរឲ្យកត់សម្គាល់ក្នុងការកសាងជីវភាពគ្រួសារ ចូលរួមអភិវឌ្ឍនៅមូលដ្ឋាន ការបង្កើតបេឡាគណទាន បេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានកសាងភូមិអភិវឌ្ឍន៍យោធិនពិការនៅតាកែនកោះស្លាស្រុកឈូក ខេត្តកំពតមណ្ឌលអភិវឌ្ឍយោធិនពិការ ៣១៧ គូលែន ខេត្តសៀមរាប និងមណ្ឌលអភិវឌ្ឍន៍យោធិនពិការភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ និងតំបន់មួយចំនួនទៀត។ ទន្ទឹមនឹងនេះសម្តេចតេជោ **ហ៊ុន សែន** សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងសប្បុរសជនបានសាងសង់ផ្ទះជូនអតីតយុទ្ធជន និងគ្រួសារនៅតាមសហគមន៍នានា តាមរយៈសមាគមអតីតយុទ្ធជនកម្ពុជាបានចំនួន ១៨៤ខ្នង និងកំពុងបន្តសាងសង់ជាបន្តបន្ទាប់ទៀត។

### ១.៦. សមត្ថភាពស្ថាប័ន ភាពជាដៃគូ កៀរគរប្រភពធនធាន បង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច

កញ្ចប់ថវិកាជាតិសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានបង្កើនជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ជាអាទិ៍នៅឆ្នាំ២០១១ មានថវិកាសរុបចំនួន ២៥៨.២៤៩.៣៤០.០០០រៀល ឆ្នាំ២០១២ មានថវិកាសរុបចំនួន ៣៥៣.១៨៧.៨០០.០០០រៀល និងនៅឆ្នាំ២០១៣ មានថវិកាសរុបចំនួន ៧៧២.៨១០.១៧៦.០០០រៀល។ ការកើនឡើងនេះបានបង្ហាញឱ្យឃើញថាក្រសួងបានអនុវត្តត្រឹមត្រូវ និងបើកផ្តល់ទាន់ពេលវេលាដល់គ្រប់មុខសញ្ញាក្នុងស្មារតីទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានផែនការច្បាស់លាស់។

ធ្វើសវនកម្មផ្ទៃក្នុងមន្ទីរ ស.អ.យ. រាជធានីខេត្ត លើចំណូល ចំណាយថវិការដ្ឋ និងការងារសមាគមអតីតយុទ្ធជនកម្ពុជា។ សហការជាមួយក្រុមការងារត្រួតពិនិត្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះត្រួតពិនិត្យការផ្គត់ផ្គង់របបឧបត្ថម្ភជនរងគ្រោះដោយសារគ្រឿងញៀនស្នាក់នៅក្នុងមណ្ឌលអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទានៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។

[6]រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហនុ កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កោះកុង កែប ព្រះវិហារ កំពង់ធំ និងស្វាយរៀង។

[7]គណៈកម្មាធិការអន្តរក្រសួងបានទទួលពាក្យស្នើសុំសម្បទានដីសង្គមកិច្ចសរុបចំនួន ១៣.២៦៥គ្រួសារ និងបញ្ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីពិនិត្យសម្រេចតាមនីតិវិធី។ អតីតយុទ្ធជនដែលទទួលបានដី និងផ្ទះពីគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិសរុប ២.៩៧១គ្រួសារក្នុងនោះទទួលបានទាំងដី និងផ្ទះចំនួន ៨៥០គ្រួសារ និងទទួលបានតែដីចំនួន ២.១២១គ្រួសារ។

ការកសាងសមត្ថភាពស្ថាប័ន ការបណ្តុះបណ្តាលមន្ត្រីដែលធ្វើការលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានអនុវត្តជាបន្តបន្ទាប់ និងបង្កើតឡើងនូវប្រភពធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បន្តអនុវត្តភារកិច្ច ដែលបានកំណត់ក្នុងរយៈពេលខាងមុខនេះ។ ក្រសួងបើកវគ្គបណ្តុះបណ្តាលបានចំនួន ៣២វគ្គ រួមមាន៖ សេវាសង្គមកិច្ចមូលដ្ឋានចំនួន ៤វគ្គ សេវាសង្គមកិច្ចជំនាញចំនួន ៤វគ្គ ជំនាញគាំទ្រចិត្តសង្គមចំនួន ១៥វគ្គ ជំនាញធ្វើការជាមួយជនរងគ្រោះដោយការជួញដូរចំនួន ៤វគ្គ និងជំនាញថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះចំនួន ៥វគ្គដែលមានសិក្ខាកាមសរុបចំនួន ៧២៤នាក់។ ទន្ទឹមនឹងនេះមន្ត្រីមួយចំនួនត្រូវបានទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេសតាមរយៈសិក្ខាសាលា និងទស្សនកិច្ចសិក្សានានា។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច។ រហូតមកដល់ចុងឆ្នាំ២០១៣នេះ វិទ្យាស្ថានជាតិសង្គមកិច្ចមាននិស្សិតចំនួន ១៧៩នាក់ ក្នុងនោះ ថ្នាក់បរិញ្ញាបត្រសង្គមកិច្ចចំនួន ៧៦នាក់ (ឆ្នាំទី១ មាន ៥៣នាក់ និងឆ្នាំទី២ មាន ២៣នាក់) ថ្នាក់បរិញ្ញាបត្រសង្គមវិទ្យាឆ្នាំទី១ មាន១៩នាក់ ថ្នាក់បរិញ្ញាបត្រគាំពារសង្គមមាន ៤៥នាក់ និងថ្នាក់បរិញ្ញាបត្របច្ចេកទេសអវៈយវៈសិប្បនិម្មិត និងរណបចំនួន ៣៩នាក់ (ឆ្នាំទី១ មាន ១៩នាក់ ឆ្នាំទី២ មាន ០៧នាក់ និងឆ្នាំទី៣ មាន ១៣នាក់)។ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ និងបន្ទាយព្រាបបានទទួលសិស្ស ១៦៣នាក់ (ស្រី៦៩នាក់)សិក្សាលើជំនាញជួសជុលម៉ូតូ ម៉ាញ៉េ ចម្លាក់ ទូរទស្សន៍ កាត់ដេរ និងកុំព្យូទ័រ។ ការងារព័ត៌មានវិទ្យាបានសម្រេចបង្កើតគេហទំព័ររបស់ក្រសួង[8] ហើយបានបញ្ចូលទិន្នន័យរួមមាន៖ រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួង ស.អ.យ. របៀបរបបធ្វើការងារ កម្មវិធីការងារ៥ឆ្នាំ របាយការណ៍លទ្ធផលការងារប្រចាំត្រីមាស ឆមាស ៩ខែ ឆ្នាំ និង៥ឆ្នាំ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ទិន្នន័យរបស់អង្គការដៃគូដែលសហការជាមួយក្រសួង។

ដោយមានការគាំទ្រពី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ "គ.ជ.អ.ប." និងអង្គការយូនីសេហ្វ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងត្រូវបានបង្កើតឡើង ហើយបានសម្រេចការងារដូចជា៖ សិក្សាស្វែងយល់ពីនីតិវិធី និងសម្របសម្រួលអំពីការផ្ទេរមុខងារមួយចំនួនជាជំហានៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមបណ្តារខេត្ត[9] និងចុះធ្វើសម្ភាសន៍ស្រង់ព័ត៌មានសម្រាប់រៀបចំបញ្ជីវិភាគមុខងារនៅទីស្តីការក្រសួង និងរាជធានីខេត្ត។[10] បានរៀបចំរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងាររបស់ក្រសួងដាក់ជូន គ.ជ.អ.ប. ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ ហើយរបាយការណ៍នេះត្រូវបាន គ.ជ.អ.ប. ឯកភាពជាផ្លូវការនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។ ក្រុមការងារក៏បានរៀបចំរបាយការណ៍ស្តីពីការពិនិត្យមុខងារឡើងវិញផងដែរ។

ក្រសួងបានយកចិត្តទុកដាក់លើភាពជាដៃគូលើកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ពហុភាគីក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក។ ក្រសួងបានអនុវត្តគោលនយោបាយលើកទឹកចិត្តដោយបង្កលក្ខណៈងាយស្រួលដល់អង្គការពាក់ព័ន្ធនានាក្នុងការអនុវត្តសកម្មភាពលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានជាអាទិ៍៖ ផ្តល់ទីតាំងដី អគារ ចំណាយចូលរួមជាបដិភាគក្នុងចំណាយប្រតិបត្តិការ សម្របសម្រួលការនាំចូលសម្ភារៈ បរិក្ខារដោយមិនបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ និងកិច្ចការសហប្រតិបត្តិការផ្សេងៗទៀត។ គិតពីឆ្នាំ

[8] www.mosvy.gov.kh

[9] ខេត្តតាកែវ កំពត កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង ក្រចេះ កែប ព្រះសីហនុ កោះកុង បន្ទាយមានជ័យ ប៉ៃលិន មណ្ឌលគិរី រតនគិរី ព្រៃវែង និងកំពង់ចាម។

[10] ភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប កំពង់ធំ ប៉ៃលិន ព្រះវិហារ កំពង់ស្ពឺ ព្រះសីហនុ តាកែវ កែប ស្វាយរៀង ក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ចាម ព្រៃវែង បាត់ដំបង កំពត។

២០១១-២០១៣ នេះក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ១៧៦អង្គការដែលធ្វើការលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលមានថវិកាគម្រោងសរុប ១៧២.៣០៨.៨៦៤,២៦ដុល្លារអាមេរិក បើគិតក្នុងមួយឆ្នាំៗប្រមាណ ៥៧.៤៣៦.២៨៨,០៩ដុល្លារ ដែលបានរួមចំណែកសម្រាលបន្ទុកថវិកាជាតិ និងប្រមូលបាននូវធនធានមនុស្ស បច្ចេកទេស និងបទពិសោធន៍ល្អៗជាច្រើនសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីទទួលបន្ទុកសុខុមាលភាពសង្គម និងអភិវឌ្ឍន៍អាស៊ានលើកទី៨ និងកិច្ចប្រជុំរដ្ឋមន្ត្រីទទួលបន្ទុកសុខុមាលភាពសង្គម និងអភិវឌ្ឍន៍អាស៊ានបូកបីលើកទី៤ និងកិច្ចប្រជុំពាក់ព័ន្ធនៅខេត្តសៀមរាបកាលពីថ្ងៃទី៣-៧ ខែកញ្ញា ឆ្នាំ២០១៣ សម្រេចបាននូវឯកសារគោលសំខាន់ៗជាច្រើន ជាពិសេសបានអនុម័តនូវសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម និងសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហឹង្សាប្រឆាំងស្ត្រី និងការលុបបំបាត់អំពើហឹង្សាប្រឆាំងកុមារនៅក្នុងអាស៊ានដែលជាឯកសារពាក់ព័ន្ធវិស័យសុខុមាលភាពសង្គម និងអភិវឌ្ឍន៍ត្រូវដាក់ជូនកិច្ចប្រជុំកំពូលអាស៊ានលើកទី២៣ នៅប្រទេសប្រ៊ុយណេដារ៉ូសាឡឹមដើម្បីអនុម័ត។

## បញ្ហាប្រឈមដែលត្រូវដោះស្រាយបន្តក្នុងអាណត្តិថ្មី

១. ទន្ទឹមនឹងសមិទ្ធផលសំខាន់ៗដែលបានលើកឡើងខាងលើ កម្ពុជាក៏នៅមានបញ្ហាប្រឈមជាច្រើនទៀត រួមមានភាពក្រីក្រ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល ការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយសង្គមផ្សេងៗបានបង្កើតឲ្យមានភាពងាយរងគ្រោះ ដូចជាការចំណាកស្រុក ជនអនាថា ការជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀន ជនចាស់ជរាក្រីក្រគ្មានទីពឹង ជនពិការក្រីក្រ កុមារកំព្រា និងកុមារងាយរងគ្រោះ។

២. យោងទៅតាមជំរឿនឆ្នាំ២០០៨ មានកុមារក្រោមអាយុ១៨ឆ្នាំ មាន ៤១ភាគរយ(៥.៤៨៧.៧០៨)នៃប្រជាជនសរុប។ នៅក្នុងចំណោមអនីតិជនទាំងអស់មានកុមារកំព្រា និងកុមារងាយរងគ្រោះប្រហែលជា ១៤ភាគរយ (៧៥០.០០០នាក់)កំពុងរស់នៅក្នុងមជ្ឈមណ្ឌលថែទាំ រស់នៅជាមួយគ្រួសារដែលក្រីក្របំផុតឬរស់នៅដោយខ្លួនឯងក្នុងភាពជាអ្នកចិញ្ចឹមគ្រួសារ។ កុមារកំព្រា និងកុមារងាយរងគ្រោះជាច្រើនកំពុងតែប្រឈមមុខយ៉ាងខ្លាំងទៅនឹងភាពងាយរងគ្រោះដូចជា៖ កង្វះស្បៀង អាហារូបត្ថម្ភ សុខភាព វិបត្តិផ្លូវចិត្ត មិនបានចូលរៀន ឬចូលរៀនយឺត ឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ និងពលកម្មជាដើម ។

៣. ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានានៅក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅមានកម្រិត ទន្ទឹមនឹងនេះក្រសួងមានការខ្វះខាតមន្ត្រី និងអ្នកជំនាញសង្គមកិច្ចសម្រាប់បម្រើឲ្យការផ្តល់សេវាសុខុមាលភាពសង្គម។

# ជំពូកទី២
# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយក្រសួង ស.អ.យ. និងសហការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការកសាងផែនការយុទ្ធសាស្ត្រនេះគឺផ្អែកលើកម្មវិធីការងារ បទពិសោធន៍ និងលទ្ធផលដែលមានពីមុនមក ដោយព្យាយាមបំពេញចំណុចខ្វះខាត និងកែលម្អលើផ្នែកមួយចំនួននៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ផែនការយុទ្ធសាស្ត្រនេះបានឆ្លុះបញ្ចាំងពីចក្ខុវិស័យរបស់ក្រសួង ស.អ.យ. លើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់រយៈពេល៥ឆ្នាំខាងមុខឆ្នាំ២០១៤-២០១៨ ។

ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងធ្វើឲ្យសម្រេចគោលដៅ ដែលបានកំណត់នៅក្នុងឯកសារគោលនយោបាយនានាដូចជា៖ (១).កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥[11](២).យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីIII[12] (៣).ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (៤).យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥ (៥).គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (៦).ផែនការយុទ្ធសាស្ត្រតាមពហុវិស័យមួយចំនួនទៀតរបស់ក្រសួង[13] និងច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលគាំទ្រដល់កិច្ចដំណើរការនៃមុខងារ។ ផែនការយុទ្ធសាស្ត្រនេះក៏ឆ្លើយតបទៅនឹង៖ (១).ផែនការយុទ្ធសាស្ត្រស្របតាមក្របខ័ណ្ឌអាស៊ាន និងអាស៊ានបូកបី (២).ផែនការសកម្មភាពម៉ាឌ្រីដស្តីពីមនុស្សចាស់ (៣).ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០១៣-២០២២ និងផែនការយុទ្ធសាស្ត្រអ៊ីនឈាន់"ធ្វើឱ្យសិទ្ធិក្លាយជាការពិត" (៤).អនុសញ្ញាស្តីពីសិទ្ធិកុមារ (៥).អនុសញ្ញា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ផែនការយុទ្ធសាស្ត្រនេះ ក៏មានទិសដៅចូលរួមចំណែកដល់របៀបវារៈគោលនយោបាយរបស់កម្ពុជាស្តីពីការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្តល់ជាក្របខ័ណ្ឌដែលធានានូវភាពជាម្ចាស់ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល និងអាចឲ្យដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិតម្រង់ទិសហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួនទៅនឹងយុទ្ធសាស្ត្រ កម្មវិធី សូចនាករ និងសកម្មភាពរបស់ក្រសួង និងចាត់ចែងធនធានសម្រាប់ផ្តល់សេវាសុខុមាលភាពសង្គមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ យន្តការនេះអាចធ្វើឲ្យវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអាចឈានទៅអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីប្រកបដោយសង្គតិភាពក្នុងការគ្រប់គ្រងចាត់ចែងធនធានផ្តល់សេវាសុខុមាលភាពសង្គម។

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងត្រូវបានរៀបចំឡើងសម្រាប់រយៈពេល៥ឆ្នាំ (២០១៤-២០១៨) គឺត្រូវគ្នានឹងអាណត្តិរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ផងដែរ។

---

[11] ចំណុចទី៤.៥. សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥

[12] មុំទី៣ និងមុំទី៤ "ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម" ស្ថិតនៅក្នុងចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

[13] (១).ផែនការយុទ្ធសាស្ត្រជាតិស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ២០១៣-២០១៨ (២).ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨ និង(៣).ផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០១៤-២០១៨។

# រូបទាពបំព្រួញក្របខ័ណ្ឌយុទ្ធសាស្ត្រ




## ២.១. ចក្ខុវិស័យ

| |
|---|
| "បង្កិតសេវាសុខុមាលភាពសង្គមឲ្យជិតកៀកជនរងគ្រោះ និងងាយរងគ្រោះ និងពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម" |

## ២.២. បេសកកម្ម

ក្រសួង ស.អ.យ. មានបេសកកម្មផ្ដល់សេវាសុខុមាលភាពសង្គមដល់ជនរងគ្រោះ និងងាយរងគ្រោះ និងក្រីក្រជាអាទិ៍៖ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា និងកុមារងាយរងគ្រោះ ស្រ្តីបម្រើសេវាកំសាន្ត ជនដែលផ្ទុកមេរោគអេដស៍ជំងឺអេដស៍ និងមេរោគកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម និងបើកផ្ដល់របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនប្រកបដោយសមធម៌ និងមានតម្លាភាព ។

## ២.៣. យុទ្ធសាស្រ្តជាអាទិភាព

<u>យុទ្ធសាស្រ្តទី១</u>: បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

- អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ
- អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា
- អភិវឌ្ឍសុខុមាលភាពជនពិការ
- អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

<u>យុទ្ធសាស្រ្តទី២</u>: ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម

- អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន
- សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា

<u>យុទ្ធសាស្រ្តទី៣</u>: ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ

- អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

## ២.៤. ស្ថាប័ន និងការសម្របសម្រួល

២.៤.១. ក្រសួង ស.អ.យ. បានបង្កើតឡើងដោយច្បាប់ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស.អ.យ. បានកំណត់មុខងារ និងការទទួលខុសត្រូវយ៉ាងច្បាស់របស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋានជំនាញ និងអង្គភាពចំណុះទាំងអស់ក្រោមឱវាទក្រសួង។ ទន្ទឹមនឹងនេះ ក្រសួង ស.អ.យ. មានភារកិច្ចទទួលខុសត្រូវចំពោះប្រមុខរាជរដ្ឋាភិបាល។ ក្នុងន័យនេះក្រសួងគឺជាស្ថាប័នដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតាមដានត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្រ្ត៥ឆ្នាំ(២០១៤-២០១៨)។[14]

[14] នាយកដ្ឋានជំនាញ និងអង្គភាពចំណុះត្រូវសហការគ្នាចំពោះការអនុវត្តសូចនាកររួម និងទទួលខុសត្រូវលើការអនុវត្តសូចនាករស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយរួមទាំងការសម្របសម្រួលជាមួយអង្គការដៃគូក្នុងការអនុវត្តនូវសូចនាករទាំងនោះ ។

២.៤.២. មន្ទីរ ស.អ.យ. រាជធានីខេត្តត្រូវបានបង្កើតឡើងដោយប្រកាសលេខ ៣៥៩ ស.អ.យ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥ ដែលជាខ្សែបណ្តោយរបស់ក្រសួងមានភារកិច្ចសម្របសម្រួល និងទទួលអនុវត្តវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ក្រោមជាតិដែលមានការិយាល័យ ស.អ.យ. ក្រុង ស្រុក ខណ្ឌធ្វើជាសេនាការដោយធ្វើការជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិ។ បច្ចុប្បន្នក្រសួងបានធ្វើប្រតិភូកម្មមុខងារមួយចំនួនឲ្យទៅមន្ទីរអនុវត្តក្នុងនាមក្រសួង និងនៅពេលខាងមុខក្រសួងនឹងផ្ទេរមុខងារមួយចំនួនទៀតដែលទាក់ទងដោយផ្ទាល់ក្នុងការផ្តល់សេវាឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗ[15] ដូច្នេះមន្ត្រីជំនាញរបស់មន្ទីរ ស.អ.យ. រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌជាអ្នកអនុវត្តដោយផ្ទាល់ក្រោមការសម្របសម្រួលពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

២.៤.៣. ភាគីពាក់ព័ន្ធដទៃទៀតដែលរួមចំណែកក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមានក្រសួង ស្ថាប័ន កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន អាជ្ញាធរថ្នាក់ក្រោមជាតិ[16] និងអ្នកដែលទទួលបានសេវាសុខុមាលភាពសង្គមទាំងអស់នឹងផ្តល់ការគាំទ្រ និងសហការជាមួយក្រសួង ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឲ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

## ២.៥. កម្មវិធីអាទិភាព និងវិធានការអនុវត្ត

### ២.៥.១. អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ

ក្រសួង ស.អ.យ.នឹងបង្កើនអន្តរាគមន៍ផ្នែកសង្គមកិច្ចដើម្បីជួយដល់ជនក្រីក្រងាយរងគ្រោះ ជនចំណាកស្រុក ជនអនាថា ជនវិកលចរិត និងជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ ហើយមិនទុកឲ្យប្រជាជនណាម្នាក់ស្លាប់ដោយអត់បាយដែលយើងមិនបានដឹង និងមិនបានដោះស្រាយឡើយ។ បន្តពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅតាមសហគមន៍ ទប់ស្កាត់ទុរគតភាព ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ បន្តពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថាចាត់ទុកជនអនាថាជាជនរងគ្រោះដែលត្រូវទទួលបាននូវការគាំពារផ្នែកសង្គមកិច្ច ការផ្តល់សេវាជូនជនអនាថាដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស និងការបង្កឱកាសឲ្យស្តារជីវភាពឡើងវិញ និងសមាហរណកម្មទៅក្នុងសង្គម។ បង្កើនការផ្តល់សេវាថែទាំគាំទ្រដល់ជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ។ ជំរុញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយដល់ជនរងគ្រោះតាមរយៈការផ្តល់សេវាផ្សេងៗដូចជាស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្ម ការធ្វើមាតុភូមិនិវត្តជនរងគ្រោះទៅសហគមន៍វិញដោយគ្មានការរើសអើង និងសេវាផ្សេងៗដើម្បីឆ្លើយតបតម្រូវការជនរងគ្រោះជាអាទិភាព។ បន្តអនុវត្តគោលនយោបាយ បទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបន្តរៀបចំទិវាប្រឆាំងនឹងអំពើជួញដូមនុស្ស១២ធ្នូ។ បន្តអភិវឌ្ឍចលនាគ្រួសារល្អ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ លើកកម្ពស់តួនាទីរបស់គ្រួសារដែលជាកោសិកាសង្គម ជាកន្លែងផ្តល់ភាពកក់ក្តៅ និងសុភមង្គលសម្រាប់ប្រជាជនគ្រប់រូប ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គម។ ក្រសួងនឹងបន្តរៀបចំទិវាអន្តរជាតិស្តីពីគ្រួសារ

[15] ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

[16] ក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ/សង្កាត់

១៥ឧសភា ជារៀងរាល់ឆ្នាំដើម្បីសម្តែងនូវការគោរពកោតសរសើរចំពោះគ្រួសារទាំងឡាយដែលបានខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនចៅឲ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។ បន្តផ្សព្វផ្សាយអនុសញ្ញា ស៊ី.ដ និងបញ្ញាបការងារយេនឌ័រដល់មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រៀបចំ និងអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសហគមន៍ប្រជាជនក្រីក្រនៅតាមសហគមន៍ដើម្បីទទួលបាននូវកាលានុវត្តភាពសម្រាប់ការកែប្រែជីវភាពរស់នៅ។

## ២.៩.២. អនិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

ក្រសួងនឹងបន្តជំរុញការផ្សព្វផ្សាយ និងអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ ជាពិសេសសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារគឺ “សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការអភិវឌ្ឍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួមរបស់កុមារ”។ បន្តអនុវត្តប្រកបដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដែលពាក់ព័ន្ធនឹង វិស័យសុខុមាលភាពកុមារ បន្តអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍។ បន្តពង្រឹងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌលទាំងមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលតាមរយៈការធ្វើអធិការកិច្ច កាត់បន្ថយចំនួនមណ្ឌលដែលមិនសមស្រប បង្រួបបង្រួមគ្រួសារកុមារតាមគោលការណ៍ផ្តល់អាទិភាពឲ្យកុមារទទួលបានការអភិវឌ្ឍក្នុងក្របខ័ណ្ឌគ្រួសារតាមគោលការណ៍ពង្រឹងគុណភាព កាត់បន្ថយបរិមាណមណ្ឌល។ បន្តជំរុញផ្សព្វផ្សាយ និងអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីរួមចំណែកក្នុងការបន្តពង្រឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការលើកកម្ពស់សុខុមាលភាពកុមារឲ្យបានល្អប្រសើរនៅទូទាំងប្រទេស ដោយយកចិត្តទុកដាក់ក្នុងការទុកដាក់កុមារនៅក្នុងស្រុកឲ្យអស់លទ្ធភាពមុនឈានដល់ដំណាក់កាលអនុវត្តការងារសុំកូនអន្តរប្រទេសក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ ដើម្បីរកគ្រួសារល្អឲ្យកុមារ និងជានាឧត្តមប្រយោជន៍របស់កុមារ។ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសដែលជាភាគីអនុសញ្ញាក្រុងឡាអេ និងប្រទេសទាំងឡាយដែលមានកិច្ចសហប្រតិបត្តិការសុំកូនពីកម្ពុជា ដើម្បីទប់ស្កាត់ការជួញដូរកុមារតាមរូបភាពសុំកូនអន្តរប្រទេស និងបន្តពង្រឹងពង្រីកសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធតាមរយៈបើកវគ្គបណ្តុះបណ្តាល និងបញ្ជូនមន្ត្រីចូលរួមកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលដើម្បីដកបទពិសោធន៍ការងារ និងនីតិវិធីសុំកូនអន្តរប្រទេសលើបណ្តាប្រទេសដែលមានកិច្ចសហប្រតិបត្តិការលើការងារសុំកូនអន្តរប្រទេសជាមួយកម្ពុជា។ អនុវត្តកម្មវិធីគ្រួសារធម៌សម្រាប់កុមារនៅតាមមណ្ឌលនានា និងសហគមន៍ជួយដល់កុមារដែលក្រីក្រ និងងាយរងគ្រោះ។ ជំរុញការអនុវត្តការងារយុវនីតិសម្បទា និងអនុវត្តនូវកម្មវិធីយុត្តិធម៌អនីតិជនបន្តផ្តល់សេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ចំពោះអនីតិជនដែលប្រព្រឹត្តល្មើសនៅតាមសហគមន៍ និងពន្ធនាគារ។ ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនដើម្បីការពារសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន។ ពង្រឹងការឆ្លើយតបទៅនឹងការគាំទ្រ ការថែទាំ និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌល និងសហគមន៍ កសាងសមត្ថភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងដើម្បីសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយ ព្យាបាល ថែទាំ ស្តារនីតិសម្បទា និងផ្តល់សេវាបញ្ជូនអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ និងបង្កើនយន្តការតាមដានត្រួតពិនិត្យការអនុវត្តលើការគាំទ្រ ការព្យាបាល ការថែទាំ ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់គ្រួសារនៅតាមសហគមន៍ និងកសាងមជ្ឈមណ្ឌល

ជាតិព្យាបាល និងស្ថានីតិសម្បទាអ្នកញៀនគ្រឿងញៀន។ បន្តអនុវត្តកាតព្វកិច្ចជាសមាជិកនៃអនុសញ្ញាសិទ្ធិកុមារ រៀបចំ និងផ្ញើរបាយការណ៍ជាតិលើកទី៤ ដល់ទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ និងធ្វើរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារពាក់ព័ន្ធនានា ជូនអង្គការសហប្រជាជាតិឲ្យទាន់ពេលវេលាប្រកបដោយវិជ្ជាជីវៈ។ បន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះឆ្នាំ២០១៣-២០១៨ និងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០១៤-២០១៨។

## ២.៩.៣. អភិវឌ្ឍសុខុមាលភាពជនពិការ

ក្រសួងនឹងជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការស្របតាមគោលនយោបាយជាតិស្តីពីជនពិការ។ តាមរយៈច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការនឹងជំរុញដល់ការអនុវត្តគោលនយោបាយការពារលើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការ ព្រមទាំងបង្កឱកាសឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម។ បន្តរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងសុខុមាលភាពជនពិការ។ បន្តដំណើរការមូលនិធិជនពិការដែលមានសមត្ថកិច្ចរកចំណូល និងផ្តល់សេវាជូនជនពិការស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ បន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មជូនជនពិការដោយឥតគិតថ្លៃ រួមទាំងការផ្តល់សោហ៊ុយធ្វើដំណើរ និងការស្នាក់នៅ។ ជំរុញការអនុវត្តរបបគោលនយោបាយស្តីពីការជួយឧបត្ថម្ភជនពិការក្រីក្របំផុតនៅតាមសហគមន៍ ស្របតាមលទ្ធភាពនៃថវិកា។ បន្តអនុវត្តកម្មវិធីសេវាសហគមន៍សម្រាប់ជនពិការ ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ការបង្កើតក្រុមជួយខ្លួនឯងការអភិវឌ្ឍមុខរបរខ្នាតតូច។ លើកទឹកចិត្តដល់ការបង្កើតអង្គការជនពិការដែលដឹកនាំដោយជនពិការផ្ទាល់ដូចជាអង្គការជនពិការភ្នែក អង្គការជនពិការកម្ពុជា មជ្ឈមណ្ឌលជាតិជនពិការជាដើម និងក្រុមជួយខ្លួនឯងរបស់ជនពិការនៅតាមសហគមន៍។ ផ្តល់ឱកាសការងារដល់ជនពិការចូលបម្រើការងារតាមស្ថាប័នរដ្ឋ ២ភាគរយ និងគ្រឹះស្ថានឯកជន ១ភាគរយតាមការកំណត់នៃច្បាប់។ ជំរុញការបង្កលក្ខណៈងាយស្រួលចេញចូលទីកន្លែងសាធារណៈសម្រាប់ជនពិការគ្រប់រូប។ បន្តកម្មវិធីផ្តល់សេវាជូនកុមារពិការភ្នែក កុមារគរ ថ្លង់ និងកុមារពិការខ្សោយសតិបញ្ញាតាមរយៈការអប់រំ និងសេវាពិសេសជូនដល់ប្រភេទកុមារពិការនីមួយៗ និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍វិញដោយគ្មានការរើសអើង។ លើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា។ ជំរុញការផ្សព្វផ្សាយ និងអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការបន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់។ ក្រសួងនឹងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្ររបស់មូលនិធិជនពិការ ២០១៤-២០១៨។

## ២.៩.៤. អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

ក្រសួងនឹងបន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ និងបន្តកែសម្រួលគោលនយោបាយនេះឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ ចាត់ទុកមនុស្សចាស់ជាធនធានដ៏មានតម្លៃរបស់សង្គមដែលបានបន្សល់ទុកស្នាដៃ និងមរតកសម្រាប់សង្គមជាតិជំនាន់ក្រោយៗ។ អត្រាមនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅមាន ៦ភាគរយនៃប្រជាពលរដ្ឋ។ អត្រានេះអាចមាននិន្នាការកើនឡើងជាបន្តបន្ទាប់ស្របតាមការរីកចម្រើននៃវិស័យសុខុមាលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជំរុញសកម្មភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្ស

ចាស់(គ.ម.ច.) និងយន្តការនៅថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់ ១តុលា ជារៀងរាល់ឆ្នាំ ស្របតាមទិវាមនុស្សចាស់អន្តរជាតិ ១តុលា។ ក្រសួងនឹងបន្តអនុវត្តនូវកម្មវិធីពីរសំខាន់គឺៈ ទី១-កម្មវិធីមនុស្សចាស់តាមសហគមន៍ និងទី២-កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ។ បន្តពង្រឹងសកម្មភាពសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់ សំដៅបង្កើតឲ្យមានកម្មវិធីថែទាំសុខភាព ធនាគារស្រូវ ធនាគារគោ ឥណទានខ្នាតតូច បេឡាមរណសង្គ្រោះ និងការសាមគ្គីជួយគ្នាទៅវិញទៅមករវាងមនុស្សចាស់ដូចគ្នានៅតាមសហគមន៍ដើម្បីធ្វើឲ្យមនុស្សចាស់មានសុខភាពល្អ និងអាយុវែង រួមចំណែកក្នុងការអភិវឌ្ឍប្រទេស។ បន្តជំរុញកម្មវិធីថែទាំមនុស្សចាស់នៅតាមគ្រួសារ តាមរយៈការផ្សព្វផ្សាយលើកកម្ពស់ប្រពៃណីទំនៀមទម្លាប់របស់គ្រួសារខ្មែរ ក្នុងការគោរពដឹងគុណចំពោះមនុស្សចាស់រួមមានឪពុកម្តាយ ជីដូនជីតា។ ក្រសួងនឹងបន្តជំរុញកម្មវិធីលើកទឹកចិត្តដល់សហគមន៍ អារាមសាសនា ជាពិសេសព្រះពុទ្ធសាសនា និងសាសនាដទៃទៀតក្នុងការជួយដល់សាសនិកដែលជាជនចាស់ជរាបានជ្រកកោន។ បន្តលើកទឹកចិត្តសប្បុរសជនឲ្យបង្កើតនូវកម្មវិធីមនុស្សធម៌ដើម្បីជួយដល់ជនចាស់ជរាដូចជាការជួយសាងសង់ផ្ទះជូនដល់ជនចាស់ជរាក្រីក្រនៅតាមសហគមន៍។ លើកទឹកចិត្តដល់ឥស្សរជន សប្បុរសជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តយកចិត្តទុកដាក់ផ្តល់អំណោយមនុស្សធម៌សម្ភារៈថវិកាដល់ជនចាស់ជរាក្រីក្រគ្មានទីពឹងនៅតាមសហគមន៍។ រៀបចំ និងដំណើរការមជ្ឈមណ្ឌលសេវាជនចាស់ជរាកម្ពុជា ដើម្បីបណ្តុះបណ្តាលបុគ្គលិកភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា។ បន្តលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនឲ្យបង្កើតសេវាថែទាំសុខភាពជនចាស់ជរា។

### ២.៩.៥. អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តឲ្យស្របតាមគោលនយោបាយជាតិ ស្តីពីការផ្តល់សេវាសាធារណៈចំពោះអតីតមន្ត្រីរាជការស៊ីវិល បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលបន្តអនុវត្តរបបសន្តិសុខសង្គម ផ្អែកតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់ដើម្បីឆ្លើយតបទៅនឹងគុណបំណាច់របស់អតីតមន្ត្រីរាជការស៊ីវិលដែលបានបម្រើជាតិមាតុភូមិ និងការអភិវឌ្ឍប្រទេសជាតិ បានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។ បន្តការលើកទឹកចិត្តតាមរយៈការផ្តល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងផ្តល់នូវរបបសន្តិសុខសង្គមដោយធ្វើការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) បម្រើសេវាបើកផ្តល់របបសន្តិសុខសង្គម ដែលគ្របដណ្តប់លើតាវកាលិកចំនួន ៦រួមមាន៖ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាពនិងអ្នកនៅក្នុងបន្ទុក។ ដោយសារវិសាលភាពការងាររបស់ ប.ជ.ស.កាន់តែធំឡើង ប.ជ.ស.នឹងរៀបចំជួលអាគារធ្វើទីស្នាក់ការកណ្តាលបណ្តោះអាសន្ន ហើយឈានទៅធ្វើការសិក្សាវាយតម្លៃទិញដី និងលើកគម្រោងថវិកាសម្រាប់សាងសង់អាគារទីស្នាក់ការកណ្តាលដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។ ការធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. នៅទូទាំង ២៥ រាជធានី ខេត្តបានបញ្ចប់ជាដំណាក់កាលដំបូង ហើយ ប.ជ.ស. នឹងធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តថ្មីជាបន្តទៀត។ ចាប់ពីដំណាច់ខែកុម្ភៈ ឆ្នាំ២០១៤ នេះតទៅសិទ្ធិវន្តទូទាំងប្រទេសរបស់ ប.ជ.ស. នឹងទទួលរបបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ។ ដើម្បីសម្រួលដល់ការផ្តល់សេវាជូនសិទ្ធិវន្តនៅទូទាំងប្រទេស ប.ជ.ស. នឹងបង្កើតសាខាគ្រប់ ក្រុង ស្រុក ខណ្ឌ នៅរាជធានី ខេត្តទៅតាមស្ថានភាពជាក់ស្តែង និងតាមការងារចាំបាច់។ ការរៀបចំប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលនៃ ប.ជ.ស. ស្តីពីការអនុវត្តអត្រាភាគ

ទានជាមូលនិធិសម្រាប់ទ្រទ្រង់ ប.ជ.ស. ចំនួន ២៤ភាគរយនឹងបញ្ចប់នៅដើមឆ្នាំ២០១៤នេះ។ តាមគោលការណ៍អត្រាភាគទានចំនួន ២៤ភាគរយលើប្រាក់បៀវត្សរ៍សរុបប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល គឺរាជរដ្ឋាភិបាលនឹងផ្តល់ប្រាក់ភាគទានចំនួន ១៨ភាគរយ និង៦ភាគរយទៀតជាបន្ទុករបស់មន្ត្រីរាជការស៊ីវិល ក៏ប៉ុន្តែរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានឹងទទួលបន្ទុកបង់ជំនួសអត្រា ៦ភាគរយដែលជាបន្ទុករបស់មន្ត្រីរាជការស៊ីវិលសម្រាប់អាណត្តិទី៥ នេះ និងអាណត្តិបន្តបន្ទាប់ទៀត។ ជំរុញការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិលជាមួយក្រសួងមុខងារសាធារណៈ ដើម្បីដាក់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ឲ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងតភ្ជាប់តាមប្រព័ន្ធព័ត៌មានវិទ្យារវាង ប.ជ.ស. សម្រាប់មន្ត្រីរាជការស៊ីវិលជាមួយធនាគារដៃគូដើម្បីពង្រឹងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលឲ្យក្លាយទៅជា គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

## ២.៥.៦. អតីតវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

បន្តយកចិត្តទុកដាក់កែសម្រួលបន្ថែមរបបសន្តិសុខសង្គម ជូនអតីតយុទ្ធជនជាបន្តបន្ទាប់ស្របតាមស្ថានភាពនៃសេដ្ឋកិច្ចជាតិ។ ជំរុញដំណើរការបេឡាជាតិអតីតយុទ្ធជនដើម្បីអនុវត្តការគ្រប់គ្រងមូលនិធិ និងធានាការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារប្រកបដោយប្រសិទ្ធភាពដោយបន្តអនុវត្តរបបសន្តិសុខសង្គមជូនអតីតយុទ្ធជនលើតារាកាលិកចំនួន ៩មាន៖ ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈ ពិការភាព មានជំងឺ និងគ្រួសាររបស់ជនទាំងនោះ។ បន្តអនុវត្តនូវគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងបង្កើតគម្រោងនានាដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។ អភិវឌ្ឍសមាគមអតីតយុទ្ធជនកម្ពុជាសំដៅបន្តជួយដល់អតីតយុទ្ធជនក្នុងការកសាងជីវភាពគ្រួសារដើម្បីចូលរួមអភិវឌ្ឍន៍នៅតាមមូលដ្ឋាន។ បន្តសកម្មភាពបេឡាឥណទាន បេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន។ បង្កលក្ខណៈងាយស្រួលដល់អតីតយុទ្ធជនឲ្យទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់សម្បទានដីសង្គមកិច្ច។ល។ ក្រសួងនឹងបន្តនិរន្តរភាពតំបន់អភិវឌ្ឍន៍យុទ្ធជនពិការនៅតាកែនកោះស្លា ស្រុកឈូក ខេត្តកំពត មណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ គូលែន ខេត្តសៀមរាប និងមណ្ឌលអភិវឌ្ឍន៍យោធិនពិការភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ និងតំបន់ដទៃមួយចំនួនទៀត និងបន្តសាងសង់ផ្ទះជូនអតីតយុទ្ធជន និងគ្រួសារដែលក្រីក្របំផុតនៅតាមសហគមន៍នានា តាមរយៈសមាគមអតីតយុទ្ធជនកម្ពុជាជាបន្តបន្ទាប់។ បន្តរៀបចំទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ជារៀងរាល់ឆ្នាំ។

## ២.៥.៧. សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា

សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយ គ្របដណ្តប់លើវិសាលភាពនៃស្រទាប់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គមធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម។

## ២.៩.៨. អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

ក្រសួងនឹងបន្តកសាងសមត្ថភាពស្ថាប័ន ពង្រឹងភាពជាដៃគូ និងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈ និងបង្កើនលទ្ធភាព សមត្ថភាពរបស់មន្ត្រីសង្គមកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីឆ្លើយតបទៅនឹងភារកិច្ចក្នុងដំណាក់កាលថ្មីនេះ។ បង្កើនការគាំទ្រដំណើរការវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមកិច្ច បង្កើនការសិក្សាស្រាវជ្រាវ និងពង្រីកកម្មវិធីសិក្សាលើជំនាញផ្សេងៗទៀត ទាំងកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ។ ជំរុញការផ្សព្វផ្សាយគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងដល់មូលដ្ឋានថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ។ បន្តអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់ផ្នែកឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនប្រសិទ្ធភាពលើការផ្តល់សេវាសុខុមាលភាពសង្គម។ បន្តអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាជំហានៗ។ បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីពង្រីកនូវស្មារតីសាមគ្គីធំនៅក្នុងសង្គម និងកៀរគរប្រភពធនធានថវិកាសម្ភារៈ និងបច្ចេកទេសសម្រាប់បម្រើឱ្យសំណូមពរនៃការងារសុខុមាលភាពសង្គមជួយដល់ជនរងគ្រោះ និងងាយរងគ្រោះ និងជនក្រីក្រតាមរយៈការកសាងយន្តការសម្របសម្រួលនានា រួមទាំងការលើកទឹកចិត្តអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាចំពោះការចូលរួមសកម្មភាពលើវិស័យសង្គមកិច្ច និងយកចិត្តទុកដាក់ដល់មន្ត្រីដែលបម្រើការងារលើផ្នែកនេះផងដែរ។ ជំរុញរាល់សកម្មភាពការងារពាក់ព័ន្ធ ជាមួយអាស៊ានរួមមានសរសរស្តម្ភសហគមន៍សង្គម-វប្បធម៌អាស៊ាន និងវិស័យសុខុមាលភាពសង្គម និងអភិវឌ្ឍន៍ខិតខំអនុវត្តទៅតាមឯកសារបង្ហាញផ្លូវរបស់អាស៊ានមានផែនការលម្អិត និងតាមដានវាយតម្លៃតាមរយៈតារាងពិន្ទុរបស់សហគមន៍សង្គម-វប្បធម៌អាស៊ាន។

# ជំពូកទី៣
## តម្រូវការធនធាន

៣.១. ក្រសួងបានទទួលការវិភាជន៍ថវិកាពីរាជរដ្ឋាភិបាលក្នុងរយៈពេលបីឆ្នាំកន្លងមក (២០១១-២០១៣) មានថវិកាសរុបចំនួន ១.៣៨៤.២៤៧.៣១៦.០០០ រៀល[17] (346,061,829 USD) សម្រាប់ចំណាយលើការទិញ សេវាខាងក្រៅ សេវាខាងក្រៅផ្សេងៗបន្ទុកបុគ្គលិក ឧបត្ថម្ភធន ជំនួយសង្គម និងពន្ធអាករ។ យោងតាមការវិភាគទិន្នន័យ និងពិភាក្សាជាមួយផ្នែកជំនាញបានបង្ហាញយ៉ាងច្បាស់ថាការគ្រប់គ្រងថវិការបស់ក្រសួងពិតជាបានបម្រើនូវសំណូមពរ និងតម្រូវការចាំបាច់ដើម្បីដោះស្រាយការលំបាកជាច្រើនដែលធ្វើឲ្យចំនួនជនរងគ្រោះ និងងាយរងគ្រោះត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ និងមុខសញ្ញាបានទទួលនូវសេវាជាទីទុកចិត្ត។ កិច្ចការទាំងនេះក៏បានអនុវត្តតាមជំពូកនៃថវិកា[18] និងឆ្លុះបញ្ចាំងពីការអនុវត្តកម្មវិធីថវិការបស់ខ្លួនផងដែរ។

៣.២. ក្រសួងបានយកចិត្តទុកដាក់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ពហុភាគី ក្នុងក្របខ័ណ្ឌអាស៊ាន តំបន់ និងសកលលោក ដោយអនុវត្តគោលនយោបាយលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួលដល់អង្គការពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គិតពីឆ្នាំ ២០១១-២០១៣ នេះ ក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ១៧៦ ដែលមានថវិកាគម្រោងសរុបចំនួន ១៧២.៣០៨.៨៦៤,២៦ ដុល្លារអាមេរិកបើគិតក្នុងមួយឆ្នាំចំនួន ៥៧.៤៣៦.២៨៨,០៩ដុល្លារ ដែលរួមចំណែកសម្រាលបន្ទុកថវិកាជាតិ និងប្រមូលបាននូវធនធានមនុស្សបច្ចេកទេស និងបទពិសោធន៍ល្អៗជាច្រើនសម្រាប់ផ្តល់សេវាវិស័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។[19]

៣.៣. ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្ត៥ ឆ្នាំ២០១៤-២០១៨ និងតាមការព្យាករណ៍ នៃកម្រិតកំណើនថវិកាប្រចាំឆ្នាំគិតជាមធ្យមប្រមាណ ១០% ថវិកាដើម្បីឆ្លើយតបនូវតម្រូវការនេះដែលជាប្រភពពីរាជរដ្ឋាភិបាលប្រមាណ **៨៦២.៧៣៩.៧៦៤,៤៦** ដុល្លាអាមេរិក[20] និងថវិកាចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលប្រមាណ **២៨៧.១៨១.៤៤០,៤៥** ដុល្លារអាមេរិក។

[17] ប្រភពទិន្នន័យដកស្រង់ពីរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១១, ២០១២ និង២០១៣

[18] ជំពូក៦០:ការទិញ, ៦១:សេវាខាងក្រៅ, ៦២:សេវាខាងក្រៅផ្សេងៗ, ៦៤:បន្ទុកបុគ្គលិក, ៦៥:ឧបត្ថម្ភធន និង ៦៣:ជំនួយសង្គម ពន្ធ និងអាករ

[19] តាមប្រភពទិន្នន័យពីនាយកដ្ឋានអន្តរជាតិគិតពីឆ្នាំ២០១១-២០១៣ មានអង្គការដៃគូ ១៧៦ ចុះកិច្ចព្រមព្រៀងជាមួយក្រសួងមានថវិកាគម្រោងសរុបចំនួន ១៧២.៣០៨.៨៦៤,២៦ លានដុល្លារ គឺស្មើនឹង ៥៧.៤៣៦.២៨៨.០៩ដុល្លារក្នុងមួយឆ្នាំ។

[20] ទិន្នន័យការគ្រប់គ្រងថវិកាថ្នាក់ជាតិឆ្នាំ២០១៤ មានថវិកា ៥៦៥,២៥៨,៤០០,០០០.០០រៀល=141,314,600.00 USD (បង្កើន១០% ប្រចាំឆ្នាំនីមួយៗ) ដូច្នេះសម្រាប់ការចំណាយរបស់ក្រសួងនៅឆ្នាំ២០១៥ [155,446,060.00 USD] ឆ្នាំ២០១៦ [170,990,666.00 USD] ឆ្នាំ២០១៧ [188,089,732.60 USD] ២០១៨ [206,898,705.86 USD] សរុប 862,739,764.46 USD មិនបានបូកបញ្ចូលថវិការបស់អង្គការដៃគូប្រចាំឆ្នាំ (57,436,288.09 USD x 5=287,181,440.45 USD).

# ជំពូកទី៤
## ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

៤.១. ដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ សម្រេចបានតាមគោលដៅ និងចំណុចដៅនៃសូចនាករដែលបានកំណត់ ក្រសួងនឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាព។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពដែលបានអនុវត្តគឺជាការងារដ៏សំខាន់នៃដំណើរការការងារផែនការ។ ក្រសួងនឹងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយដោយផ្អែកលើផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស.អ.យ. ឆ្នាំ២០១៤-២០១៨។ ទន្ទឹមនឹងនេះ មន្ទីរ ស.អ.យ. រាជធានីខេត្ត ក៏ត្រូវរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួនដោយផ្អែកលើផែនការយុទ្ធសាស្ត្ររបស់ក្រសួងផងដែរ។ ផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់មន្ទីរ ស.អ.យ. រាជធានីខេត្ត នឹងត្រូវកំណត់ជាយុទ្ធសាស្ត្រ កម្មវិធី សូចនាករ ចំណុចដៅ និងសកម្មភាពជាក់លាក់ដែលនឹងត្រូវអនុវត្ត។

៤.២. នីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុវត្តជាបីដំណាក់កាលគឺទី១ ធ្វើឡើងនៅរាល់ចុងឆ្នាំនីមួយៗ ទី២ នៅពាក់កណ្តាលអាណត្តិ (ឆមាសទី២ នៃឆ្នាំ២០១៦) និងទី៣ ធ្វើឡើងនៅក្នុងឆ្នាំ២០១៨។ ក្រសួងនឹងរៀបចំយន្តការសម្រាប់ប្រមូលទិន្នន័យ និងធ្វើការវិភាគដើម្បីវាស់វែងសមិទ្ធផល និងវឌ្ឍនភាពដែលក្រសួងសម្រេចបាន។ នាយកដ្ឋានផែនការ ស្ថិតិ និងសរុបត្រូវធ្វើជាស្នូលនៃការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដោយសហការជាមួយនាយកដ្ឋានជំនាញ អង្គភាពចំណុះ និងផ្នែកពាក់ព័ន្ធទាំងអស់។ នាយកដ្ឋានជំនាញ អង្គភាពចំណុះ និងភាគីដៃគូពាក់ព័ន្ធទាំងអស់ដែលធ្វើការងារលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវផ្តល់អាទិភាពខ្ពស់ដល់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃយ៉ាងទៀងទាត់លើការអនុវត្តកម្មវិធី គម្រោង និងផែនការសកម្មភាពរបស់ខ្លួន។

៤.៣. ផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស.អ.យ. ឆ្នាំ២០១៤-២០១៨ គឺជាឯកសារចាំបាច់ដ៏មានសារសំខាន់ និងជាឧបករណ៍បង្ហាញផ្លូវសម្រាប់នាយកដ្ឋានជំនាញ អង្គភាពចំណុះ និងភាគីពាក់ព័ន្ធនានាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលត្រូវមានភារកិច្ចតាមដានត្រួតពិនិត្យ និងវាយតម្លៃ ហើយត្រូវធ្វើការកែលម្អជាលំដាប់ឲ្យសមស្របទៅនឹងបច្ចុប្បន្នភាពនៃបរិបទរបស់កម្ពុជា។

# សេចក្តីសន្និដ្ឋាន

១. ផែនការយុទ្ធសាស្រ្ត របស់ក្រសួង ស.អ.យ. ឆ្នាំ២០១៤-២០១៨ ត្រូវបានរៀបចំកសាងឡើងនៅឆ្នាំ ២០១៣ ក្រោមការដឹកនាំចង្អុលទិសពីឯកឧត្តមរដ្ឋមន្រ្តី និងការចូលរួមរបស់ក្រុមការងារ នាយកដ្ឋានជំនាញ អង្គភាពចំណុះដោយមានការសម្របសម្រួលពិគ្រោះយោបល់ និងពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីដៃគូពាក់ព័ន្ធនានាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

២. ផែនការយុទ្ធសាស្រ្តនេះ គឺជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តយុទ្ធសាស្រ្ត កម្មវិធី និងបេសកកម្មរបស់ក្រសួង ស.អ.យ. ដើម្បីរួមចំណែកអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា យុទ្ធសាស្រ្តចតុកោណដំណាក់កាលទីIII និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨។

៣. ផែនការយុទ្ធសាស្រ្តនេះ មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់សុខុមាលភាពសង្គមសម្រាប់ប្រជាជន ក៏ដូចជាមុខសញ្ញាទទួលរបបសន្តិសុខសង្គមពីរាជរដ្ឋាភិបាល ជាពិសេសក្រុមជនរងគ្រោះ និងងាយរងគ្រោះ និងលើកស្ទួយជីវភាពរស់នៅ ទប់ស្កាត់ភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ បង្កើនអន្តរាគមន៍សង្គមជួយដល់ប្រជាជនទន់ខ្សោយជាងគេក្នុងសង្គម និងបង្កឱកាសទទួលបានផ្លែផ្កានៃការអភិវឌ្ឍប្រកបដោយសមធម៌។ ពង្រឹងប្រព័ន្ធសន្តិសុខសង្គមដែលមានស្រាប់ និងពង្រីកប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយមានវិសាលភាពគ្របដណ្តប់គ្រប់មជ្ឈដ្ឋាននៅក្នុងសង្គមធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម។ ជំរុញការបង្វិតសេវាសុខុមាលភាពសង្គមឲ្យជិតកៀកមុខសញ្ញា ជនរងគ្រោះ និងងាយរងគ្រោះ និងប្រជាជន កែលម្អគុណភាពការផ្តល់សេវាឲ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អ្នកទទួលសេវា។

៤. ផែនការយុទ្ធសាស្រ្តនេះ គឺជាក្របខ័ណ្ឌយុទ្ធសាស្រ្តថ្មីមួយសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលអាចគ្របដណ្តប់រាល់ការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពពាក់ព័ន្ធទាំងអស់។ ផែនការយុទ្ធសាស្រ្តនេះតម្រូវឲ្យមានការចូលរួម ការប្តេជ្ញាចិត្តពីក្រសួង ស.អ.យ. និងការគាំទ្រពីដៃគូពាក់ព័ន្ធ ព្រមទាំងសប្បុរសជននានា។ ផែនការយុទ្ធសាស្រ្តនេះនឹងធ្វើឲ្យមានភាពសុខដុមនីយកម្មរវាងកម្មវិធី គម្រោងរបស់ក្រសួងជាមួយកម្មវិធី គម្រោងរបស់អង្គការដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ផែនការយុទ្ធសាស្រ្តនេះនឹងឆ្លើយតបទៅនឹងសំណូមពររបស់ភាគីពាក់ព័ន្ធ និងជួយដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយ ដើម្បីធ្វើឲ្យសម្រេចបាននូវយុទ្ធសាស្រ្ត គោលដៅ កម្មវិធី និងសូចនាករដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**ឧបសម្ព័ន្ធ៖**

**ក-តារាងសូចនាករ និងចំណុចដៅ**

# ឧបសម្ព័ន្ធ ក: តារាងសូចនាករ និងចំណុចដៅ

## យុទ្ធសាស្ត្រទី1.បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

### កម្មវិធី 1.1. អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ

**គោលដៅ 1.1.1. ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ និងងាយរងគ្រោះ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | ជនរងគ្រោះ និងងាយរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ និងទីទំលក្រដែលត្រូវបានស្រង់ទិន្នន័យ *"ទិន្នន័យកាត់បន្ថយ"* | គ្រួសារ | 584,861 | 526,375 | 473,738 | 426,364 | 383,728 | 345,355 |
| 2 | ជនរងគ្រោះ និងងាយរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ និងទីទំលក្រដែលទទួលបានជំនួយសង្រោះបន្ទាន់ *"ទិន្នន័យកាត់បន្ថយ"* | គ្រួសារ | 68,834 | 68,146 | 67,465 | 66,790 | 66,122 | 65,461 |
| 3 | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលការងារសង្គ្រោះបន្ទាន់ | នាក់ | 48 | 48 | 48 | 48 | 48 | 48 |

**សកម្មភាពអនុវត្ត:**

- ចុះស្រាវជ្រាវទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ និងទីទំលក្រ
- រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការងារសង្គ្រោះសង្គមសម្រាប់ប្រជាជនរងគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ និងប្រជាជនក្រីក្រងាយរងគ្រោះនៅក្នុងសង្គម
- រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលការងារសង្គ្រោះបន្ទាន់ និងត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃកម្មវិធីសង្គ្រោះបន្ទាន់ និងកម្មវិធីជំនួយសង្គ្រោះសង្គម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយដល់ជនរងគ្រោះមហន្តរាយផ្សេងៗមានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត
- សហការដៃគូ ជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ចនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញការណែនាំ និងការផ្តល់សេវាសង្គមកិច្ចនានា
- បំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋានក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានាដើម្បីជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ។

### គោលដៅ 1.1.2. ទប់ស្កាត់ និងការពារជនអនាថា

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 4 | ជនអនាថានៅរាជធានី ខេត្តដែលត្រូវបានស្រង់ទិន្នន័យ | នាក់ | 2,237 | 2,215 | 2,192 | 2,170 | 2,148 | 2,126 |
| 5 | ជនអនាថាដែលទទួលបានសេវាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្ម | នាក់ | 893 | 884 | 875 | 866 | 857 | 848 |
| 6* | ប្រជាជនដែលបានចូលរួមវគ្គផ្សព្វផ្សាយស្តីពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព | នាក់ | 50,869 | 55,956 | 61,551 | 67,707 | 74,477 | 81,925 |

**សកម្មភាពអនុវត្ត:**

- រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា
- បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា
- រៀបចំ និងអនុវត្តលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងមណ្ឌលស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនអនាថា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងកម្មវិធី ដែលមានការពាក់ព័ន្ធទៅនឹងកិច្ចការពារជនអនាថា
- រៀបចំបណ្តាញសង្គមកិច្ចនៅថ្នាក់ឃុំ/សង្កាត់ និងផ្សព្វផ្សាយការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅកម្រិតថ្នាក់ឃុំ/សង្កាត់។

### គោលដៅ 1.1.3. ផ្តល់សេវាការពារជនផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 7 | មន្ត្រីថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីពី នីតិវិធីសេវាថែទាំ គាំទ្រដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ | នាក់ | 128 | 137 | 147 | 155 | 162 | 168 |
| 8* | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗដែលទទួលបានសេវាថែទាំ និងគាំទ្រនៅតាមសហគមន៍ | នាក់ | 9,185 | 9,644 | 10,104 | 10,563 | 11,022 | 11,481 |
| 9* | មន្ត្រីថ្នាក់ជាតិចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃការងាររបស់មន្ត្រីថ្នាក់ក្រោមជាតិ | ដង | 12 | 13 | 14 | 15 | 16 | 17 |

**សកម្មភាពអនុវត្ត:**

- រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាព ដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាការពារជនផ្ទុកមេរោគអេដស៍ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- បំពេញមុខងារជាលេខាធិការដ្ឋានគណៈកម្មាធិការការពារទប់ស្កាត់មេរោគអេដស៍ជំងឺអេដស៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសហគមន៍ក្នុងការផ្តល់សេវាការពារអ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងជំងឺកាចសាហាវផ្សេងៗ
- ផ្តល់សេវាសង្គមកិច្ចរួមទាំងអ្នកវិកលចរិក-គាំទ្រសង្គម និងការថែរក្សាចំពោះកុមារ និងគ្រួសារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ ឬជំងឺឆ្លងផ្សេងៗ
- ផ្តល់ការបណ្តុះបណ្តាល និងពង្រឹងសហគមន៍អ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញអេដស៍។

### គោលដៅ 1.1.4. លើកកម្ពស់សុខុមាលភាពគ្រួសារ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 10 | អ្នកដែលបានចូលរួមទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា | នាក់ | 1,820 | 2,002 | 2,202 | 2,422 | 2,665 | 2,931 |

**សកម្មភាពអនុវត្ត:**

- រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការលើកកម្ពស់សុខុមាលភាពគ្រួសារ
- រៀបចំគោលការណ៍ និងចាត់ចែងទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា ដោយសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធនានា។

### គោលដៅ 1.1.5. បញ្ជ្រាបការងារយេនឌ័រ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 11* | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីពីទស្សនទានយេនឌ័រ និងការផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ | នាក់ | 144 | 159 | 174 | 192 | 211 | 232 |

**សកម្មភាពអនុវត្ត:**

- រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការងារយេនឌ័រ
- រៀបចំគោលការណ៍ និងបើកវគ្គបណ្តុះបណ្តាល ការងារយេនឌ័រ និងផ្សព្វផ្សាយអនុសញ្ញាស៊ី.ដ ដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### គោលដៅ 1.1.6. ផ្តល់កិច្ចការពារ និងទប់ស្កាត់អំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីកម្ម

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 12 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានជួយគាំពារ និងសង្គ្រោះ | នាក់ | 212 | 200 | 200 | 200 | 200 | 200 |
| 13 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលស្តារនីតិសម្បទា | នាក់ | 100 | 250 | 250 | 250 | 250 | 250 |
| 14 | អ្នកផ្តល់សេវាទទួលបានការបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធការជួញដូរមនុស្ស | នាក់ | 150 | 600 | 600 | 600 | 600 | 600 |
| 15 | អ្នកដែលបានចូលរួមវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល | នាក់ | គ្មាន | 250 | 372 | 372 | 372 | 372 |
| 16 | មជ្ឈមណ្ឌលស្នាក់នៅ និងមជ្ឈមណ្ឌលស្តារ[1] ដែលត្រូវបានធ្វើអធិការកិច្ច | លើក | គ្មាន | 28 | 28 | 28 | 28 | 28 |
| 17 | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានការស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា | នាក់ | 170 | 250 | 400 | 400 | 400 | 400 |

**សកម្មភាពអនុវត្ត:**

- ធ្វើវិសោធនកម្មគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងផ្សព្វផ្សាយបើកវគ្គបណ្តុះបណ្តាលបន្ត
- រៀបចំគោលនយោបាយ ប្រកាសស្តីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងរៀបចំបទដ្ឋានគតិយុត្ត និងឧបករណ៍សម្រាប់ធ្វើអធិការកិច្ចលើមជ្ឈមណ្ឌល រដ្ឋ និងអង្គការ និងធ្វើការសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនៅខេត្តបន្ទាយមានជ័យ (រយៈពេលខ្លី) និងសាងសង់មជ្ឈមណ្ឌលសំចតស្តារនីតិសម្បទា(រយៈពេលវែង)
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីការពារ និងទប់ស្កាត់ជនរងគ្រោះ និងអន្តរាគមន៍សង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន ធ្វើអាជីកម្ម និងចាត់វិធានការផ្លូវច្បាប់ ដើម្បីឆ្លើយតប និងទប់ស្កាត់ការជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីកម្ម និងដើម្បីកំណត់នីតិវិធីបែបបទនៃដំណើរការគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីវកម្ម ដោយស្វែងរកគ្រួសារ ធ្វើផែនការប៉ាន់ប្រមាណគ្រួសារ សមាហរណកម្ម តាមដានការបញ្ជូនបន្តទៅអង្គការដៃគូ អន្តរាគមន៍មានវិបត្តិ និងបិទករណី

[1] មជ្ឈមណ្ឌលរដ្ឋ និងអង្គការ

- បើកវគ្គបណ្តុះបណ្តាលដល់អ្នកផ្តល់សេវានៅមូលដ្ឋានសហគមន៍ ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការថែទាំជនរងគ្រោះក្នុងមជ្ឈមណ្ឌល និងឧបករណ៍វាស់វែង។ បំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រងករណីតាមបណ្តារាជធានី ខេត្ត ពាក់ព័ន្ធការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធអំពើជួញដូរមនុស្ស
- រៀបចំប្រកាសស្តីពីការបង្កើតមជ្ឈមណ្ឌលសំចតប៉ោយប៉ែត និងមជ្ឈមណ្ឌលស្តារនីតិសម្បទា ។

**គោលដៅ 1.1.7. ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 18 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ | នាក់ | 30 | 220 | 220 | 220 | 220 | 220 |
| 19 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបាននីរទេស | នាក់ | 150 | 180 | 180 | 180 | 180 | 180 |
| 20 | មន្ត្រីដែលត្រូវទទួលបានបង្កើនសមត្ថភាពបន្ថែមលើកិច្ចសហការស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ក្នុងនិង ក្រៅប្រទេស) | នាក់ | 5 | 10 | 10 | 10 | 10 | 10 |

**សកម្មភាពអនុវត្ត:**

- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេស និងភាគីថៃ វៀតណាម ទទួលនិងប្រគល់ជនរងគ្រោះ
- បញ្ជូនមន្ត្រីជំនាញចូលរួមសហការជាមួយប្រទេសជិតខាង បង្កើនសមត្ថភាពបន្ថែម និងចែករំលែកបទពិសោធន៍
- ធ្វើការទំនាក់ទំនងជាមួយប្រទេសជិតខាង ដើម្បីធ្វើការតាមដានដល់លំនៅដ្ឋានជនរងគ្រោះនៅក្រៅប្រទេស[2]
- មន្ទីរ ស.អ.យ. រាជធានី ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលធ្វើសមាហរណកម្មនៅសហគមន៍ និងបញ្ជូនទៅរកសេវា
- បញ្ជូន និងផ្តល់សេវា និងបណ្តុះបណ្តាលជំនាញដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងតាមដានបន្តដោយមន្ត្រី ស.អ.យ. រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក
- រៀបចំគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ
- រៀបចំកិច្ចប្រជុំករណីជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស

[2] ប្រទេសវៀតណាមជាដើម

### គោលដៅ 1.1.8. ធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ការរំលោភបំពាន និងធ្វើអាជីវកម្ម

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 21 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវទទួលបានការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ (១៣ខេត្ត) | នាក់ | 458 | 1,000 | 1,000 | 1,000 | 1,000 | 1,000 |
| 22 | សេវា[3] ដែលត្រូវបានផ្ដល់ឲ្យជនរងគ្រោះដោយអំពើជួញដូរមនុស្ស[4] | សេវា | 1.162 | 1,516 | 1,516 | 1,516 | 1,516 | 1,516 |
| 23 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបានបិទករណី[5] | នាក់ | គ្មាន | 150 | 300 | 300 | 300 | 300 |

**សកម្មភាពអនុវត្ត:**

- អនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីវកម្ម
- រៀបចំ និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីវកម្ម
- រៀបចំ និងអនុវត្តកម្មវិធីស្រាវជ្រាវស្វែងរកគ្រួសារ និងប៉ាន់ប្រមាណគ្រួសារជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីវកម្ម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលដើម្បីកំណត់នីតិវិធីបែបបទនៃដំណើរការគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពាន និងធ្វើអាជីវកម្ម ដោយស្វែងរកគ្រួសារ ធ្វើផែនការប៉ាន់ប្រមាណគ្រួសារ សមាហរណកម្ម តាមដាន ការបញ្ជូនបន្តទៅអន្តរាគមន៍ មានវិបត្តិ និងបិទករណី
- ទទួលនិងបញ្ជូនជនរងគ្រោះពីអង្គការ ស្ថាប័នពាក់ព័ន្ធ ផ្ដល់សេវាសង្គ្រោះបន្ទាន់
- សហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីផ្ដល់កន្លែងស្នាក់នៅ ការអប់រំ ថែទាំសុខភាព សេវាផ្លូវច្បាប់ ដល់ជនរងគ្រោះដោយសារអំពើជួញដូរ រំលោភបំពាន និងធ្វើអាជីវកម្ម
- ទំនាក់ទំនងជាមួយប្រទេសនានាដែលពាក់ព័ន្ធ ដើម្បីផ្លាស់ប្ដូរព័ត៌មាន និងផ្ដល់កិច្ចការពារ និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការដែលនៅជាធរមាន
- សន្និសិទករណីនៅតាមបណ្ដាខេត្ត រាជធានីពាក់ព័ន្ធ (ស្ថាប័នពាក់ព័ន្ធ កាកបាទក្រហម កិច្ចការនារី មហាផ្ទៃ អប់រំ សុខាភិបាល NGOs មន្ត្រី ស.អ.យ. ក្រុង ខណ្ឌ រយៈពេល២ខែម្ដង)
- រៀបចំកិច្ចប្រជុំសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល និងអង្គការដៃគូរ សហការនៅថ្នាក់ជាតិ ២ ខែម្ដង
- កែសម្រួលសារាចរណែនាំ ស្ដីពីការធ្វើសមាហរណកម្មជនរងគ្រោះ។

[3] សេវារួមមានៈ អប់រំ ឥណទាន សុខាភិបាល ពិគ្រោះយោបល់ ជំនួយផ្លូវច្បាប់ សួរសុខទុក្ខ បណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាដើម

[4] ជនរងគ្រោះ ១រូបអាចទទួលបានសេវាចាប់ពី ២ឡើង

[5] ជនរងគ្រោះមានស្ថានភាពនឹងនរ ជនរងគ្រោះទៅរស់នៅក្នុងមជ្ឈមណ្ឌល ជនរងគ្រោះស្លាប់ ជនរងគ្រោះមិនគោរពតាមកិច្ចសន្យា និងជនរងគ្រោះផ្លាស់ទីលំនៅជាដើម។

## កម្មវិធី 1.2. អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

### គោលដៅ 1.2.1. ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងវិស័យសុខុមាលភាពកុមារ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | មន្ត្រីថ្នាក់ជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីអំពីនីតិវិធីអនុវត្ត គោលនយោបាយថែទាំជំនួសចំពោះកុមារ  គោលការណ៍ណែនាំ និងបទដ្ឋាននានាដែលពាក់ព័ន្ធនឹងសុខុមាលភាពកុមារ | នាក់ | 20 | 15 | 15 | 15 | 15 | 15 |
| 2 | មន្ត្រីថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីអំពីនីតិវិធីអនុវត្ត គោលនយោបាយថែទាំជំនួសចំពោះកុមារ | នាក់ | 730 | 1,000 | 1,000 | 1,000 | 1,000 | 1,000 |
| 3 | បុគ្គលិកអង្គការដែលទទួលបានការបណ្តុះបណ្តាលស្តីអំពីនីតិវិធីអនុវត្ត គោលនយោបាយថែទាំជំនួសចំពោះកុមារ | នាក់ | 29 | 100 | 100 | 100 | 100 | 100 |
| 4 | មន្ត្រីអង្គការដែលទទួលបានការបណ្តុះបណ្តាលអំពីគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ | នាក់ | 300 | 300 | 300 | 300 | 300 | 300 |
| 5 | អង្គការដែលទទួលវិញ្ញាបនបត្រជាអង្គការសុវត្ថិភាពកុមារ | អង្គការ | 6 | 10 | 10 | 10 | 10 | 10 |

**សកម្មភាពអនុវត្ត:**

- ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយនីតិវិធី និងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារនៅក្នុងក្រសួង និងក្រៅក្រសួង ស.អ.យ.
- រៀបចំហ្វឹកហ្វឺន និងធ្វើសិក្ខាសាលាដើម្បីពង្រឹងប្រសិទ្ធភាពបន្ថែមលើការថែទាំជំនួសចំពោះកុមារ រួមទាំងការកសាងសមត្ថភាពសម្រាប់ប្រតិបត្តិករ រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលស្តីពីក្របខណ្ឌការងារថែទាំជំនួសចំពោះកុមារ
- ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយនីតិវិធី ស្តីពីអង្គការសុវត្ថិភាពកុមារដល់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើវិស័យសុខុមាលភាពកុមារ
- ចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តបទដ្ឋានអប្បបរមាស្តីពីអង្គការសុវត្ថិភាពកុមារដល់អង្គការដែលបានដាក់ពាក្យស្នើសុំ
- ផ្តល់វិញ្ញាបនប័ត្រអង្គការសុវត្ថិភាពដល់អង្គការដែលអនុវត្តស្របតាមបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ

**គោលដៅ 1.2.2. ពង្រឹង និងពង្រីកសេវាថែទាំជំនួសចំពោះកុមារជាលក្ខណៈគ្រួសារ និងសហគមន៍**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 6* | កុមារដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | 85,921 | 90,000 | 95,000 | 100,000 | 105,000 | 110,000 |
| 7 | កុមារដែលមានតម្រូវការថែទាំជំនួសនៅតាមសហគមន៍ត្រូវបានកំណត់អត្តសញ្ញាណ | នាក់ | គ្មាន | 500 | 500 | 500 | 500 | 500 |
| 8 | កុមារនៅក្នុងការថែទាំជំនួសដែលត្រូវបានបង្រួបបង្រួមគ្រួសារ ឬធ្វើសមាហរណកម្មក្រោមអាយុ១៨ឆ្នាំ | នាក់ | 58 | 400 | 400 | 400 | 400 | 400 |
| 9 | គ្រួសារដែលទទួលបានការបណ្តុះបណ្តាលជាគ្រួសារធម៌ | គ្រួសារ | គ្មាន | 100 | 100 | 100 | 100 | 100 |
| 10 | កុមារដែលត្រូវបានទុកដាក់អចិន្ត្រៃយ៍ | នាក់ | គ្មាន | 50 | 50 | 50 | 50 | 50 |
| 11 | អង្គការដែលបានចូលជាសមាជិកបណ្តាញគ្រួសារធម៌ | អង្គការ | 25 | 5 | 5 | 5 | 5 | 5 |
| 12 | កន្លែងថែទាំជំនួសចំពោះកុមារជាលក្ខណៈសហគមន៍ដែលត្រូវបានធ្វើអធិការកិច្ច | កន្លែង | 150 | 150 | 150 | 150 | 150 | 150 |

**សកម្មភាពអនុវត្ត:**

- ប្រមូលទិន្នន័យកុមាររងគ្រោះនៅថ្នាក់ស្រុក និងរក្សាទុកសំណុំឯកសារករណីដោយផ្អែកលើវឌ្ឍនភាពនៃករណីបុគ្គលនីមួយៗ
- ផ្តល់សេវារក្សាកុមារគ្រួសារក្នុងកិច្ចសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ
- ផ្តល់សេវាបង្រួបបង្រួមគ្រួសារ ដោយធ្វើកិច្ចសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ដែលជាប្រយោជន៍សម្រាប់កុមារ
- អនុវត្តផែនការអចិន្ត្រៃយ៍សម្រាប់ករណីកុមារទាំងអស់ដែលត្រូវការគ្រួសារអចិន្ត្រៃយ៍ ដោយសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការកិច្ចការស្ត្រី និងកុមារ
- ជ្រើសរើស បណ្តុះបណ្តាល និងគាំទ្រគ្រួសារដែលមានបំណងចង់ក្លាយជាគ្រួសារសុំកូនក្នុងស្រុក និងគ្រួសារធម៌
- ធ្វើបច្ចុប្បន្នភាពកុមារដែលត្រូវបោះបង់ចោល គ្រួសារធម៌  និងសាច់ញាតិ
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ និងអន្តរជាតិក្នុងការផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងការងារសុខុមាលភាពកុមារ
- បង្កើតយន្តការអន្តរក្រសួងរួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងនីតិវិធីសម្របសម្រួលសម្រាប់ឆ្លើយតបករណីរំលោភបំពាន  អំពើហឹង្សា ឬការមិនអើពើចំពោះកុមារដែលស្ថិតក្នុងការថែទាំជំនួស និងសហការជាមួយក្រសួងយុត្តិធម៌ដើម្បីរៀបចំនីតិវិធីសុំកូនក្នុងប្រទេស។

**គោលដៅ 1.2.3. ពង្រឹងគុណភាពសេវាថែទាំកុមារក្នុងមណ្ឌល**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 13 | អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារត្រូវបានរៀបចំបង្កើត | ច្បាប់ | ពង្រៀង | អនុម័ត/ផ្សព្វផ្សាយ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| 14 | អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋត្រូវបានធ្វើកែសម្រួល | ច្បាប់ | មាន | អនុម័ត/ផ្សព្វផ្សាយ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| 15* | កុមារកំព្រា និងកុមារងាយរងគ្រោះដែលទទួលបានការរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | 11,856 | 10,310 | 9,942 | 9,574 | 9205 | 8837 |
| 16 | កុមារនៅក្នុងមណ្ឌលត្រូវបានកំណត់អត្តសញ្ញាណ | នាក់ | 189 | 300 | 400 | 500 | 600 | 700 |
| 17 | កុមារអាយុលើសពី១៨ឆ្នាំ ដែលបានចាកចេញពីមណ្ឌលត្រូវបានធ្វើសមាហរណកម្មទៅរស់នៅតាមសហគមន៍ | នាក់ | គ្មាន | 500 | 500 | 500 | 500 | 500 |
| 18 | មណ្ឌលថែទាំកុមារដែលទទួលបានធ្វើអធិការកិច្ចការអនុវត្តបទដ្ឋានអប្បបរមា (មណ្ឌលរដ្ឋ និងអង្គការ) | មណ្ឌល | 200 | 200 | 200 | 200 | 200 | 200 |
| 19 | មណ្ឌលថែទាំកុមារដែលត្រូវបានរៀបចំផែនទី | ខេត្ត | គ្មាន | 5 | 9 | 10 | | |

**សកម្មភាពអនុវត្ត:**

- រៀបចំ និងអនុវត្តអនុក្រឹត្យការគ្រប់គ្រងមណ្ឌលថែទាំកុមារ
- អនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ រួមទាំងការត្រួតពិនិត្យការអនុវត្តចំពោះបទដ្ឋាន
- សហការជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការអនុវត្តគោលនយោបាយថែទាំជំនួស និងបទដ្ឋានអប្បបរមា
- ពិនិត្យសំណើរបស់អង្គការមិនមែនរដ្ឋាភិបាល និងប្រតិបត្តិករផ្សេងទៀតទាក់ទងទៅនឹងការបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលថែទាំដោយផ្អែកតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា។

### គោលដៅ 1.2.4. ជំរុញការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជនដើម្បីការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 20 | សេចក្តីព្រៀងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវទទួលបានការអនុម័ត[6] | ច្បាប់ | បញ្ចប់សេចក្តីព្រៀង | បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត | រៀបចំគោលការណ៍ណែនាំអនុវត្ត/បណ្តុះបណ្តាល | បណ្តុះបណ្តាល | អនុវត្ត | អនុវត្ត |

**សកម្មភាពអនុវត្ត:**

- រៀបចំអនុក្រឹត្យស្តីពីការអនុវត្តច្បាប់យុត្តិធម៌អនីតិជន
- រៀបចំ និងបណ្តុះបណ្តាលគោលការណ៍ណែនាំអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### គោលដៅ 1.2.5. អប់រំផ្សព្វផ្សាយទប់ស្កាត់ ការប្រព្រឹត្តបទល្មើស និងការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 21 | អ្នកដែលបានចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន | នាក់ | 2,000 | 12,000 | 12,000 | 9,600 | 7,200 | 6,000 |
| 22 | អ្នកដែលបានចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ | នាក់ | 5,000 | 5,000 | 5,000 | 5,000 | 5,000 | 5,000 |

**សកម្មភាពអនុវត្ត:**

- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយទប់ស្កាត់សម្រាប់អនីតិជនប្រព្រឹត្តបទល្មើស និងជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍
- ប្រមូល និងគ្រប់គ្រងទិន្នន័យអនីតិជនប្រព្រឹត្តខុសនឹងច្បាប់ និងជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍
- រៀបចំសិក្ខាសាលា វគ្គបំប៉នសម្រាប់មន្ត្រីសង្គមកិច្ច និងមន្ត្រីពាក់ព័ន្ធ ស្តីពីកិច្ចការពារ អប់រំសិទ្ធិកុមារ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន។

[6] ច្បាប់នេះចាប់ផ្តើមពីឆ្នាំ២០០២ដោយអន្តរក្រសួងមាន: យុត្តិធម៌ មហាផ្ទៃ ស.អ.យ NGOs UNICEF UNOHCR ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### គោលដៅ 1.2.6. ស្តារនីតិសម្បទា និងសមាហរណកម្មអនីតិជនប្រព្រឹត្តបទល្មើសនៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទា មណ្ឌលអប់រំកែប្រែ និងពន្ធនាគារ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 23 | រៀបចំអនុក្រឹត្យស្តីពីការស្តារនីតិសម្បទា និងសមាហរណកម្មអនីតិជនប្រព្រឹត្តបទល្មើសនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគារត្រូវបានរៀបចំ | អនុក្រឹត្យ | គ្មាន | សេចក្តីព្រាង | អនុម័ត/ផ្សព្វផ្សាយ | អនុវត្ត | អនុវត្ត | អនុវត្ត |
| 24 | រៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួង ស.អ.យ.ស្តីពី ការចិញ្ចឹមបីបាច់ថែរក្សាកូនតាមម្តាយនៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារដែលមានអាយុចាប់ពី ៣(បី)ឆ្នាំឡើងត្រូវបានរៀបចំឡើង | ប្រកាស | គ្មាន | សេចក្តីព្រាង | អនុម័ត/ផ្សព្វផ្សាយ | អនុវត្ត | អនុវត្ត | អនុវត្ត |
| 25 | អនីតិជនប្រព្រឹត្តិបទល្មើសនៅក្នុងមណ្ឌលយុវនីតិសម្បទា មណ្ឌលអប់រំកែប្រែ និងពន្ធនាគារដែលទទួលបានសេវាស្តារនីតិសម្បទា និងសមាហរណកម្ម | នាក់ | គ្មាន | 250 | 300 | 600 | 500 | 400 |
| 26 | កុមារតាមម្តាយដែលមានអាយុចាប់ពី ៣(បី)ឆ្នាំឡើងក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារដែលត្រូវទទួលបានសេវាការពារ និងថែទាំ | នាក់ | 50 | 50 | 45 | 40 | 30 | 25 |

**សកម្មភាពអនុវត្ត:**

- ប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យស្តីពីអនីតិជនប្រព្រឹត្តបទល្មើស នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា មជ្ឈមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ
- ពិនិត្យសំណើរបស់អាជ្ញាធរ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីបង្កើត និងគ្រប់គ្រងកម្មវិធីស្តារនីតិសម្បទាដល់អនីតិជនប្រព្រឹត្តបទល្មើស
- រៀបចំនីតិវិធីដើម្បីអនុញ្ញាតឲ្យគ្រប់គ្រងករណី និងផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម និងតាមដានបន្ត
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិស្តីពីការធ្វើសមាហរណកម្ម និងតាមដានទៀងទាត់ចំពោះអនីតិជនប្រព្រឹត្តបទល្មើសដោយផ្អែកលើនីតិវិធីគ្រប់គ្រងករណីដែលមានស្រាប់ ។
- ផ្តល់អាហារូបត្ថម្ភ សម្លៀកបំពាក់ដល់កុមារ តាមម្តាយ និងសម្របសម្រួលជាមួយសាច់ញាតិដើម្បីរកអ្នកថែទាំជំនួស នៅពេលកុមារមានអាយុលើសពី ៣ឆ្នាំ
- រៀបចំ បណ្តុះបណ្តាល និងអនុវត្តអនុក្រឹត្យស្តីពីការស្តារនីតិសម្បទា និងសមាហរណកម្មអនីតិជនប្រព្រឹត្តបទល្មើស
- រៀបចំ និងអនុវត្តប្រកាសអន្តរក្រសួងស្តីពីការចិញ្ចឹមបីបាច់ថែរក្សាកូនតាមម្តាយនៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ

**គោលដៅ 1.2.7. ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមណ្ឌលរដ្ឋ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 27 | រៀបចំអនុក្រឹត្យស្តីពីវិធីសាស្រ្តព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទា ភាពញៀនគ្រឿងញៀន | អនុក្រឹត្យ | គ្មាន | សេចក្តីព្រាង | អនុម័ត/ផ្សព្វផ្សាយ | អនុវត្ត | អនុវត្ត | អនុវត្ត |
| 28 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋដែលទទួលបានសេវាស្តារនីតិសម្បទា | នាក់ | 1,100 | 1,000 | 950 | 950 | 950 | 900 |
| 29 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនស្នាក់នៅក្នុងមជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល | នាក់ | 190 | 190 | 190 | 190 | 190 | 200 |

**សកម្មភាពអនុវត្ត:**

- រៀបចំគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីសម្រាប់ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- ប្រមូល និងគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមជ្ឈមណ្ឌល
- រៀបចំប្រកាសបញ្ចេញបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនរបស់មជ្ឈមណ្ឌល
- សហការជាមួយក្រសួងសុខាភិបាលដើម្បីព្យាបាលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនតាមបែបវេជ្ជសាស្រ្ត
- ពិនិត្យសំណើរបស់ស្ថាប័នពាក់ព័ន្ធ និងអង្គការជាតិ អន្តរជាតិក្រៅរដ្ឋាភិបាលស្តីពីការបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- រៀបចំផែនការសមាហរណកម្ម និងតាមដានសម្រាប់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនទៅសហគមន៍
- វាយតម្លៃការគ្រប់គ្រង ការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនរបស់មជ្ឈមណ្ឌលរដ្ឋ
- រៀបចំបណ្តុះបណ្តាល និងអនុវត្តអនុក្រឹត្យ គោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន។

### គោលដៅ 1.2.8. ពង្រឹងការឆ្លើយតបទៅនឹងការគាំទ្រ ការថែទាំ ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាម មជ្ឈមណ្ឌល និងសហគមន៍

| ល.រ | ការកំណត់សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 30 | គោលការណ៍ណែនាំ សម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន | ច្បាប់ | 01 | 01 | 01 | 01 | 01 | 01 |
| 31 | មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនត្រូវបានសាងសង់នៅកែវផុស ខេត្តព្រះសីហនុ | កន្លែង | 01 | 01 | គ្មាន | គ្មាន | គ្មាន | គ្មាន |
| 32 | អ្នកញៀនគ្រឿងញៀនបានទទួលសេវាការព្យាបាល និងបន្សាប | នាក់ | 50 | 100 | 200 | 300 | 350 | 500 |
| 33 | អ្នកញៀនគ្រឿងញៀនបានទទួលសេវាស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | 25 | 100 | 100 | 200 | 200 | 300 |
| 34 | អតិថិជនធ្វើសមាហរណកម្ម និងតាមដាននៅសហគមន៍ | នាក់ | 25 | 100 | 100 | 100 | 200 | 300 |
| 35 | បណ្តុះបណ្តាលធនធានមនុស្សរបស់មជ្ឈមណ្ឌលជាតិ | នាក់ | 09 | 20 | 25 | 30 | 35 | 40 |

សកម្មភាពអនុវត្តៈ

- កសាងគោលនយោបាយជាតិដែលជួយឲ្យមានការថយចុះនូវគ្រោះថ្នាក់ដោយសារការប្រើប្រាស់គ្រឿងញៀនរួមមានផ្នែកសុខភាព ផ្នែកសង្គមផ្នែកសេដ្ឋកិច្ចដល់បុគ្គល គ្រួសារ និងសហគមន៍
- ផ្តល់សេវាបន្សាបព្យាបាលដល់អ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនៅក្នុងមជ្ឈមណ្ឌលជាតិដោយមិនមានការរើសអើង
- ផ្តល់សេវាស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនៅក្នុងមជ្ឈមណ្ឌលជាតិដោយមិនមានការរើសអើង
- ផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត មិនគិតថ្លៃ និងផ្តល់សេវារកការងារធ្វើ
- ផ្តល់សេវាសមាហរណកម្ម និងថែទាំតាមដានបន្តនៅក្នុងសហគមន៍បង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនសារជាថ្មី
- ទស្សនកិច្ចសិក្សាអន្តរជាតិស្វែងយល់អំពីគំរូនៃការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនឲ្យមានប្រសិទ្ធភាព
- រៀបចំសិក្ខាសាលាស្តីពីបេកគំហើញនៃការកំណត់នីតិវិធីសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទានៅតាមសហគមន៍និង មជ្ឈមណ្ឌលស្តារនីតិសម្បទា
- បណ្តុះបណ្តាលមន្ត្រីជំនាញទាក់ទងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរយៈពេល ៣ទៅ៦ខែនៅប្រទេសវៀតណាម
- បណ្តុះបណ្តាលបំប៉នមន្ត្រីជំនាញព្យាបាល និងស្តារនីតិសម្បទាក្នុងប្រទេសកម្ពុជា។

**គោលដៅ 1.2.9. ធានាថាអ្នកថែទាំកុមារ និងក្រុមគ្រួសារកុមារមានសមត្ថភាពថែទាំ គាំទ្រ និងការពារកុមារកំព្រា និងកុមារងាយរងគ្រោះតាមផ្ទះសហគមន៍ និងមណ្ឌលប្រកបដោយគុណភាព  និងប្រសិទ្ធភាពស្របតាមនីតិវិធីនៃការថែទាំជំនួសចំពោះកុមារ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 36 | គ្រួសារកុមារកំព្រា និងកុមារងាយរងគ្រោះទទួលបានការគាំទ្រដើម្បីប្រកបមុខរបរបានទទួលជោគជ័យ | % | 20 | 30 | 50 | 52 | 55 | 60 |
| 37 | អ្នកថែទាំដែលទទួលបានបណ្តុះបណ្តាលក្នុងការថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះ | % | 0 | 0 | 20 | 30 | 40 | 50 |
| 38 | អ្នកផ្តល់សេវាដែលបានបណ្តុះបណ្តាលក្នុងការថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះ | % | 0 | 0 | 50 | 55 | 60 | 70 |

**សកម្មភាពអនុវត្ត:**

- បង្កើនប្រសិទ្ធភាពការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដល់កុមារកំព្រា និងកុមារងាយរងគ្រោះ និងគ្រួសារ
- បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលមុខរបរកុមារកំព្រា និងកុមារងាយរងគ្រោះ និងក្រុមគ្រួសារពិសេសគ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ និងមានកុមារកំព្រា និងកុមារងាយរងគ្រោះក្នុងបន្ទុក
- ពង្រឹងសមត្ថភាពអ្នកថែទាំកុមារ និងក្រុមគ្រួសារកុមារតាមផ្ទះ សហគមន៍ មណ្ឌលសាសនា និងមណ្ឌលថែទាំជំនួសដទៃទៀតស្តីពីរបៀបនៃការថែទាំកុមារ។

**គោលដៅ 1.2.10. ធានាថាការថែទាំ ការគាំទ្រ និងការការពារកុមារកំព្រា និងកុមារងាយរងគ្រោះនៅតាមសហគមន៍ ព្រមទាំងមណ្ឌលសាសនា ទទួលបានការគាំទ្រ លើកទឹកចិត្ត និងមានគុណភាពខ្ពស់**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 39 | ឃុំ/សង្កាត់ដែលយ៉ាងតិចណាស់មានស្ថាប័ន ឬអង្គការ០១ កំពុងទទួលបានផ្តល់ការថែទាំ និងគាំទ្រដល់កុមារកំព្រា និងកុមារងាយរងគ្រោះ | % | 71 | 75 | 80 | 85 | 90 | 95 |
| 40 | ឃុំ/សង្កាត់ដែលត្រូវបានដាក់បញ្ចូលបញ្ហាកុមារកំព្រា និងកុមារងាយរងគ្រោះទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខ្លួន | % | 0 | 0 | 50 | 70 | 80 | 90 |
| 41 | មណ្ឌលថែទាំជំនួសចំពោះកុមារ សហគមន៍ និងគ្រួសារ ដែលអនុវត្តបាននូវបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ | % | 70 | 75 | 80 | 85 | 90 | 95 |
| 42 | កុមារកំព្រា និងកុមារងាយរងគ្រោះដែលបានធ្វើការបង្រួបបង្រួមគ្រួសារប្រកបដោយជោគជ័យ | % | 1 | 5 | 10 | 12 | 13 | 15 |

**សកម្មភាពអនុវត្ត:**

- បង្កើនប្រសិទ្ធភាព នៃការធ្វើសមាហរណកម្មកុមារពីមណ្ឌលទៅបង្រួបបង្រួមក្នុងក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ ស្របតាមនីតិវិធីនៃការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- ពង្រឹងការធ្វើសមាហរណកម្មបញ្ហា និងតម្រូវការរបស់កុមារកំព្រានិងកុមារងាយរងគ្រោះទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ/សង្កាត់។

**គោលដៅ 1.2.11. ធានាថាកុមារកំព្រា និងកុមារងាយរងគ្រោះទទួលបាននូវសេវាថែទាំ គាំទ្រ និងការពារស្របតាមបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 43 | ក្រុមគ្រួសារដែលមានកុមារកំព្រា និងកុមារងាយរងគ្រោះបានទទួលប័ណ្ណសមធម៌ | % | 70 | 75 | 85 | 90 | 93 | 95 |
| 44 | កុមារកំព្រា និងកុមារងាយរងគ្រោះដែលគ្រួសារបានទទួលការគាំទ្រ យ៉ាងហោចណាស់ ០៣កញ្ចប់នៃកញ្ចប់ទាំង ៦តាមបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ | % | 0 | 30 | 50 | 55 | 60 | 70 |
| 45 | កុមារផ្ទុកមេរោគអេដស៍ ក្នុងដំណាក់កាលចុងក្រោយទទួលការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ | % | 95 | 95.5 | 96 | 96.5 | 97 | 98 |

**សកម្មភាពអនុវត្ត:**

- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការស្វែងរកការគាំទ្រ ឲ្យកុមារកំព្រា និងកុមារងាយរងគ្រោះ និងគ្រួសារក្រីក្រដែលមានកុមារកំព្រា និងកុមារងាយរងគ្រោះក្នុងបន្ទុកទទួលបានប័ណ្ណសមធម៌ និងពង្រីកវិសាលភាពនៃការប្រើប្រាស់ប័ណ្ណសម្រាប់វិស័យដទៃទៀត ក្រៅពីវិស័យសុខភាព
- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការស្វែងរកការគាំទ្រឲ្យគ្រួសារកុមារកំព្រា និងកុមារងាយរងគ្រោះទទួលបានការថែទាំ គាំទ្រ និងការពារតាមតម្រូវការជាពិសេសនៅពេលដែលមានគ្រោះមហន្តរាយកើតឡើង
- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើឲ្យប្រសើរឡើងដល់ការផ្តល់សេវាថែទាំគាំទ្រ និងការពារដល់កុមារកំព្រា និងងាយរងគ្រោះ។

**គោលដៅ 1.2.12. ធានាថាកុមារកំព្រា និងកុមារងាយរងគ្រោះទទួលបានការការពារពីអំពើហិង្សា ការរើសអើង ការជួញដូរ និងការរំលោភបំពានគ្រប់ទម្រង់ តាមរយៈការតាក់តែង និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 46 | កម្រិតនៃការអនុវត្តគោលនយោបាយ គោលការណ៍ណែនាំ និងច្បាប់ដែលពាក់ព័ន្ធទៅនឹងកិច្ចការថែទាំ គាំទ្រ និងការពារដល់កុមារកំព្រា និងកុមារងាយរងគ្រោះ | % | 60 | 65 | 70 | 72 | 75 | 80 |
| 47 | កម្រិតនៃការចូលរួមរបស់កុមារកំព្រា និងកុមារងាយរងគ្រោះក្នុងការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃរបស់យន្តការឆ្លើយតបនានាដែលទាក់ទងទៅនឹងកុមារកំព្រា និងកុមារងាយរងគ្រោះ | ពិន្ទុ | 2 | 2 | 2 | 2 | 2 | 3 |

**សកម្មភាពអនុវត្តៈ**

- បង្កើនប្រសិទ្ធភាពការការពារកុមារដោយបញ្ចូលការការពារកុមារទៅក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តកិច្ចការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរ និងទម្រង់កេងប្រវ័ញ្ចផ្សេងៗព្រមទាំងជំរុញការតាក់តែងគោលនយោបាយ ច្បាប់ និងគោលការណ៍ណែនាំចាំបាច់នានាដែលពាក់ព័ន្ធ
- ពង្រឹងយន្តការ និងលើកទឹកចិត្តឲ្យមានការចូលរួមរបស់កុមារក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ការផ្ដល់សេវាកម្ម ការត្រួតពិនិត្យ និងវាយតម្លៃ។

**គោលដៅ 1.2.13. ធានាបាននូវបរិយាកាសគាំទ្រសម្រាប់ការសម្របសម្រួលដែលមានលក្ខណៈពហុវិស័យដើម្បីបង្កើនប្រសិទ្ធភាពក្នុងការថែទាំការគាំទ្រ និងការការពារកុមារកំព្រា និងកុមារងាយរងគ្រោះ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 48 | ការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើកុមារកំព្រា និងកុមារងាយរងគ្រោះនៅគ្រប់កម្រិត (វាស់វែងតាមរយៈឧបករណ៍ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ) | % | 10 | 30 | 60 | 70 | 75 | 80 |
| 49 | កម្រិតនៃប្រសិទ្ធភាព របស់យន្តការសម្របសម្រួលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍សម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះ (ប្រើប្រាស់ឧបករណ៍ដែលសមស្រប) | % | 0 | 30 | 70 | 75 | 80 | 90 |
| 50 | សរុបនៃក្រុមការងារថ្នាក់ខេត្តពហុវិស័យស្ដីពីកុមារកំព្រា និងកុមារងាយរងគ្រោះ | ខេត្ត | 6 | 2 | 2 | 2 | 1 | 2 |

**សកម្មភាពអនុវត្ត:**

- បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការធ្វើសហប្រតិបត្តិការ និងលទ្ធភាពធ្វើសមាហរណកម្មយន្តការសម្របសម្រួលគ្រប់លំដាប់ថ្នាក់ជាពិសេសថ្នាក់ក្រោមជាតិ
- បង្កើនប្រសិទ្ធភាពនិងពង្រីកវិសាលភាពនៃប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃកុមារកំព្រា និងកុមារងាយរងគ្រោះនៅទូទាំងប្រទេស
- ធ្វើសមាហរណកម្មបញ្ហាកុមារកំព្រា និងកុមារងាយរងគ្រោះទៅក្នុងកម្មវិធីការងាររបស់ក្រសួង ស.អ.យ. និងស្របតាមយុទ្ធសាស្ត្រជាតិគាំពារសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងក្របខណ្ឌសង្គមវប្បធម៌អាស៊ាន
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយផ្នែកឯកជនដើម្បីផ្តល់ការថែទាំ ការគាំទ្រ និងការការពារកុមារកំព្រា និងកុមារងាយរងគ្រោះឲ្យមានប្រសិទ្ធភាព។

## គោលដៅ 1.2.14. ធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 51 | កុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនអន្តរប្រទេស | នាក់ | គ្មាន | 20 | 50 | 100 | 100 | 100 |
| 52 | ទីភ្នាក់ងារដែលធ្វើការសុំកូនអន្តរប្រទេស ក្នុងប្រទេសកម្ពុជាប្រកបដោយវិជ្ជាជីវៈ គុណវុឌ្ឍិ និងក្រមសីលធម៌ត្រឹមត្រូវ | ទីភ្នាក់ងារ | គ្មាន | 10 | 20 | 20 | 20 | 20 |
| 53 | ការតាមដាន និងត្រួតពិនិត្យលើការអភិវឌ្ឍរបស់កូនសុំក្រោយសុំកូនអន្តរប្រទេស | លើក | គ្មាន | 0 | 1 | 2 | 2 | 2 |
| 54 | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាល ស្តីពីសុំកូនអន្តរប្រទេសនៅក្នុងប្រទេស | នាក់ | 20 | 50 | 100 | 100 | 100 | 100 |
| 55 | មន្ត្រីថ្នាក់ជាតិដែលទទួលបានការបណ្តុះបណ្តាល ស្តីពីសុំកូនអន្តរប្រទេសនៅក្រៅប្រទេស | នាក់ | 6 | 6 | 6 | 8 | 8 | 8 |

**សកម្មភាពអនុវត្ត:**

- បង្កើតនីតិវិធី និងទម្រង់ឯកសារសុំកូនអន្តរប្រទេសទៅតុលាការដោយមានការទទួលស្គាល់ជាអន្តរក្រសួង
- បង្កើត និងបន្តយន្តការសហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអំពីដំណើរការសុំកូនអន្តរប្រទេស
- អភិវឌ្ឍន៍ និងរៀបចំបង្កើតសូចនាករ និងយន្តការសម្រាប់ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ និងនិយ័តកម្មដែលទាក់ទងនឹងរដ្ឋបាលសុំកូនអន្តរប្រទេស ដោយធានាឲ្យមាននូវការត្រួតពិនិត្យប្រកបដោយគុណភាព និងការពិនិត្យផ្ទៀងផ្ទាត់សមស្រប ការបណ្តុះបណ្តាលបុគ្គលិក និងការអនុវត្តនូវការត្រួតពិនិត្យជាក់ស្តែង និងសកម្មភាពអធិការកិច្ច

- ធ្វើបច្ចុប្បន្នភាពលើគេហទំព័រអំពីការវិវឌ្ឍការងារសុំកូនអន្តរប្រទេស
- ផ្សព្វផ្សាយព័ត៌មានផ្សេងៗទាក់ទងនឹងសុំកូនអន្តរប្រទេសតាមរយៈសិក្ខាសាលានានា និងប្រព័ន្ធផ្សព្វផ្សាយជាតិ អន្តរជាតិ (វិទ្យុ ទូរទស្សន៍)
- រក្សាដំណើរការផ្តល់កុមារប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគិតគូរខ្ពស់អំពីឧត្តមប្រយោជន៍របស់កុមារ
- ធ្វើទំនាក់ទំនងជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល និងទីភ្នាក់ងារដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារទាក់ទងនឹងសុំកូនអន្តរប្រទេស
- បង្កើនកិច្ចសហការល្អជាមួយបណ្តាប្រទេសដែលមានបំណងធ្វើកិច្ចសហប្រតិបត្តិការសុំកូននៅកម្ពុជា
- តាមដានត្រួតពិនិត្យសកម្មភាពរបស់ទីភ្នាក់ងារសំដៅណែនាំទីភ្នាក់ងារឲ្យអនុវត្ត និងឆ្លើយតបទៅនឹងបទដ្ឋានគតិយុត្តរបស់ប្រទេសកម្ពុជា និងអនុសញ្ញាក្រុងឡាអេ បានល្អ
- បង្កើតយន្តការតាមដាន និងត្រួតពិនិត្យវាយតម្លៃដំណើរការសុំកូនអន្តរប្រទេស និងក្រោយសុំកូនអន្តរប្រទេស
- ធ្វើការតាមដាន និងត្រួតពិនិត្យលើដំណើរការសុំកូនអន្តរប្រទេស និងក្រោយសុំកូនអន្តរប្រទេសតាមរយៈទស្សនកិច្ចដល់ទីកន្លែងផ្ទាល់ ឬតាមរយៈទីភ្នាក់ងារ ឬតាមរយៈអ៊ីម៉ែលរបស់ឪពុកម្តាយចិញ្ចឹមដោយផ្ទាល់
- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមកុំព្យូទ័រសម្រាប់រក្សាព័ត៌មាន ឯកសារ និងរបាយការណ៍តាមដានកុមារ អ្នកសុំ និងទីភ្នាក់ងារ
- សិក្សាករណីជាក់ស្តែងរបស់កុមារនីមួយៗដែលកើតមាននៅរដ្ឋបាលសុំកូនអន្តរប្រទេសជាប្រចាំខែ
- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលសុំកូនអន្តរប្រទេសលើការវិភាគ សំណុំឯកសារទីភ្នាក់ងារ សំណុំឯកសារកុមារ និងគ្រួសារអ្នកស្នើសុំឆ្លើយតបនឹងបទដ្ឋានគតិយុត្តរបស់ប្រទេសកម្ពុជា និងអនុសញ្ញាក្រុងឡាអេដោយអនុវត្តការងារជាក់ស្តែងតាមបណ្តាទីភ្នាក់ងារ
- ធ្វើការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលសុំកូនក្នុង និងក្រៅប្រទេសដើម្បីមានសមត្ថភាពក្នុងការបំពេញការងារ និងឆ្លើយតបបានត្រឹមត្រូវនូវរាល់ទស្សនៈទាំងឡាយដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស។

**គោលដៅ 1.2.15. ពង្រឹងប្រពន្ធ័ពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 56 | របាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារត្រូវបានរៀបចំ | របាយការណ៍ | 2 | 2 | 2 | 2 | 2 | 3 |
| 57 | សូចនាករសិទ្ធិកុមារថ្នាក់ជាតិដែលបានបញ្ចូលក្នុងប្រពន្ធ័ព័ត៌មានកម្ពុជា (CamInfo) | សូចនាករ | 58 | 61 | 61 | 61 | 63 | 66 |
| 58 | បញ្ហារបស់កុមារត្រូវបានធ្វើការស្រាវជ្រាវ | លើក | 2 | 2 | 2 | 2 | 2 | 2 |

**សកម្មភាពអនុវត្ត:**

- រៀបចំរបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ
- រៀបចំរបាយការណ៍ផ្សេងៗពាក់ព័ន្ធការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិជូនរាជរដ្ឋាភិបាល
- រៀបចំបញ្ចូលសូចនាករពាក់ព័ន្ធសិទ្ធិកុមារទៅក្នុងប្រពន្ធ័ព័ត៌មានកម្ពុជា (CAMINFO) ដោយសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ពាក់ពន្ធ័ដើម្បីបញ្ចូលសូចនាករថ្មីៗមួយចំនួនពាក់ពន្ធ័នឹងសិទ្ធិកុមារទៅក្នុងប្រពន្ធ័ទិន្នន័យដែលមានស្រាប់របស់ក្រសួង ស្ថាប័ន
- ប្រមូលទិន្នន័យពីក្រសួងស្ថាប័នពាក់ពន្ធ័បញ្ចូលក្នុងប្រពន្ធ័ទិន្នន័យរបស់ ក.ជ.ក. ដែលមានស្រាប់
- រៀបចំរបៀបវារៈនៃការសិក្សាស្រាវជ្រាវពីបញ្ហារបស់កុមារដើម្បីយល់ដឹងកាន់តែច្បាស់ពីតម្រូវការចាំបាច់របស់កុមារ។

**គោលដៅ 1.2.16. ពង្រឹងប្រពន្ធ័ការពារកុមារ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 59 | សេចក្តីសម្រេចស្តីពីគោលការណ៍នៃការចូលរួមរបស់កុមារត្រូវបានរៀបចំឡើង | ច្បាប់ | អនុម័ត | បណ្តុះបណ្តាល | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| 60 | ច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានរៀបចំឡើង | ច្បាប់ | សិក្សាស្រាវជ្រាវ | សេចក្តីព្រាង | សេចក្តីព្រាង | សេចក្តីព្រាង | សេចក្តីព្រាង | សេចក្តីព្រាង |

**សកម្មភាពអនុវត្ត:**

- រៀបចំច្បាប់ស្តីពីការការពារកុមារ និងផែនការជាតិអភិវឌ្ឍន៍កុមាររយៈពេល ១០ឆ្នាំ និងធ្វើការតាមដានការអនុវត្តច្បាប់ពាក់ព័ន្ធការការពារកុមារ
- ជំរុញការអនុវត្តផែនការជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (២០១២-២០១៧)
- រៀបចំផែនការសកម្មភាពផ្អែកលើលទ្ធផលការវិភាគចន្លោះខ្វះខាតនៃក្របខណ្ឌច្បាប់ពាក់ពន្ធ័ការការពារកុមារ
- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ពាក់ពន្ធ័ឱ្យអនុវត្តផែនការសកម្មភាពពាក់ពន្ធ័នឹងការការពារកុមារ
- រៀបចំផែនការទាក់ទាញមតិគាំទ្រសម្រាប់ចរិកាសង្គមផ្តោតលើវិស័យសុខុមាលភាពកុមារ។

### គោលដៅ 1.2.17. លើកកម្ពស់ការយល់ដឹងសិទ្ធិកុមារ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 61 | គ្រូបង្គោលសិទ្ធិកុមារដែលទទួលបានការបណ្តុះបណ្តាលមេរៀនស្តីពីសិទ្ធិកុមារ | នាក់ | 10 | 5 | 5 | 5 | 5 | 5 |
| 62 | អ្នកធ្វើការងារពាក់ព័ន្ធនឹងកុមារដែលទទួលបានការបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ និងគោលការណ៍ចូលរួមរបស់កុមារ | នាក់ | 150 | 50 | 50 | 50 | 50 | 50 |
| 63 | ឧបករណ៍ផ្សព្វផ្សាយពាក់ព័ន្ធនឹងសិទ្ធិកុមារត្រូវបានផលិត | ច្បាប់ | 2 | 2 | 2 | 2 | 2 | 2 |
| 64 | កុមារដែលបានចូលរួមទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា | នាក់ | 3,000 | 6,600 | 6,600 | 6,600 | 6,600 | 6,600 |
| 65 | ព្រឹត្តប័ត្រស្តីពីស្ថានភាពកុមារដែលត្រូវបានផលិត | ច្បាប់ | 1 | 1 | 2 | 2 | 2 | 2 |

**សកម្មភាពអនុវត្ត:**

- រៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា រៀងរាល់ឆ្នាំ
- ផ្សព្វផ្សាយសារាចរណែនាំស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ
- ផ្សព្វផ្សាយ ច្បាប់ គោលនយោបាយ របាយការណ៍ជាតិ របាយការណ៍សិក្សាស្រាវជ្រាវ ផែនការ គោលការណ៍ និងពិធីសារបន្ថែមពាក់ព័ន្ធទៅនឹងសិទ្ធិកុមារ
- ផ្សព្វផ្សាយគោលការណ៍នៃការចូលរួមរបស់កុមារដល់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ
- រៀបចំវេទិកា ពិភាក្សា និងវិភាគលើបញ្ហាសិទ្ធិកុមារដែលទាក់ទងនឹងការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិលើគោលនយោបាយពីយន្តការការការពារកុមារ

ដែលមានការចូលរួមពីយុវជន សមាគមសេដ្ឋកិច្ច វិទ្យាស្ថានសេដ្ឋកិច្ច និងស្រាវជ្រាវ
- បង្កើតបណ្តាញកុមារពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារ
- បើកវគ្គបណ្តុះបណ្តាលមេរៀនសិទ្ធិកុមារដល់មន្ត្រីនៃក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ និងផលិតសម្ភារៈផ្សព្វផ្សាយរួមមានសៀវភៅផ្ទត់ ព្រឹត្តិបត្រ ខិតប័ណ្ណស្តីពីសិទ្ធិកុមារ។

### គោលដៅ 1.2.18. បង្កើនសមត្ថភាពស្ថាប័ន និងភាពជាដៃគូ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 66 | មន្ត្រីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត និងក្រសួងស្ថាប័នដែលទទួលបានការបណ្តុះបណ្តាល | នាក់ | 40 | 45 | 45 | 45 | 45 | 45 |

**សកម្មភាពអនុវត្ត:**
- បង្កើតអនុគណៈកម្មការកៀរគរធនធាន និងរៀបចំផែនការយុទ្ធសាស្ត្រកៀរគរធនធាន
- ចូលរួមការពាររបាយការណ៍ជាតិនៅគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ កិច្ចប្រជុំអាស៊ាន តំបន់ អន្តរជាតិពាក់ពន្ធ័នឹងកុមារ
- រៀបចំសន្និសិទថ្នាក់តំបន់ស្តីពីផលប៉ះពាល់សង្គមលើស្ត្រី និងកុមារដោយការបម្រែបម្រួលអាកាសធាតុ
- កែសម្រួលអនុគណៈកម្មការរៀបចំច្បាប់ គោលនយោបាយពាក់ពន្ធ័នឹងកុមារ
- ស្នើសុំមន្ត្រីក្របខណ្ឌក្រសួង ស.អ.យ. និងកិច្ចសន្យាមកបំពេញការងារតាមការិយាល័យ
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីលើកគម្រោងថវិកាជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បណ្តុះបណ្តាលសមត្ថភាពមន្ត្រី ក.ជ.ក. ថ្នាក់ជាតិ និងថ្នាក់ខេត្តទៅតាមមុខងារ និងតួនាទីតាមរយៈវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- សម្របសម្រួល និងកៀរគរធនធានពីអង្គការដៃគូអភិវឌ្ឍន៍នានាសំដៅបម្រើការងារកុមារ ស្វែងរកទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិជួយពង្រឹងសមត្ថភាព។

**គោលដៅ 1.2.19. ផ្តល់បណ្តាញទូរស័ព្ទជំនួយកុមារសម្រាប់សេវាពិគ្រោះយោបល់ និងព័ត៌មាន**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 67 | កុមារដែលទទួលបានសេវាពិគ្រោះបញ្ហាព័ត៌មាន និងសេវាបញ្ជូនបន្ត និងតាមដានដោយឥតគិតថ្លៃ | នាក់ | 16,000 | 17,000 | 17,000 | 17,000 | 17,000 | 17,000 |
| 68 | យុវវ័យដែលទទួលបានសេវាពិគ្រោះបញ្ហា សេវាព័ត៌មាននិងសេវាបញ្ជូនបន្ត និងតាមដានដោយឥតគិតថ្លៃ | នាក់ | 10,500 | 10,600 | 10,600 | 10,600 | 10,600 | 10,600 |
| 69 | គ្រូបង្រៀនដែលបានដឹងពីសេវាបណ្តាញទូរស័ព្ទជំនួយកុមារ និងសហការធ្វើអន្តរាគមន៍សម្រាប់ហេតុការណ៍បន្ទាន់ពាក់ព័ន្ធនឹងកុមារ និងយុវវ័យ | នាក់ | 60 | 60 | 60 | 60 | 60 | 60 |
| 70 | កុមារ និងយុវវ័យដែលបានដឹងពីសេវាបណ្តាញទូរស័ព្ទជំនួយកុមារ និងសហការធ្វើអន្តរាគមន៍សម្រាប់ហេតុការណ៍បន្ទាន់ពាក់ព័ន្ធនឹងកុមារ និងយុវវ័យ | នាក់ | 150 | 150 | 150 | 150 | 150 | 150 |
| 71 | អាជ្ញាធរមូលដ្ឋានដែលបានដឹងពីសេវាបណ្តាញទូរស័ព្ទជំនួយកុមារ និងសហការធ្វើអន្តរាគមន៍សម្រាប់ហេតុការណ៍បន្ទាន់ពាក់ព័ន្ធនឹងកុមារ និងយុវវ័យ | នាក់ | 60 | 60 | 60 | 60 | 60 | 60 |
| 72 | នគរបាលដែលបានដឹងពីសេវាបណ្តាញទូរស័ព្ទជំនួយកុមារ និងសហការធ្វើអន្តរាគមន៍សម្រាប់ហេតុការណ៍បន្ទាន់ពាក់ព័ន្ធនឹងកុមារ និងយុវវ័យ | នាក់ | 60 | 60 | 60 | 60 | 60 | 60 |
| 73 | កុមារ និងយុវវ័យងាយរងគ្រោះពីគ្រប់ខេត្តក្រុងដែលទទួលបានសេវាសមស្របជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល | នាក់ | 25 | 25 | 25 | 25 | 25 | 25 |
| 74 | សម្ភារៈផ្សព្វផ្សាយត្រូវបានផលិត និងចែកចាយ | សន្លឹក | 20,000 | 20,000 | 20,000 | 20,000 | 20,000 | 20,000 |
| 75 | ស្ប៉ុតវិទ្យុត្រូវបានផលិត និងចាក់ផ្សាយ | ស្ប៉ុត | 1 | 1 | 1 | 1 | 1 | 1 |
| 76 | បុគ្គលិកក្រសួង ស.អ.យ. ត្រូវបានអញ្ជើញឲ្យចូលរួមវគ្គបំប៉នសមត្ថភាពលើជំនាញពិគ្រោះបញ្ហា និងកិច្ចការពារកុមារ | នាក់ | 2 | 2 | 2 | 2 | 2 | 2 |
| 77 | ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធអាចទទួលបានទិន្នន័យច្បាស់លាស់ស្តីពីសុខុមាលភាពកុមារពីបណ្តាញទូរស័ព្ទជំនួយកុមារ | ស្ថាប័ន | 14 | 14 | 14 | 14 | 14 | 14 |

**សម្ទភាពអនុវត្ត:**

- រៀបចំដំណើរការសេវាបណ្តាញទូរស័ព្ទជំនួយកុមារ ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍តាមរយៈការផ្តល់សេវាពិគ្រោះបញ្ហាសេវាព័ត៌មាន និងសេវាបញ្ជូនបន្ត និងតាមដានព្រមទាំងធានាការសម្ងាត់ជូនកុមារ និងយុវវ័យ
- ចុះផ្សព្វផ្សាយសេវាបណ្តាញទូរស័ព្ទជំនួយកុមារនៅតាមខេត្តក្រុងអាស្រ័យទៅតាមថវិកាដែលអាចមាន
- បញ្ជូនកុមារ និងយុវវ័យដែលងាយរងគ្រោះ ឬជាជនរងគ្រោះទៅកាន់សេវាដែលមានស្រាប់ជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល
- កុមារ និងយុវវ័យ ៧០ភាគរយដែលទទួលបានសេវាពិគ្រោះបញ្ហាពីបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាមានសភាពធូរស្បើយ និងមានអារម្មណ៍ល្អប្រសើរឡើងវិញ
- ផលិតសម្ភារៈផ្សព្វផ្សាយពីសេវាកម្មបណ្តាញទូរស័ព្ទជំនួយកុមារអាស្រ័យតាមថវិកាដែលអាចមាន
- ចូលរួមបង្កើនសមត្ថភាពមន្ត្រីក្រសួង ស.អ.យ. លើជំនាញពិគ្រោះបញ្ហា និងកិច្ចការពារកុមារអាស្រ័យតាមថវិកាដែលអាចមាន
- ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន នគរបាល អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ក្នុងការអន្តរាគមន៍ និងផ្តល់សេវាដែលសមស្រប
- ចូលរួមផ្តល់ទិន្នន័យស្តីពីសុខុមាលភាពកុមារជូនស្ថាប័នរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធដែលបម្រើដល់ផលប្រយោជន៍នៃការគាំទ្រគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តក្នុងកិច្ចការពារកុមារ និងមនុស្សវ័យក្មេង ។

## កម្មវិធី 1.3. អភិវឌ្ឍសុខុមាលភាពជនពិការ

### គោលដៅ 1.3.1. ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការស្របតាមគោលនយោបាយជាតិ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុខុមាលភាពជនពិការត្រូវបានរៀបចំ | ច្បាប់ | 7 | 9 | 5 | 4 | 4 | 4 |
| 2 | គ្រូឧទ្ទេសច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការដែលទទួលបានការបណ្តុះបណ្តាល | នាក់ | 90 | 90 | 90 | 90 | 90 | 90 |
| 3 | អ្នកដែលបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពិការភាព | នាក់ | 300 | 300 | 300 | 300 | 300 | 300 |
| 4 | ឧបករណ៍ផ្សព្វផ្សាយពាក់ព័ន្ធនឹងពិការភាពត្រូវបានផលិតៈ | | | | | | | |
| | – ទស្សនាវដ្តីដែលត្រូវបានផលិត | ច្បាប់ | 3,000 | 3,000 | 3,000 | 3,000 | 3,000 | 3,000 |
| | – ខិតប័ណ្ណដែលត្រូវបានផលិត | សន្លឹក | 10,000 | 10,000 | 10,000 | 10,000 | 10,000 | 10,000 |
| | – ឈុតវីដេអូផ្សព្វផ្សាយដែលត្រូវបានផលិត | ឈុត | 1 | 2 | 2 | 2 | 2 | 2 |
| | – ឈុតវិទ្យុផ្សព្វផ្សាយដែលត្រូវបានផលិត | ឈុត | គ្មាន | 2 | 2 | 2 | 2 | 2 |
| | – វេទិកាតុមូលត្រូវបានផ្សព្វផ្សាយ | លើក | 1 | 1 | 1 | 2 | 2 | 2 |

**សកម្មភាពអនុវត្តៈ**

- រៀបចំ និងអនុម័តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិជនពិការ
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិជនពិការ
- ផ្សព្វផ្សាយច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពិការភាព តាមរយៈការផលិត ការចែកចាយ និងការចាក់ផ្សាយនូវឧបករណ៍ផ្សព្វផ្សាយដូចជា ទស្សនាវដ្តី ខិតប័ណ្ណ ឈុតវីដេអូ ឈុតវិទ្យុ។ល។

**គោលដៅ 1.3.2. បន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 5 | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | 28,000 | 28,000 | 28,000 | 28,000 | 28,000 | 28,000 |
| 6 | សេវា និងឧបករណ៍ដែលត្រូវបានផ្តល់ជូនជនពិការពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា | | | | | | | |
| | – គ្រឿងផ្សំអវយវៈសិប្បនិម្មិត រណបដែលត្រូវបានផលិត និងបែងចែកជូនមជ្ឈមណ្ឌល | រាយ/ឃិត/គ្រឿង | 13,000 | 13,000 | 13,000 | 13,000 | 13,000 | 13,000 |
| | – គ្រឿងផ្សំឧបករណ៍ទ្រទ្រង់រាងកាយ | រាយ | 8,000 | 8,000 | 8,000 | 8,000 | 8,000 | 8,000 |
| | – អវយវៈសិប្បនិម្មិត និងរណប និងគ្រឿងជំនួយការដើរត្រូវបានផ្តល់ជូនជនពិការ | គ្រឿង | 18,000 | 18,000 | 18,000 | 18,000 | 18,000 | 18,000 |
| | – រទេះរុញ ត្រូវបានផ្តល់ជូនជនពិការ | គ្រឿង | 1,600 | 1,600 | 1,600 | 1,600 | 1,600 | 1,600 |
| | – សេវាព្យាបាលដោយចលនាដែលត្រូវបានផ្តល់ជូនជនពិការ | ដង | 96,000 | 96,000 | 96,000 | 96,000 | 96,000 | 96,000 |
| | – ជនពិការ ដែលត្រូវបានទទួលសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | 24,000 | 24,000 | 24,000 | 24,000 | 24,000 | 24,000 |
| 7 | មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តារលទ្ធភាពពលកម្មកាយសម្បទានៅក្នុងប្រទេស | នាក់ | 170 | 170 | 170 | 170 | 170 | 170 |
| 8 | មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តារលទ្ធភាពពលកម្មកាយសម្បទានៅក្រៅប្រទេស | នាក់ | 10 | 10 | 10 | 10 | 10 | 10 |
| 9 | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមសហគមន៍តាមរយៈកម្មវិធីOutreach របស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា | នាក់ | 9,000 | 9,000 | 9,000 | 9,000 | 9,000 | 9,000 |

**សកម្មភាពអនុវត្ត:**

- ធ្វើកិច្ចសហប្រតិបត្តិការ រវាងមូលនិធិជនពិការ ជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ដើម្បីកៀរគរប្រភពធនធាន សំដៅធានានិរន្តរភាព និងគុណភាពនៃការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការ
- បង្កើត និងបង្កើនកម្មវិធីវិនិយោគរបស់មូលនិធិជនពិការ និងបង្កើនថវិកាដែលប្រមូលបានពីហិបសប្បុរសធម៌មូលនិធិជនពិការ
- ផ្តល់ការគាំទ្រដល់ទ្រមូលនិធិនូវកម្មវិធីនានារបស់ស្ថាប័ន គ្រឹះស្ថាន និងអង្គការនានា ដែលជួយដល់ជនពិការ
- រៀបចំផែនការនិរន្តរភាពហិរញ្ញវត្ថុសម្រាប់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី ខេត្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាសំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំស្តីពីការងារស្តារលទ្ធភាពពលកម្មកាយសម្បទានៅកម្ពុជា
- បង្កើន និងអភិវឌ្ឍសមត្ថភាពមន្ត្រីបច្ចេកទេសរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី ខេត្ត តាមរយៈការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- បន្តដំណើរការរោងចក្រផលិតឧបករណ៍សិប្បនិម្មិត និងរណបដើម្បីធានាបាននូវបរិមាណ និងគុណភាពនៃការផលិតគ្រឿងផ្សំឧបករណ៍ទ្រទ្រង់រាងកាយបែងចែកជូនគ្រប់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងជួសជុល
- បន្តដំណើរការ និងនិរន្តរភាពមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងជួសជុលរាជធានី ខេត្តដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ការព្យាបាលដោយចលនា និងការស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រជូនជនពិការ
- បន្តកម្មវិធីចុះតាមសហគមន៍(Out-reach)របស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា។

**គោលដៅ 1.3.3. បន្តអនុវត្តកម្មវិធីសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ជូនជនពិការ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 10* | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | គ្មាន | 20,000 | 40,000 | 60,000 | 80,000 | 100,000 |
| 11* | ក្រុមជួយខ្លួនឯងនៃជនពិការដែលត្រូវបានបង្កើតនៅតាមសហគមន៍ | ក្រុម | 1,950 | 1,970 | 1,990 | 2,010 | 2,030 | 2,050 |
| 12* | ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍ | លើក | 10 | 11 | 12 | 13 | 14 | 15 |
| 13* | សិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាល និងចូលរួមសិក្ខាសាលា ការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | 765 | 910 | 1,055 | 1,200 | 1,345 | 1,490 |

**សកម្មភាពអនុវត្ត:**

- បន្តផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ជូនជនពិការទៅតាមតម្រូវការជាក់ស្តែង
- បន្តនិរន្តរភាព និងកសាងបន្ថែមក្រុមជួយខ្លួនឯងនៃជនពិការ
- រៀបចំកម្មវិធីទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍ដល់មន្ត្រីក្រសួង ស.អ.យ. មន្ទីរ ស.អ.យ. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រតិបត្តិករពាក់ព័ន្ធ ដើម្បីចែករំលែកបទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក
- រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍ដល់មន្ត្រីក្រសួង ស.អ.យ. មន្ទីរ ស.អ.យ. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រតិបត្តិករពាក់ព័ន្ធ ដើម្បីបង្កើនសមត្ថភាព និងធានាបាននូវគុណភាពនៃការផ្តល់សេវាជូនជនពិការ
- ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ដែលអនុវត្តដោយប្រតិបត្តិករដៃគូសំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំស្តីពីការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍នៅកម្ពុជា។

### គោលដៅ 1.3.4. ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសម្គាល់ប្រភេទ និងកម្រិតពិការភាពជូនជនពិការ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 14 | ជនពិការទទួលបានអត្តសញ្ញាណប័ណ្ណពិការភាព | នាក់ | គ្មាន | 50,000 | 50,000 | 50,000 | 50,000 | 50,000 |

**សកម្មភាពអនុវត្ត:**

- បង្កើត និងដាក់ឲ្យដំណើរការក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតពិការភាពថ្នាក់ជាតិ និងថ្នាក់រាជធានី/ខេត្ត
- រៀបចំនីតិវិធី និងទម្រង់នៃការកំណត់អត្តសញ្ញាណពិការភាព
- បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់ក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតពិការភាពថ្នាក់រាជធានី/ខេត្ត
- ធ្វើការកំណត់អត្តសញ្ញាណ និងផ្តល់អត្តសញ្ញាណប័ណ្ណពិការភាពជូនជនពិការ។

**គោលដៅ 1.3.5. ជំរុញអនុវត្តការផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 15 | ជនពិការក្រីក្រដែលត្រូវបានធ្វើអត្តសញ្ញាណកម្ម និងទទួលបានប័ណ្ណសង្គមកិច្ច | % | 0.10 | 90 | 100 | 100 | 100 | 100 |
| 16 | ជនពិការក្រីក្រដែលមានប័ណ្ណសង្គមកិច្ចទទួលបានរបបគោលនយោបាយឧបត្ថម្ភជីវភាពរស់នៅ | % | គ្មាន | 20 | 100 | 100 | 100 | 100 |
| 17 | ជនពិការក្រីក្រដែលមានប័ណ្ណសង្គមកិច្ចទទួលបានសេវាស្តារលទ្ធភាពពលកម្ម និងសេវាពិនិត្យថែទាំសុខភាព | % | គ្មាន | 10 | 80 | 80 | 88 | 88 |
| 18 | មន្ត្រីថ្នាក់រាជធានី/ខេត្ត អនុគណៈកម្មការក្រុង ស្រុក ខណ្ឌ និងក្រុមការងារឃុំ/សង្កាត់ត្រូវបានបណ្តុះបណ្តាលជំនាញបច្ចេកទេសគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ | វគ្គ | គ្មាន | 7 | 18 | 0 | 0 | 0 |

**សកម្មភាពអនុវត្ត:**

- បង្កើត និងដាក់ឲ្យដំណើរការគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ថ្នាក់រាជធានី/ខេត្ត
- រៀបចំនីតិវិធី និងទម្រង់នៃការកំណត់អត្តសញ្ញាណជនពិការក្រីក្រនៅតាមសហគមន៍ ដើម្បីទទួលបានរបបគោលនយោបាយ
- បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ថ្នាក់រាជធានី/ខេត្តអនុគណៈកម្មការក្រុង ស្រុក ខណ្ឌ និងក្រុមការងារឃុំ/សង្កាត់
- ធ្វើការកំណត់អត្តសញ្ញាណ និងផ្តល់ប័ណ្ណសង្គមកិច្ចជូនជនពិការក្រីក្រ ដែលត្រូវទទួលបានរបបគោលនយោបាយស្របតាមអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- ធ្វើការប្រមូល និងវិភាគទិន្នន័យជនពិការក្រីក្រនៅតាមសហគមន៍ ដែលទទួលបានប័ណ្ណសង្គមកិច្ច ដើម្បីរៀបចំផែនការក្នុងការបើកប្រាក់ឧបត្ថម្ភរបបគោលនយោបាយ
- លើកគម្រោងផែនការថវិកា សម្រាប់ការបើកប្រាក់ឧបត្ថម្ភរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- រៀបចំប្រព័ន្ធសម្រាប់ការបើកប្រាក់ឧបត្ថម្ភរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាព
- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- ធ្វើបច្ចុប្បន្នភាពលើការកំណត់អត្តសញ្ញាណជនពិការក្រីក្រនៅតាមសហគមន៍។

**គោលដៅ 1.3.6. បង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំរុញឱកាសការងារសម្រាប់ជនពិការ។ ជំរុញការបង្កលក្ខណៈងាយស្រួលប្រើប្រាស់ទីកន្លែងសាធារណៈ និងយានយន្តសម្រាប់ជនពិការ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 19* | ជនពិការដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | 292 | 442 | 592 | 742 | 892 | 1,042 |
| 20* | ជនពិការដែលទទួលបានការអប់រំសិក្សាពីកម្រិតបឋមសិក្សាដល់ឧត្តមសិក្សា | នាក់ | គ្មាន | 200 | 400 | 600 | 800 | 1000 |
| 21 | អត្រាជនពិការត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ | % | 2 | 2 | 2 | 2 | 2 | 2 |
| 22 | អត្រាជនពិការត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន | % | គ្មាន | 1 | 1 | 1 | 1 | 1 |
| 23 | ក្រសួង ស្ថាប័នរដ្ឋ និងឯកជនត្រូវបានកែសម្រួល និងរៀបចំឲ្យមានលក្ខណៈងាយស្រួលចេញ ចូល និងប្រើប្រាស់សម្រាប់ជនពិការ | % | គ្មាន | 30 | 80 | 100 | 100 | 100 |
| 24* | ជនពិការដែលទទួលបានការវាយតម្លៃសមត្ថភាពបើកបរយានយន្ត និងទទួលបានប័ណ្ណបើកបរពិសេស | នាក់ | គ្មាន | 100 | 400 | 900 | 1,400 | 1,900 |
| 25* | យានយន្តសម្រាប់ជនពិការ ត្រូវបានកែសម្រួល និងរៀបចំលក្ខណៈបច្ចេកទេសតាមប្រភេទពិការភាព | គ្រឿង | គ្មាន | 50 | 150 | 250 | 350 | 450 |

**សកម្មភាពអនុវត្ត:**

- បន្តនិរន្តរភាពមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ
- ជំរុញការដាក់បញ្ចូលការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទៅក្នុងសាលាបណ្តុះបណ្តាលបច្ចេកទេសនានារបស់រដ្ឋ និងឯកជន
- កៀរគររកប្រភពធនធានដើម្បីគាំទ្រកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការដែលមានស្រាប់ និងផ្អាកដំណើរការ
- សម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានសិក្សាឯកជនដើម្បីប្រមូលទិន្នន័យសិស្ស និស្សិតពិការចាប់ពីបឋមសិក្សាដល់ឧត្តមសិក្សា
- ជំរុញក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលឲ្យអនុវត្តនូវកាតព្វកិច្ចទទួលយកជនពិការចូលបម្រើការងារតាមអត្រាកំណត់ (ស្ថាប័នរដ្ឋ២% និងឯកជន១%)
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំបទដ្ឋានស្តង់ដាសម្រាប់ការរៀបចំលក្ខណៈងាយស្រួលប្រើប្រាស់ទីកន្លែងសាធារណៈ (អគារ ចំណតយានយន្ត មធ្យោបាយដឹកជញ្ជូន ។ល។) សម្រាប់ជនពិការ
- ជំរុញក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលក្នុងការកែសម្រួល និងរៀបចំបង្កលក្ខណៈងាយស្រួលប្រើប្រាស់ទីកន្លែងសាធារណៈសម្រាប់ជនពិការ

- ធ្វើអធិការកិច្ចលើការអនុវត្តកាតព្វកិច្ចរបស់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលក្នុងការជ្រើសរើសជនពិការចូលបម្រើការងារ (ទទួលភាគទាន ដាកពិន័យ និងរៀបចំសំណុំរឿងប្តឹងទៅតុលាការចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលពុំបានអនុវត្តកាតព្វកិច្ច)
- ធ្វើអធិការកិច្ចលើការអនុវត្តរបស់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ក្នុងការកែសម្រួល និងរៀបចំបង្កលក្ខណៈងាយស្រួលប្រើប្រាស់ទីកន្លែងសាធារណៈ សម្រាប់ជនពិការ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំលិខិតបទដ្ឋានក្នុងការកំណត់ប្រភេទយានយន្ត និងសមត្ថភាពបើកបរយានយន្តរបស់ជនពិការ
- ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់សមត្ថភាពបើកបរយានយន្តផ្តល់ប័ណ្ណបើកបរពិសេស និងរៀបចំកែសម្រួលប្រភេទយានយន្តសម្រាប់ជនពិការ។

**គោលដៅ 1.3.7. បន្តកម្មវិធីផ្តល់សេវាជូនសិស្ស និស្សិតពិការភ្នែក គថ្លង់ និងពិការសតិបញ្ញាតាមរយៈការផ្តល់នូវការអប់រំ និងសេវាពិសេស**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 26* | សិស្ស និស្សិតពិការទទួលបានការអប់រំពិសេស | នាក់ | គ្មាន | 500 | 1,000 | 1,500 | 2,000 | 2,500 |
| 27* | សិស្ស និស្សិតពិការទទួលបានសេវាពិសេស | នាក់ | គ្មាន | 100 | 300 | 500 | 700 | 900 |
| 28* | សិស្ស និស្សិតពិការត្រូវបានដាក់បញ្ចូល និងធ្វើសមាហរណកម្មទៅក្នុងថ្នាក់រៀនចំរុះ | នាក់ | គ្មាន | 70 | 140 | 210 | 280 | 350 |
| 29 | បទដ្ឋានអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនពិការត្រូវបានរៀបចំ | ច្បាប់ | គ្មាន | 2 | 0 | 0 | 0 | 0 |
| 30* | ស្ថានីយ៍ទូរទស្សន៍រដ្ឋ និងឯកជនដែលមានកម្មវិធីផ្សាយជាភាសាសញ្ញា | ស្ថានីយ៍ | 4 | 5 | 6 | 7 | 8 | 10 |

**សកម្មភាពអនុវត្ត:**

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូដើម្បីអនុវត្តកម្មវិធីអប់រំ និងផ្តល់សេវាពិសេសជូនសិស្ស និស្សិតពិការ
- ជំរុញ និងលើកទឹកចិត្តឲ្យមានការដាក់បញ្ចូលកុមារពិការទៅក្នុងប្រព័ន្ធអប់រំ និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងថ្នាក់រៀនចំរុះ
- ជំរុញការផ្សព្វផ្សាយ និងលើកទឹកចិត្តមាតាបិតា អាណាព្យាបាលដើម្បីបញ្ជូនកុមារពិការឲ្យទទួលបានសេវាអប់រំគ្រប់កម្រិតសិក្សា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យសិស្ស និស្សិតពិការដែលទទួលបានការអប់រំពិសេស សេវាពិសេស និងធ្វើសមាហរណកម្មទៅក្នុងថ្នាក់រៀនចំរុះ
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូដើម្បីអភិវឌ្ឍបទដ្ឋានជាតិស្តីពីអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនពិការ
- ជំរុញ និងលើកទឹកចិត្តឲ្យមានការដាក់បញ្ចូលកម្មវិធីប្រើប្រាស់ភាសាសញ្ញាតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន។

**គោលដៅ 1.3.8. បន្តជំរុញ និងលើកទឹកចិត្តចលនាកីឡា និងសិល្បៈ របស់ជនពិការ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 31* | កីឡាករ កីឡាការិនីជាជនពិការទទួលបានការបណ្តុះបណ្តាល និងចូលរួមការប្រកួតក្នុងកម្រិតជាតិ និងអន្តរជាតិ | នាក់ | 4,890 | 5,450 | 6,510 | 7,070 | 7,630 | 8,190 |
| 32* | សិល្បករ សិល្បការិនីជាជនពិការទទួលបានការហ្វឹកហាត់ និងមានសមត្ថភាពចូលរួមសំដែង | នាក់ | 100 | 220 | 370 | 520 | 670 | 820 |

**សកម្មភាពអនុវត្ត:**

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធគណៈកម្មាធិការប៉ារ៉ាឡាំពិកកម្ពុជា គណៈកម្មាធិការស្បៀស្យាល់អូឡាំពិកកម្ពុជា និងអង្គការដៃគូដើម្បីអនុវត្តកម្មវិធីកីឡាជនពិការ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូដើម្បីអនុវត្តកម្មវិធីសិល្បៈជនពិការ
- បំផុស និងលើកទឹកចិត្តជនពិការដើម្បីចូលរួមសកម្មភាពកីឡា និងសិល្បៈ
- ប្រមូលទិន្នន័យជនពិការដែលបានចូលរួមក្នុងសកម្មភាពកីឡា និងសិល្បៈ
- កៀរគរប្រភពធនធាន (បច្ចេកទេស សម្ភារៈ ថវិកា) ទាំងក្នុង និងក្រៅប្រទេសដើម្បីគាំទ្រដល់កម្មវិធីកីឡា និងសិល្បៈជនពិការ។

**គោលដៅ 1.3.9. លើកកម្ពស់ និងធ្វើសមាហរណកម្មស្ត្រី និងកុមារីពិការទៅក្នុងគម្រោងអភិវឌ្ឍន៍នានា**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 33* | ស្ត្រីពិការដែលទទួលបានការបណ្តុះបណ្តាលជំនាញពីគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈរដ្ឋ និងឯកជន | នាក់ | 99 | 149 | 199 | 249 | 299 | 349 |
| 34 | កុមារីពិការដែលទទួលបានការអប់រំសិក្សា | នាក់ | | | | | | |
| 35* | ស្ត្រីពិការដែលទទួលបានការងារធ្វើ និងមុខរបរ | នាក់ | 85 | 135 | 185 | 235 | 285 | 335 |

**សកម្មភាពអនុវត្ត:**

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងផ្នែកឯកជនដើម្បីបង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈស្ត្រីពិការ

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងផ្នែកឯកជនដើម្បីផ្តល់ការអប់រំដល់កុមារីពិការ
- បំផុស និងលើកទឹកចិត្តដល់ស្ត្រី កុមារីពិការ និងគ្រួសារដើម្បីទទួលបាននូវការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ស្រាវជ្រាវ ប្រមូល និងវិភាគទិន្នន័យស្ត្រី និងកុមារីពិការ
- ជំរុញឲ្យមានប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មនានាឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងកុមារីពិការ
- ទប់ស្កាត់ និងកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារីពិការ (ការរើសអើង អំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងការកេងប្រវ័ញ្ចផលប្រយោជន៍ស្ត្រី និងកុមារីពិការ)
- បំផុស និងលើកទឹកចិត្តដល់ស្ត្រី និងកុមារីពិការដើម្បីចូលរួមគ្រប់សកម្មភាពនានាក្នុងសង្គម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីលើកកម្ពស់ឲ្យមានសមភាពយេនឌ័ររវាងបុរស និងស្ត្រីពិការ។

## គោលដៅ 1.3.10.ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពសម្រាប់ឆ្នាំ២០១៤ ដល់ ២០១៨

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 36 | របាយការណ៍ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពពីគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន ក.ស.ជ. ក្រុមការងារ ក.ស.ជ.តាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្ត[7] | របាយការណ៍ | គ្មាន | 4 | 4 | 4 | 4 | 4 |
| 37 | សិក្ខាកាមពីអគ្គលេខាធិការដ្ឋាន ក.ស.ជ. ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និង ក.ស.ជ. ថ្នាក់រាជធានី ខេត្តបានយល់ដឹងពីផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព[8] | នាក់ | គ្មាន | 120 | 120 | 120 | 120 | 120 |
| 38 | អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ទាំង២៥ រាជធានី ខេត្ត | លើក | គ្មាន | 24 | 24 | 24 | 24 | 24 |
| 39 | របាយការណ៍វឌ្ឍនភាពពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់នៃការអនុវត្តផែនការជាតិត្រូវបានកសាង និងដាក់ជូនរាជរដ្ឋាភិបាល[9] | របាយការណ៍ | គ្មាន | គ្មាន | គ្មាន | 1 | | 1 |

[7] ក្រុមការងារថ្នាក់ក្រសួង និងអគ្គលេខាធិការដ្ឋានថ្នាក់រាជធានីខេត្តត្រូវបានបង្កើតតាមអនុក្រឹត្យលេខ២១៦ និងមានរបាយការណ៍ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ

[8] សិក្ខាសាលាផ្សព្វផ្សាយ តាមដាន និងវាយតម្លៃការអនុវត្ត NDSP

[9] NDSP has its mandate 2014-2018, therefore midterm review is 2 years and half

**សកម្មភាពអនុវត្ត:**

- កសាងសមត្ថភាពជំនាញបច្ចេកទេសក្នុងចំណោមមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ស.ជ. ថ្នាក់រាជធានី ខេត្ត និងក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន សម្រាប់តាមដាន វាយតម្លៃ និងរៀបចំរបាយការណ៍ស្តីពី ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ឆ្នាំ២០១៤-២០១៨ (NDSP) ដាក់ឆ្លង ក.ស.ជ. ដើម្បីជូនរាជរដ្ឋាភិបាល
- ទំនាក់ទំនងក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្ត (ក្រោយពេល ក.ស.ជ. ថ្នាក់រាជធានី ខេត្ត បង្កើតក្រុមការងាររួច) ដើម្បីជាប្រភពទិន្នន័យសម្រាប់ធ្វើរបាយការណ៍
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ចុះតាមដានការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព
- ធ្វើការវិភាគភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបានក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាពដើម្បីដាក់ក្នុងរបាយការណ៍ជូនរាជរដ្ឋាភិបាល
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រសួង ស្ថាប័ន វិស័យឯកជន និងសង្គមស៊ីវិលលើការពិនិត្យឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាពរយៈពេលពាក់កណ្តាលអាណត្តិនៃផែនការដើម្បីសរសេររបាយការណ៍វឌ្ឍនភាព
- រៀបចំធ្វើរបាយការណ៍ចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨។

### គោលដៅ 1.3.11.ជំរុញការអនុវត្ត និងរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 40 | របាយការណ៍ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្រ្តអ៊ីនឈាន់ត្រូវបានផលិត និងផ្ញើជូនរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ[10] | របាយការណ៍ | គ្មាន | 1 | | 1 | | 1 |
| 41 | គ្រូឧទ្ទេសថ្នាក់ជាតិ និងក្រោមជាតិចំនួន ១២៥នាក់ ត្រូវបានបណ្តុះបណ្តាល ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្រ្តអ៊ីនឈាន់[11] | នាក់ | គ្មាន | 25 | 25 | 25 | 25 | 25 |
| 42 | ឧបករណ៍ផ្សព្វផ្សាយការយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្រ្តអ៊ីនឈាន់ត្រូវបានកសាងផ្សព្វផ្សាយតាមទូរទស្សន៍ ដេព្លីយ៉ង់ និងកូនសៀវភៅផ្នត់ (TV, Poster, leaflets) | លើក | គ្មាន | 4 | 4 | 4 | 4 | 4 |

[10] អនុសញ្ញាចែងថារដ្ឋភាគីត្រូវរាយការណ៍រាល់២ឆ្នាំក្រោយពីអនុសញ្ញាស្តីពីសិទ្ធិជនពិការបានអនុម័ត

[11] គ្រូបង្គោល អគ្គលេខាធិការដ្ឋាន ៤០នាក់ ក.ស.ជ. ថ្នាក់រាជធានី ខេត្ត ៥០ នាក់ ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន ៣០នាក់

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 43 | អ្នកប្រមូលទិន្នន័យពិការភាពថ្នាក់ជាតិ និងក្រោមជាតិចំនួន ១២៥នាក់ ត្រូវបានបណ្តុះបណ្តាល និងមានសមត្ថភាពក្នុងការប្រមូលទិន្នន័យប្រកបដោយគុណភាព | នាក់ | គ្មាន | 25 | 25 | 25 | 25 | 25 |
| 44 | សិទ្ធិជនពិការ និងរបាយការណ៍ពិការភាពត្រូវបានបញ្ជ្រាបក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) និងមានរបាយណ៍ពិការភាពក្នុងរបាយការណ៍ជាតិ | របាយការណ៍ | គ្មាន | 1 | 1 | 1 | 1 | 1 |
| 45 | ទិន្នន័យផ្នែកពិការភាពត្រូវបានចងក្រង និងធ្វើបច្ចុប្បន្នភាព | ទិន្នន័យ | គ្មាន | 1 | 1 | 1 | 1 | 1 |
| 46 | សិក្ខាសាលាផ្សព្វផ្សាយ អនុសាសន៍ និងព័ត៌មានត្រឡប់របស់អង្គការសហប្រជាជាតិទៅលើរបាយការណ៍ការអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិជនពិការដល់មន្ត្រីតាមក្រសួង ស្ថាប័នជាតិ និងក្រោមជាតិ | របាយការណ៍ | គ្មាន | 1 | | 1 | | 1 |

**សកម្មភាពអនុវត្ត:**

- កសាងសមត្ថភាពជំនាញបច្ចេកទេសក្នុងចំណោមមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ស.ជ. សម្រាប់រៀបចំរបាយការណ៍ដែលបំពេញទៅតាមតម្រូវការរបស់គណៈកម្មាធិការសិទ្ធិជនពិការនៃអង្គការសហប្រជាជាតិ
- បង្កើតបណ្តាញទំនាក់ទំនងជាមួយប្រភពទិន្នន័យរាជរដ្ឋាភិបាលដូចជាវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
- ធ្វើការវិភាគភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបានសម្រាប់ធ្វើការពិនិត្យតាមដានសិទ្ធិជនពិការ និងធ្វើការស្នើសុំរបាយការណ៍ទៅតាមតម្រូវការចាំបាច់
- កសាងសមត្ថភាពឲ្យស្របទៅតាមតម្រូវការនៃការរៀបចំរបាយការណ៍ឲ្យដល់ សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ និងអគ្គលេខាធិការដ្ឋាន ក.ស.ជ.
- បង្កើតគោលការណ៍ណែនាំអំពីការរៀបចំរបាយការណ៍ជាភាសាខ្មែរ និងបញ្ចូលគោលការណ៍ណែនាំទាំងនោះទៅក្នុងដំណើរការរៀបចំសរសេររបាយការណ៍
- រៀបចំកិច្ចប្រជុំត្រៀមឆ្លើយទៅនឹងសំណួរ របស់គណៈកម្មាធិការសិទ្ធិជនពិការ និងត្រៀមការពាររបាយការណ៍ជាតិមុននឹងទៅការពារនៅអង្គការសហប្រជាជាតិ
- រៀបចំគណៈប្រតិភូទៅការពាររបាយការណ៍ជាតិនៅអង្គការសហប្រជាជាតិ
- ផ្តល់ការកសាងសមត្ថភាពស្តីពីគោលការណ៍គ្រឹះនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់ និងការវិភាគអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់លើបញ្ហាជាក់លាក់របស់ថ្នាក់រាជធានី ខេត្ត និងថ្នាក់ ក្រុង ស្រុក និងខណ្ឌនីមួយៗ
- បើកវគ្គបណ្តុះបណ្តាលជំនាញសម្របសម្រួលដល់គ្រូឧទ្ទេសថ្នាក់ជាតិ (ក្រសួង-ស្ថាប័ន) និងបើកវគ្គបណ្តុះបណ្តាលជំនាញសម្របសម្រួលគ្រូបង្គោលថ្នាក់ក្រោមជាតិ
- បើកវគ្គបណ្តុះបណ្តាលជំនាញប្រមូលទិន្នន័យ និងសរសេររបាយការណ៍សម្រាប់គ្រូឧទ្ទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ផលិតសម្ភារៈផ្សព្វផ្សាយ ដូចជាខិត្តប័ណ្ណ ផ្ទាំងរូបភាព វីដេអូអប់រំ។ល។
- បង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យ ក.ស.ជ. ស្តីពីសិទ្ធិជនពិការ និងធ្វើការបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ស.ជ. និងសមាជិកអំពីប្រតិបត្តិការ ឬនីតិវិធី

- កសាងសមត្ថភាពដល់មន្ត្រីសំខាន់ៗក្នុងការប្រមូល និងវិភាគទិន្នន័យទាំងផ្នែកគុណភាព និងបរិមាណដើម្បីឲ្យមានជារបាយការណ៍ដែលមានលក្ខណៈសកម្មទុកជាមុន និងប្រកបដោយការពិចារណាល្អិតល្អន់
- ធ្វើការជាមួយក្រសួងផែនការដើម្បីបញ្ជ្រាបការរៀបចំរបាយការណ៍ និងការអនុវត្តសិទ្ធិជនពិការចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងផែនការតាមវិស័យ និងការបញ្ជ្រាបទៅក្នុងផែនការថ្នាក់ក្រោមជាតិ។
- ប្រើប្រាស់យន្តការដែលមានស្រាប់ និងបង្កើតយន្តការថ្មីទាំងថ្នាក់ជាតិ និងក្រោមជាតិដែលមានប្រសិទ្ធភាពក្នុងការប្រមូលទិន្នន័យដើម្បីសរសេររបាយការណ៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលព័ត៌មាន និងការពិគ្រោះយោបល់ដើម្បីធានាថាជនពិការមានការចូលរួមនៅគ្រប់កម្រិត
- កំណត់សូចនាករ ឬទម្រង់របាយការណ៍ និងនីតិវិធីក្នុងការរាយការណ៍ជាមួយស្ថាប័នដែលរៀបចំរបាយការណ៍
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ជាតិលើកទី១ និងលើកទី២ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅកម្ពុជា និងយោបល់សន្និដ្ឋានរបស់អង្គការសហប្រជាជាតិនៅក្នុងចំណោមក្រសួង ស្ថាប័នជាសមាជិក ក.ស.ជ. ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្ត។

**គោលដៅ 1.3.12. លើកកម្ពស់ការយល់ដឹង ស្វែងរកការគាំទ្រដើម្បីបញ្ជ្រាបសិទ្ធិជនពិការ និងជំរុញការអនុវត្តអនុសាសន៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីពិការភាព**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 47 | ជនពិការកម្ពុជាទទួលបានសេវាសុខភាព កាន់តែប្រសើរឡើងតាមរយៈការពង្រឹងការផ្តល់សេវាផ្នែកសុខភាព[12] | % | គ្មាន | 15 | 15 | 15 | 15 | 15 |
| 48 | កុមារពិការទូទាំងប្រទេសទទួលបានសិទ្ធិមូលដ្ឋានទាំងបួនរបស់កុមារ[13] | % | គ្មាន | 100 | 100 | 100 | 100 | 100 |
| 49 | ស្ត្រីពិការទូទាំងប្រទេសទទួលបានសេវាគ្រប់ជ្រុងជ្រោយដូចមានចែងក្នុងអនុសញ្ញា CEDAW និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ | % | គ្មាន | 100 | 100 | 100 | 100 | 100 |
| 50 | សិក្ខាសាលាផ្សព្វផ្សាយការយល់ដឹងពីស្ថានភាពអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបររបស់ជនពិការដល់ក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ | លើក | គ្មាន | 1 | 1 | 1 | 1 | 1 |

[12] កិច្ចការនេះត្រូវមានការសហការ ជាមួយក្រសួងសុខាភិបាល

[13] សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការចូលរួម និងសិទ្ធិទទួលបានការការពារ

**សកម្មភាពអនុវត្ត:**

- បន្តអនុវត្តកម្មវិធីផ្សព្វផ្សាយ និងជួយជំរុញឱ្យជនពិការទទួលបានសេវាការពារ ការថែទាំ និងការព្យាបាលសុខភាព
- សហការជាមួយក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងស្ថាប័ន អង្គការពាក់ព័ន្ធជំរុញ និងតស៊ូមតិដើម្បីឱ្យស្ត្រីពិការទទួលបានសិទ្ធិពេញលេញ ដូចមានចែងនៅក្នុងគោលនយោបាយជាតិ និងអនុសញ្ញា CEDAW
- ផ្សព្វផ្សាយរបាយការណ៍ពីការរកឃើញស្តីពីការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរដល់នាយកដ្ឋានជំនាញរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច វិស័យអប់រំ វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យការងារ វិស័យផែនការ និងអ្នកពាក់ព័ន្ធ។

### គោលដៅ 1.3.13. ពង្រឹងទំនាក់ទំនងរវាង ក.ស.ជ. ជាមួយក្រសួងស្ថាប័នដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិល

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 51 | គណៈកម្មការអនុគណៈកម្មការ និងក្រុមការងាររបស់ ក.ស.ជ. ត្រូវបានបង្កើត និងដំណើរការទៅតាមជំនាញរបស់គណៈកម្មការនីមួយៗ[14] | លើក | គ្មាន | 48 | 48 | 48 | 48 | 48 |
| 52 | របាយការណ៍នៃការចូលរួមទិវានានា និងក្លាយជាសមាជិកនៃស្ថាប័នជាតិ និងអន្តរជាតិ[15] | របាយការណ៍ | គ្មាន | 12 | 12 | 12 | 12 | 12 |
| 53 | របាយការណ៍ ឬកំណត់ហេតុពីស្ថាប័នរៀបចំ និងចម្លងជូនដល់ដៃគូពាក់ព័ន្ធ | % | គ្មាន | 100 | 100 | 100 | 100 | 100 |

**សកម្មភាពអនុវត្ត:**

- បង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងាររបស់ ក.ស.ជ. ឡើងវិញ
- រៀបចំកិច្ចប្រជុំគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងាររបស់ ក.ស.ជ. អង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការពាក់ព័ន្ធក្នុងវិស័យពិការភាពទាំងក្នុង និងក្រៅប្រទេស
- សម្របសម្រួលកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ផ្តល់បទឧទ្ទេស សម្របសម្រួលទស្សនកិច្ចសិក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការពាក់ព័ន្ធក្នុងវិស័យពិការភាពទាំងនៅក្នុង និងក្រៅប្រទេស

[14] មានគណៈកម្មការ៥ គឺ គណៈកម្មការអប់រំ គណៈកម្មការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ គណៈកម្មការស្តារលទ្ធភាពពលកម្ម និងគណៈកម្មការច្បាប់

[15] ការចូលរួមប្រជុំក្នុង និងក្រៅប្រទេសយ៉ាងតិច២៥

- ចូលជាសមាជិកភាពជាមួយអង្គការ ស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធក្នុងវិស័យពិការភាព
- ចូលរួមព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងវិស័យពិការភាពទាំងក្នុងថ្នាក់ជាតិ និងអន្តរជាតិដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារ
- ចែករំលែកបទពិសោធន៍ចំណេះដឹងដែលទទួលបានពីការចូលរួមក្នុងព្រឹត្តការណ៍ជាតិ និងអន្តរជាតិដល់ដៃគូពាក់ព័ន្ធ។

**គោលដៅ 1.3.14. ពង្រីករចនាសម្ព័ន្ធ ក.ស.ជ និងពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន ក.ស.ជ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 54 | របាយការណ៍ស្តីពីកិច្ចប្រជុំ និងអនុសាសន៍ដើម្បីដាក់ជូនរាជរដ្ឋាភិបាល | របាយការណ៍ | គ្មាន | 25 | 25 | 25 | 25 | 25 |
| 55 | សមាជិកគ្រប់ៗរូបមានវត្តមានរៀងរាល់កិច្ចប្រជុំ ក.ស.ជ. | លើក | គ្មាន | 2 | 2 | 2 | 2 | 2 |
| 56 | ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ននិង ក.ស.ជ. ថ្នាក់រាជធានី ខេត្ត និងរាយការណ៍ស្តីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តជាតិ និងលិខិតូបករណ៍អន្តរជាតិប្រកបដោយប្រសិទ្ធភាព | របាយការណ៍ | គ្មាន | 50 | 50 | 50 | 50 | 50 |
| 57 | ដំណើរការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ស.ជ. មានភាពរលូន និងប្រកបដោយប្រសិទ្ធភាព | ស្ថាប័ន | គ្មាន | 1 | 1 | 1 | 1 | 1 |

**សកម្មភាពអនុវត្ត:**

- រៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ ក.ស.ជ. ឲ្យបានទៀងទាត់ទៅតាមអនុក្រឹត្យ
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំអំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារ និងអនុសាសន៍ ដែល ក.ស.ជ. ដាក់ជូនរាជរដ្ឋាភិបាល
- បង្កើនការចូលរួមរបស់ថ្នាក់ដឹកនាំ និងសមាជិក ក.ស.ជ. ឱ្យកាន់តែសកម្ម
- បង្កើតក្រុមការងារ ក.ស.ជ. នៅតាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្តដើម្បីជាយន្តការក្នុងការប្រមូល និងបញ្ជូនព័ត៌មានអំពីពិការភាព និងតាមដានការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ យុទ្ធសាស្រ្តអ៊ីនឈាន់ ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព លិខិតបទដ្ឋានគតិយុត្តជាតិ និងលិខិតូបករណ៍អន្តរជាតិ
- លើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ស.ជ. តាមរយៈការផ្សព្វផ្សាយព្រះរាជក្រម អនុក្រឹត្យ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល
- បញ្ជូនមន្រ្តី និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ក.ស.ជ. ទទួលវគ្គបណ្តុះបណ្តាលតាមជំនាញនីមួយៗក្នុង និងក្រៅប្រទេស
- ពង្រឹង និងពង្រីករចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន ក.ស.ជ. សមត្ថភាពមន្រ្តី តួនាទី ការទទួលខុសត្រូវ និងថវិកាទ្រទ្រង់។

## កម្មវិធី 1.4. អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

### គោលដៅ 1.4.1. ជំរុញសកម្មភាពគណៈកម្មាធិការជាតិ និងយន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់ និងរៀបចំ ទិវាមនុស្សចាស់ ១ តុលា ជារៀងរាល់ឆ្នាំ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | ទិវាមនុស្សចាស់ ១តុលាត្រូវបានប្រារព្ធឡើងរៀងរាល់ឆ្នាំ | នាក់ | 10,000 | 10,000 | 10,000 | 10,000 | 10,000 | 10,000 |
| 2 | សមាជិកគណៈកម្មាធិការថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីពីការផ្តល់សេវាគាំទ្រ និងលើកស្ទួយសុខុមាលភាពមនុស្សចាស់ក្នុងមួយឆ្នាំ៦០នាក់ | នាក់ | គ្មាន | 60 | 60 | 60 | 60 | 60 |
| 3 | គោលនយោបាយជាតិសម្រាប់មនុស្សចាស់កម្ពុជាត្រូវបានសិក្សា រៀបចំចងក្រង កែសម្រួល និងស្នើសុំការអនុម័ត | ច្បាប់ | សិក្សា | សេចក្តីព្រាង | ឆ្លង | ឆ្លង អនុម័ត | ផ្សព្វផ្សាយ | អនុវត្ត |

**សកម្មភាពអនុវត្ត:**

- រៀបចំទិវាមនុស្សចាស់កម្ពុជា ១តុលា រៀងរាល់ឆ្នាំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានអ្នកចូលរួមប្រហែល ១៨.០០០នាក់ក្នុងមួយឆ្នាំ
- រៀបចំកែសម្រួលគោលនយោបាយជាតិសម្រាប់មនុស្សចាស់កម្ពុជា និងរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដើម្បីលើកស្ទួយសុខុមាលភាពមនុស្សចាស់
- សិក្សាឯកសារពាក់ព័ន្ធពីបណ្តាប្រទេសសមាជិកអាស៊ានដើម្បីរៀបចំកែសម្រួលគោលនយោបាយ និងធ្វើសិក្ខាសាលាកែលម្អរួចដាក់ជូនគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ប្រជុំពិនិត្យ និងអនុម័តសម្រេចជាគោលការណ៍ និងបោះពុម្ពជាសៀវភៅ
- ធ្វើការផ្សព្វផ្សាយ បណ្តុះបណ្តាលមន្ត្រីជំនាញ អាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្ត
- រៀបចំបោះពុម្ពសៀវភៅគោលការណ៍ណែនាំស្តីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់ និងរៀបចំឯកសារលិខិតបទដ្ឋានពាក់ព័ន្ធស្តីពីការពង្រឹងការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់ទូទាំងប្រទេស ។

**គោលដៅ 1.4.2. ជំរុញអនុវត្តនូវកម្មវិធីពីរជាសំខាន់គឺ ទី១.កម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងទី២.កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 4* | មនុស្សចាស់ដែលបានស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍សមាគមមនុស្សចាស់នៅតាមសហគមន៍ | នាក់ | 167,152 | 177.152 | 187.152 | 197.152 | 207.152 | 217.152 |
| 5 | មនុស្សចាស់ដែលបានស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីថែទាំមនុស្សចាស់នៅតាមគ្រួសារ | នាក់ | 968,882 | 48,162 | 52,252 | 56,587 | 61,182 | 66,053 |
| 6 | មនុស្សចាស់ដែលបានស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីថែទាំមនុស្សចាស់នៅតាមសហគមន៍ | នាក់ | 2,295 | 2,795 | 3,295 | 3,795 | 4,295 | 4,795 |

**សកម្មភាពអនុវត្ត:**

- ជំរុញអនុវត្តកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់នៅតាមសហគមន៍
- លើកទឹកចិត្តមនុស្សចាស់ឲ្យចូលរួមអភិវឌ្ឍន៍សហគមន៍តាមកម្មវិធីអភិបាលកិច្ចល្អ
- លើកទឹកចិត្តមនុស្សចាស់ចូលរួមកសាងធនធានមនុស្សក្នុងសហគមន៍
- ផ្សព្វផ្សាយគោលនយោបាយជាតិសម្រាប់មនុស្សចាស់ និងលិខិតបទដ្ឋានពាក់ព័ន្ធកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍
- បន្តផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់តាមសហគមន៍
- សិក្សាសេវាសាធារណៈសម្រាប់មនុស្សចាស់ដើម្បីផ្តល់ការលើកទឹកចិត្តផ្នែកពន្ធ ការប្រាក់ធនាគារ និងសម្បទានក្នុងពេលធ្វើដំណើរ
- សិក្សាស្រាវជ្រាវប្រភពទិន្នន័យដើម្បីស្វែងយល់ពីស្ថានភាពសង្គម សេដ្ឋកិច្ច សុខភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់មនុស្សចាស់ និងសិក្សាពីផលប៉ះពាល់នៃសន្តប្រវេសន៍យុវជនមកលើមនុស្សចាស់ ។

**គោលដៅ 1.4.3. បន្តពង្រឹង និងពង្រីកសកម្មភាពសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 7* | បន្តពង្រឹង ពង្រីកសកម្មភាពសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់ | សមាគម | 459 | 559 | 659 | 759 | 859 | 959 |
| 8* | សមាគមមនុស្សចាស់ដែលបានអនុវត្តកម្មវិធីថែទាំសុខភាព | សមាគម | 175 | 375 | 575 | 675 | 775 | 875 |
| 9* | សមាគមមនុស្សចាស់ដែលបានអនុវត្តកម្មវិធីធនាគារស្រូវ | សមាគម | 175 | 375 | 575 | 675 | 775 | 875 |
| 10* | សមាគមមនុស្សចាស់ដែលបានអនុវត្តកម្មវិធីធនាគារគោ | សមាគម | 175 | 375 | 575 | 675 | 775 | 875 |
| 11* | សមាគមមនុស្សចាស់ដែលបានអនុវត្តកម្មវិធីបេឡាមរណសង្គ្រោះ | សមាគម | 459 | 559 | 659 | 759 | 859 | 959 |
| 12* | សមាគមមនុស្សចាស់ដែលបានអនុវត្តកម្មវិធីឥណទានខ្នាតតូច | សមាគម | 175 | 375 | 575 | 675 | 775 | 875 |

**សកម្មភាពអនុវត្ត:**

- បន្តពង្រឹងពង្រីកសកម្មភាពបង្កើតសមាគមមនុស្សចាស់នៅតាមឃុំ/សង្កាត់ឲ្យបាន ១០០សមាគមក្នុងមួយឆ្នាំ
- បណ្តុះបណ្តាលសមាគមមនុស្សចាស់ឲ្យបានយល់ពីការអនុវត្តកម្មវិធីថែទាំសុខភាព អនាម័យ និងលំហាត់ប្រាណ
- បណ្តុះបណ្តាលសមាគមមនុស្សចាស់ឲ្យបានយល់ពីកម្មវិធីធនាគារស្រូវ ធនាគារគោដើម្បីរកប្រាក់ចំណូលដើម្បីអភិវឌ្ឍន៍សហគមន៍
- បន្តជំរុញសមាគមមនុស្សចាស់ឲ្យអនុវត្តកម្មវិធីបេឡាមរណៈសង្គ្រោះតាមគោលការណ៍នៃលក្ខន្តិកៈរបស់សមាគម និងស្វែងរកពីសប្បុរសជនបន្ថែម។

**គោលដៅ 1.4.4. បន្តជំរុញកម្មវិធីថែទាំមនុស្សចាស់នៅតាមគ្រួសារ លើកទឹកចិត្តដល់សហគមន៍ អារាមសាសនា និងបណ្តុះបណ្តាលបុគ្គលិកភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 13 | គ្រូបង្គោលដែលទទួលបានការបណ្តុះបណ្តាលថែទាំមនុស្សចាស់ | នាក់ | 10 | 24 | 24 | 24 | 24 | 24 |
| 14 | អ្នកស្ម័គ្រចិត្តដែលទទួលបានការបណ្តុះបណ្តាលថែទាំមនុស្សចាស់ | នាក់ | គ្មាន | 100 | 200 | 300 | 400 | 500 |
| 15* | គ្រូបង្គោលដែលទទួលបានការបណ្តុះបណ្តាល | នាក់ | គ្មាន | 24 | 48 | 72 | 96 | 120 |
| 16 | វត្តអារាមដែលទទួលបានការបណ្តុះបណ្តាល | វត្ត | គ្មាន | 5 | 10 | 15 | 20 | 25 |
| 17 | មន្ត្រីជំនាញពាក់ព័ន្ធផ្តល់សេវាជនចាស់ជរាដែលទទួលបានការបណ្តុះបណ្តាល | នាក់ | គ្មាន | 72 | 72 | 72 | 72 | 72 |

**សកម្មភាពអនុវត្ត:**

- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន ២វគ្គស្តីពីរបៀបរបបផ្តល់សេវាសម្រាប់គាំទ្រផ្នែកចិញ្ចឹមជីវិត សុខភាព ការថែទាំមនុស្សចាស់ លំនៅឋាន ការចូលរួមធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន និងកម្មវិធីផ្សេងៗទៀតក្នុងការអភិវឌ្ឍ
- ធ្វើការបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត ព្រមទាំងក្រុមគ្រួសារឲ្យបានយល់ដឹងពីកម្មវិធីថែទាំមនុស្សចាស់តាមលំនៅឋាន និងមនុស្សចាស់គ្មានទីពឹង។

## យុទ្ធសាស្ត្រទី2: ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម

### កម្មវិធី 2.1.អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល[16]

**គោលដៅ 2.1.1. លើកកម្ពស់សុខុមាលភាព និងបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1* | និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបប សោធននិវត្តន៍ | នាក់ | 37,371 | 45,000 | 50,000 | 55,000 | 60,000 | 65,000 |
| 2 | សិទ្ធិវន្តដែលត្រូវបានធ្វើបច្ចុប្បន្នភាព | រាជធានី ខេត្ត | 13 | 8 | បន្តមុខ សញ្ញាថ្មី | បន្តមុខ សញ្ញាថ្មី | បន្តមុខ សញ្ញាថ្មី | បន្តមុខ សញ្ញាថ្មី |
| 3 | ប្រកាសអន្តរក្រសួងស្តីពីការអនុវត្តអត្រាភាគទានសម្រាប់ជាមូលនិធិទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវបានបង្កើតឡើង | ច្បាប់ | អនុម័ត | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ |
| 4 | ប្រព័ន្ធទិន្នន័យមន្ត្រីរាជការស៊ីវិលត្រូវបានតភ្ជាប់ជាមួយ ក្រសួងមុខងារសាធារណៈ | ប្រព័ន្ធ | ឯកភាព ជាគោល ការណ៍ | ឯកភាព តភ្ជាប់ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ |
| 5 | ប្រព័ន្ធទិន្នន័យ ប.ជ.ស. ត្រូវបានតភ្ជាប់ជាមួយធនាគារ ដៃគូដើម្បីបម្រើសេវា និងគ្រប់គ្រងឲ្យមានប្រសិទ្ធភាព | ប្រព័ន្ធ | ពិភាក្សា | ឯកភាព តភ្ជាប់ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ | អនុវត្តន៍ |

[16] ចំពោះការយកចិត្តទុកដាក់លើកកម្ពស់សុខុមាលភាព និងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានរៀបចំគោលការណ៍ច្បាប់ដើម្បីអនុវត្តអត្រាភាគទានជាមូលនិធិសម្រាប់ទ្រទ្រង់ ប.ជ.ស. ដែលការងារនេះ និងចប់រួចរាល់នៅដើមឆ្នាំ២០១៤ ។ ចាប់ពីឆ្នាំ២០១៤ តទៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល នឹងប្រើប្រាស់មូលនិធិពង្រីកការផ្តល់នូវរបបគាលិកផ្សេងទៀតសម្រាប់សិទ្ធិវន្តជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ អ្នកនៅក្នុងបន្ទុក និងមន្ត្រីរាជការស៊ីវិលនៅទូទាំងប្រទេសដែលមានចំនួនប្រហែល ២៣០.០០០ មានដូចជាការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ អ្នកនៅក្នុងបន្ទុក មរណភាព មាតុភាព និងគ្រោះថ្នាក់ការងារ ។

**សកម្មភាពអនុវត្ត:**

- រៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធី គម្រោង និងសកម្មភាពដើម្បីលើកកម្ពស់សុខុមាលភាពអតីតមន្ត្រីរាជការស៊ីវិល
- ពង្រឹងការបើកផ្តល់ប្រាក់សោធននិវត្ត និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធធនាគារ
- ដោះស្រាយរបបសន្តិសុខសង្គមដល់អ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិល
- ពង្រឹងដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តរបបសន្តិសុខសង្គម
- រៀបចំការផ្តល់តាវកាលិកផ្សេងទៀតដូចជាគ្រោះថ្នាក់ការងារ និងមាតុភាពបន្ថែមលើតាវកាលិកដែលកំពុងផ្តល់ជូនសិទ្ធិវន្តដូចជាការចូលនិវត្ត ការចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព និងអ្នកនៅក្នុងបន្ទុក
- ជំរុញការរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងអណាព្យាបាលនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដើម្បីអនុវត្តអត្រាភាគទានសម្រាប់ជាមូលនិធិទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- រៀបចំធ្វើសំណើទៅភាគីពាក់ព័ន្ធ និងទៅប្រមុខរាជរដ្ឋាភិបាល និងសម្របសម្រួលកិច្ចប្រជុំនានាសំដៅប្រកាសអន្តរក្រសួងអាណាព្យាបាលនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដើម្បីអនុវត្តនីតិវិធីនៃការកំណត់អត្រាភាគទានសម្រាប់ជាមូលនិធិទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ជំរុញការចុះបេសកកម្មធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តទៅតាមបណ្តាខេត្តផ្សេងទៀតដែលមិនទាន់បានធ្វើបច្ចុប្បន្នភាពហើយដោយរៀបចំជាក្រុមការងារ
- រៀបចំបម្រើសេវាសោធនជូនសិទ្ធិវន្តតាមប្រព័ន្ធធនាគារទូទាំង ២៥រាជធានី ខេត្ត (ធនាគារ កាណាឌីយ៉ា ក.អ. សម្រាប់សិទ្ធិវន្តដែលរស់នៅរាជធានីភ្នំពេញ និងធនាគារអេស៊ីលីដា ភីអិលស៊ីសម្រាប់សិទ្ធិវន្តដែលរស់នៅតាមបណ្តាខេត្ត)
- ជំរុញការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិលដោយតភ្ជាប់ប្រព័ន្ធព័ត៌មានវិទ្យារវាងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលជាមួយក្រសួងមុខងារសាធារណៈ និងធនាគារដៃគូ។

## កម្មវិធី 2.2. អនិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

### គោលដៅ 2.2.1. គ្រប់គ្រង និងបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1* | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 95,959 | 98,634 | 101,309 | 103,984 | 106,659 | 109,334 |
| 2* | អតីតយុទ្ធជនដែលកំពុងបើករបបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ តាមរាជធានី ខេត្ត | នាក់ | 44,959 | 98,634 | 101,309 | 103,984 | 106,659 | 109,334 |
| 3 | រៀបចំអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានដើម្បីទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន | % | 80 | 100 | គ្មាន | គ្មាន | គ្មាន | គ្មាន |

**សកម្មភាពអនុវត្ត:**

- ចុះអនុស្សរណៈរវាងបេឡាជាតិអតីតយុទ្ធជន ជាមួយធនាគារកាណាឌីយ៉ា ក.អ. និងអេស៊ីលីដា ភីអិលស៊ី
- ផ្តល់សាលាកបត្រព័ត៌មានជូនមន្ទីរ ស.អ.យ. រាជធានី ខេត្ត ដើម្បីឲ្យអតីតយុទ្ធជនបំពេញ ដោយមានចុះហត្ថលេខាភូមិ និងត្រាមេឃុំ/សង្កាត់
- ចេញលិខិត ស្តីពីសំណើសុំស្ថិតិ និងបញ្ជីបើកប្រាក់របស់អតីតយុទ្ធជនគ្រប់ប្រភេទ ដែលមន្ទីរកំពុងគ្រប់គ្រង និងផ្តល់របបសន្តិសុខសង្គម
- ចេញសេចក្តីជូនដំណឹង ស្តីពីការធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ដែលស្ថិតក្រោមការគ្រប់គ្រង និងបើករបបសន្តិសុខសង្គមរបស់មន្ទីរ ស.អ.យ. រាជធានី ខេត្ត និងផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះ តាមរយៈទូរទស្សន៍ កាសែត វិទ្យុ ឲ្យអតីតយុទ្ធជនបានដឹងពីទីតាំង និងកាលបរិច្ឆេទដើម្បីចូលរួមធ្វើបច្ចុប្បន្នភាព
- ចុះធ្វើបច្ចុប្បន្នភាពជូនអតីតយុទ្ធជននៅរាជធានី ខេត្តដោយសហការជាមួយមន្ទីរ ស.អ.យ. រាជធានី ខេត្ត ធនាគារកាណាឌីយ៉ា ក.អ. និងអេស៊ីលីដា ភីអិលស៊ី
- បញ្ចូលទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា និងត្រួតពិនិត្យទិន្នន័យឡើងវិញជាមួយបញ្ជីបើកប្រាក់របស់រាជធានី ខេត្ត
- ធ្វើបច្ចុប្បន្នភាព និងបើករបបសន្តិសុខសង្គមជូនអតីតយុទ្ធជនតាមប្រព័ន្ធធនាគារក្រោយពីមានការផ្ទេរសាច់ប្រាក់ពីមន្ទីរ ស.អ.យ.រាជធានី ខេត្តចូលក្នុងគណនីរបស់ ប.ជ.អ
- បង្កើតក្រុមការងារដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានដើម្បីទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន
- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តអនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានដើម្បីទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន
- រៀបចំកិច្ចដំណើរការបេឡាជាតិអតីតយុទ្ធជនឲ្យបានពេញលេញជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ ។

**គោលដៅ 2.2.2. កែសម្រួលរបបសន្តិសុខសង្គម និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 4 | ដំឡើងប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬអាណាព្យាបាលរបស់គ្រួសារជនពលី មរណៈ | នាក់ | 43,126 | 43,301 | N/A | N/A | N/A | N/A |
| 5 | កែសម្រួលប្រាក់របបសន្តិសុខសង្គមជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារដែលផ្ទេរមកក្រសួង ស.អ.យ. មុន និងក្រោយឆ្នាំ២០០៧ឲ្យមានគុណភាពគ្នា | នាក់ | 28,694 | 28,694 | N/A | N/A | N/A | N/A |
| 6 | ប្រព័ន្ធគ្រប់គ្រងទិន្នន័យអតីតយុទ្ធជនតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានធ្វើបច្ចុប្បន្នភាព | លើក | 2 | 2 | 2 | 2 | 2 | 2 |

**សកម្មភាពអនុវត្ត:**

- រៀបចំស្ថិតិគ្រួសារជនពលី មរណៈដែលមានប្រាក់ឧបត្ថម្ភឪពុកម្តាយ ឬអាណាព្យាបាល
- រៀបចំសំណើសុំដំឡើងប្រាក់ឧបត្ថម្ភជូន ឪពុកម្តាយ ឬអាណាព្យាបាលគ្រួសារជនពលី មរណៈពី ៣.២០០៛ ទៅ ៨.០០០៛ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំស្ថិតិជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារដែលផ្ទេរមកក្រសួង ស.អ.យ. មុន និងក្រោយឆ្នាំ២០០៧
- រៀបចំសំណើសុំកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារដែលផ្ទេរមកក្រសួង ស.អ.យ. មុន និងក្រោយឆ្នាំ២០០៧ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ជួបប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារកំណែទម្រង់ប្រព័ន្ធបៀវត្ស ពិភាក្សាស្តីពីការកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ និងដំឡើងប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬអាណាព្យាបាលរបស់គ្រួសារជនពលី មរណៈ
- លើកសំណើសុំការពិនិត្យ សម្រេចពីរាជរដ្ឋាភិបាលដើម្បីកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ
- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្ត និងដំឡើងប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬអាណាព្យាបាលរបស់គ្រួសារជនពលី មរណៈ
- រៀបចំកែសម្រួលប្រព័ន្ធព័ត៌មានវិទ្យាទៅតាមការកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ។

**គោលដៅ 2.2.3. ជំរុញការអនុវត្ត និងពង្រឹងពង្រីកគម្រោងអភិវឌ្ឍន៍អតីតយុទ្ធជននៅថ្នាក់ឃុំ/សង្កាត់**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 7 | អតីតយុទ្ធជន និងគ្រួសារដែលបានដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច | គ្រួសារ | 13,265 | 2,047 | 2,047 | 2,047 | 2,047 | 2,047 |
| 8* | គណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជនឃុំ/សង្កាត់ដែលត្រូវបានបង្កើត | សហគមន៍ | 62 | 102 | 142 | 182 | 222 | 262 |

**សកម្មភាពអនុវត្ត:**

- កំណត់អត្តសញ្ញាណអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលត្រូវទទួលសម្បទានដីសង្គមកិច្ច
- រៀបចំសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយបញ្ជីឈ្មោះអ្នកស្នើសុំសម្បទានដីសង្គមកិច្ចចំពោះអតីតកងកម្លាំងប្រដាប់អាវុធស្ថិតក្រោមក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អតីតយុទ្ធជន និងគ្រួសារស្ថិតក្រោមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំសំណុំបែបបទកំណត់អត្តសញ្ញាណអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលត្រូវទទួលសម្បទានដីសង្គមកិច្ចផ្ញើជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- រៀបចំគំរោងអភិវឌ្ឍសហគមន៍អតីតយុទ្ធជននៅតាមរាជធានី ខេត្តដូចជា ៖
  - ការរៀបចំគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ឃុំ/សង្កាត់
  - ការរៀបចំគម្រោងការងារជួយគាំទ្រសេដ្ឋកិច្ចគ្រួសារអតីតយុទ្ធជនដូចជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់ឥណទានខ្នាតតូច។ល។

**គោលដៅ 2.2.4. ជំរុញការអភិវឌ្ឍសមាគមអតីតយុទ្ធជនកម្ពុជាសំដៅបន្តជួយដល់អតីតយុទ្ធជនក្នុងការកសាងជីវភាពគ្រួសារចូលរួមអភិវឌ្ឍន៍នៅមូលដ្ឋាន**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 9* | សមាគមអតីតយុទ្ធជនកម្ពុជាដែលទទួលបានសមាជិកចូលរួម | នាក់ | 79,187 | 80,690 | 82,190 | 83,690 | 85,190 | 86,690 |
| 10* | សមាជិក ស.អ.ក.ដែលទទួលបានប្រាក់បេឡាមរណសង្គ្រោះ | នាក់ | 3,573 | 4,173 | 4,773 | 5,373 | 5,973 | 6,573 |
| 11* | អតីតយុទ្ធជន និងគ្រួសារក្រីក្របំផុតតាមសហគមន៍ដែលទទួលបានផ្ទះ | គ្រួសារ | 228 | N/A | N/A | N/A | N/A | N/A |
| 12 | ទិវាអតីតយុទ្ធជន ២១ មិថុនា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | នាក់ | 10,370 | 7,450 | 7,450 | 7,450 | 7,450 | 7,450 |

**សកម្មភាពអនុវត្ត:**

- ផ្សព្វផ្សាយដល់អតីតយុទ្ធជន និងគ្រួសារឲ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃការចូលជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាតាមរយៈសមាគមអតីតយុទ្ធជនកម្ពុជារាជធានី ខេត្ត
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាពង្រឹងការងារបេឡាឥណទាន បេឡាមរណសង្គ្រោះ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់សមាគមអតីតយុទ្ធជនកម្ពុជា
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាពង្រឹងការឃោសនា អប់រំ ផ្សព្វផ្សាយអំពីគោលនយោបាយអតីតយុទ្ធជន
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាពង្រីកខ្សែរយៈចាត់តាំង និងសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាគ្រប់ថ្នាក់
- ពង្រឹងការអនុវត្តបេឡាមរណសង្គ្រោះ ស.អ.ក ស្របតាមគោលការណ៍នៃលក្ខន្តិកៈសមាគមអតីតយុទ្ធជនកម្ពុជាឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អង្គការមិនមែនរដ្ឋាភិបាលដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនអតីតយុទ្ធជនមានអាទិភាពទទួលបានសេវាសាធារណៈផ្សេងៗដូចជា ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់អាហាររូបករណ៍ ការដោះស្រាយការងារ ការដោះស្រាយមុខរបរ ការព្យាបាល ការផ្តល់ជំនួយសង្គ្រោះពេលមានគ្រោះថ្នាក់ផ្សេងៗ
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាពង្រឹងការអភិវឌ្ឍ ការបំផុសចលនា ៣ពូកែក្នុងជួរអតីតយុទ្ធជន
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាក្នុងការអនុវត្តការងារត្រួតពិនិត្យ ការដោះស្រាយវិវាទតាមលក្ខន្តិកៈរបស់សមាគមអតីតយុទ្ធជនកម្ពុជា
- រៀបចំ និងតាមដានការអនុវត្តការសាងសង់លំនៅឋានជូនអតីតយុទ្ធជន និងគ្រួសារ ដែលក្រីក្របំផុតនៅតាមសហគមន៍
- រៀបចំប្រារព្ធទិវាអតីតយុទ្ធជន ២១ មិថុនា ជារៀងរាល់ឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាក្នុងការរៀបចំឯកសារដើម្បីដំណើរការមហាសន្និបាត និងសន្និបាតសមាគមអតីតយុទ្ធជនកម្ពុជា។

## កម្មវិធី 2.3. សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា

### គោលដៅ 2.3.1. សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយ គ្របដណ្តប់លើវិសាលភាពនៃស្រទាប់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គមធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | រៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា | ច្បាប់ | សេចក្តីព្រៀង | ពិនិត្យ | ឆ្លងទី១ | ឆ្លងទី២ | អនុម័ត | ផ្សព្វផ្សាយ |

**សកម្មភាពអនុវត្ត:**

- បន្តប្រជុំក្រុមការងារពិនិត្យកែសម្រួលសេចក្តីព្រៀងច្បាប់ស្តីពីសន្តិសុខសង្គមសម្រាប់ប្រជាពលរដ្ឋទូទៅនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំធ្វើសិក្ខាសាលាដើម្បីធ្វើការត្រួតពិនិត្យ និងកែសម្រួលដោយមានការចូលរួមពីក្រសួង ស្ថាប័ននានា និងអង្គការដែលពាក់ព័ន្ធ
- រៀបចំបែបបទឆ្លងអន្តរក្រសួង និងសុំសេចក្តីសម្រេច និងអនុម័តពីរាជរដ្ឋាភិបាល និងធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ។

## យុទ្ធសាស្ត្រទី3: ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ

### កម្មវិធី 3.1. អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

#### គោលដៅ 3.1.1. ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | សិស្ស និស្សិតដែលបានជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង | នាក់ | 70 | 45 | 45 | 45 | 45 | 45 |
| 2 | មន្ត្រីរាជការក្រសួងត្រូវបានប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ | នាក់ | 200 | 77 | 77 | 77 | 77 | 77 |
| 3 | លិខិត ប័ណ្ណសរសើរ និងឯកសារផ្សេងៗដែលត្រូវបានផលិត | សន្លឹក | 4,900 | 4,900 | 4,900 | 4,900 | 4,900 | 4,900 |
| 4 | មន្ត្រីថ្នាក់ជាតិដែលបានចុះពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលនៅថ្នាក់ក្រោមជាតិ | លើក | 24 | 24 | 24 | 24 | 24 | 24 |
| 5 | មន្ត្រីរាជការថ្មី និងមន្ត្រីរាជការចាស់ដែលទទួលបានការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស | នាក់ | 120 | 120 | 120 | 120 | 120 | 120 |
| 6 | ពិធីបុណ្យជាតិផ្សេងដែលត្រូវបានរៀបចំឡើង | លើក | 9 | 9 | 9 | 9 | 9 | 9 |

**សកម្មភាពអនុវត្ត:**

- គ្រប់គ្រងលិខិតរដ្ឋបាល ទទួលលិខិតចូលចុះបញ្ជី និងលិខិតចេញ
- រៀបចំការតែងតាំង តម្លើងឋានន្តរស័ក្ត សម្រួលភារកិច្ច ផ្ទេរ ផ្លាស់ប្តូរឋានន្តរស័ក្តិ និងថ្នាក់ លុបឈ្មោះ ដាក់ឲ្យចូលនិវត្តន៍ ផ្អាកការងារដោយគ្មាន បៀវត្ស លើកសរសើរ ជូនរង្វាន់ គ្រប់គ្រងស្ថានភាពបៀវត្ស លំហែមាតុភាព មរណភាព
- រៀបចំ និងបោះពុម្ពលិខិត និងប័ណ្ណសរសើរជូនមន្ត្រីរាជការដែលមានស្នាដៃ
- បណ្តុះបណ្តាលបង្កើនសមត្ថភាពជំនាញការងាររបស់មន្ត្រីរាជការ និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលក្រៅប្រទេស
- ផ្សព្វផ្សាយពីការជ្រើសរើសសិស្ស-និស្សិតចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងជាសាធារណៈតាមរយៈបណ្តាញសារព័ត៌មាន(កាសែត,វិទ្យុ-ទូរទស្សន៍)
- សហការជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស។

**គោលដៅ 3.1.2.បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 7 | អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង | អង្គការ | 36 | 36 | 36 | 36 | 36 | 36 |
| 8 | អង្គការដែលបានធ្វើអធិការកិច្ច | អង្គការ | គ្មាន | 36 | 36 | 36 | 36 | 36 |
| 9 | មន្ត្រីដែលត្រូវបានអញ្ជើញឲ្យចូលរួមប្រជុំអន្តរជាតិ | នាក់ | 30 | 35 | 35 | 35 | 35 | 35 |
| 10 | ការបង់ថវិកាប្រចាំឆ្នាំសម្រាប់ គណៈកម្មការ ACWC អាស៊ាន | ដុល្លារ | គ្មាន | 00 | 40,000 | 00 | 00 | 00 |
| 11 | ពិធីការ និងបដិសណ្ឋាកិច្ចជាតិ និងអន្តរជាតិ | ដង | 330 | 300 | 300 | 300 | 300 | 300 |
| 12 | បទដ្ឋានត្រួតពិនិត្យ និងវាយតម្លៃអង្គការដែលត្រូវបានចងក្រង | ច្បាប់ | 0 | 1 | 1 | 1 | 1 | 1 |

**សកម្មភាពអនុវត្ត:**

- ចុះកិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក និងអន្តរជាតិលើវិស័យសង្គមកិច្ចក្នុងការបង្កើតជាដៃគូរដែលថវិកានឹងត្រូវអនុវត្តផ្ទាល់ដោយអង្គការនីមួយៗ
- ចុះធ្វើអធិការកិច្ចលើបណ្តាអង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ. ដើម្បីពង្រឹងប្រសិទ្ធភាពអនុវត្តគម្រោង ករណីអង្គការល្អ ក្រសួងអាចចេញក្នុងការផ្តល់រង្វាន់លើកទឹកចិត្តដូចជាបណ្ណ័សរសើរ មេដាយៗ ករណីអង្គការមិនល្អ អាចធ្វើការក្រើនរំលឹក អោយកែលំអ ក្នុងរយៈពេលណាមួយ រឺបិទសកម្មភាព/សេវាតែម្តងក្នុងករណីធ្ងន់ធ្ងរមិនគោរពតាមអនុសាសន៍របស់ក្រសួង
- ចូលរួមប្រជុំអន្តរជាតិដើម្បីទទួលបាន និងចែករំលែកនូវបទពិសោធន៍ស្តីពីការអនុវត្តគោលនយោបាយ និងសកម្មភាពពាក់ព័ន្ធក្នុងវិស័យសង្គមកិច្ច
- ចូលរួមតាមការអញ្ជើញឲ្យចូលរួមប្រជុំគណៈកម្មការ ACWC អាស៊ាន និងបង់ថវិកាតាមការព្រមព្រៀងរបស់ប្រទេសសមាជិក
- រៀបចំពិធីការ និងបដិសណ្ឋាកិច្ចសម្រាប់កិច្ចប្រជុំជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ និងក្រសួង
- រៀបចំប្រកាសស្តីពីការត្រួតពិនិត្យ និងវាយតម្លៃអង្គការនានាដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង បង្កើតឲ្យមានចំណាត់ថ្នាក់ និងកំណត់តារាងពិន្ទុក្នុងកម្រិតនីមួយៗ។

**គោលដៅ 3.1.3. អនុវត្តដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 13 | តម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ | % | | | | | | |
| 14 | មន្ត្រីដែលទទួលបានការបណ្តុះបណ្តាល | នាក់ | | | | | | |
| 15 | រៀបចំផែនការយុទ្ធសាស្ត្រហិរញ្ញវត្ថុ | ផែនការ | | | | | | |

**សកម្មភាពអនុវត្តៈ**

- តាមដានការចំណាយថវិកាទាំងថ្នាក់ជាតិ និងក្រោមជាតិ
- តាមដានការប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំឲ្យបានទាន់ពេលវេលា
- លើកកម្ពស់ការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បន្តពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការបើកប្រាក់បៀវត្ស
- បណ្តុះបណ្តាលមន្ត្រីជំនាញតាមរយៈសិក្ខាសាលា និងប្រជុំថ្នាក់ជំនាញ
- មានទិន្នន័យគ្រប់គ្រាន់ក្នុងការលើកផែនការថវិកា។

**គោលដៅ 3.1.4. កសាងផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេលមធ្យម និងវែង**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 16 | ផែនការយុទ្ធសាស្ត្រ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ២០១៤-២០១៨ | ផែនការ | បញ្ចប់ | អនុវត្ត | អនុវត្ត | ត្រួតពិនិត្យ | អនុវត្ត | ត្រួតពិនិត្យ |
| 17 | កម្មវិធីវិនិយោគសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | កម្មវិធី | 13 | 12 | 11 | 10 | 9 | 8 |
| 18 | ផែនសកម្មភាពការងារប្រចាំឆ្នាំ | ផែនការ | គ្មាន | 1 | 1 | 1 | 1 | 1 |

**សកម្មភាពអនុវត្តៈ**

- រៀបចំឯកសារប្រមូលផ្តុំមតិយោបល់ និងអនុសាសន៍ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្ត
- ពិនិត្យកែសម្រួលកម្មវិធីការងាររបស់មន្ទីរ ស.អ.យ. ស្របតាមកម្មវិធីការងាររបស់ក្រសួង
- ពិនិត្យកែសម្រួលកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល
- សហការជាមួយក្រសួងផែនការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ
- រៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់ក្រសួង ស.អ.យ. និងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ។

### គោលដៅ 3.1.5. បង្កើតប្រព័ន្ធស្ថិតិជាក់លាក់ និងជំរុញការប្រើប្រាស់ព័ត៌មានវិទ្យាសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 19 | ប្រព័ន្ធទិន្នន័យបណ្តុំព័ត៌មានត្រូវបានរៀបចំឡើង | ប្រព័ន្ធ | គ្មាន | សិក្សា | រៀបចំ | សាកល្បង | អនុវត្ត | អនុវត្ត |

**សកម្មភាពអនុវត្តៈ**

- បង្កើតគណៈកម្មការ/ក្រុមការងារស្ថិតិ
- ចុះប្រមូលព័ត៌មាន ទិន្នន័យ ពាក់ព័ន្ធមុខសញ្ញាដែលទទួលសេវា
- រៀបចំតារាង និងចងក្រងសូចនាកររបស់ក្រសួង
- ធ្វើបច្ចុប្បន្នភាពជាប្រចាំ
- ជំរុញការរៀបចំឲ្យមានប្រព័ន្ធទិន្នន័យកណ្តាល (Central Database)
- ធ្វើបច្ចុប្បន្នភាពគេហទំព័រ www.mosvy.gov.kh
- ធ្វើបច្ចុប្បន្នភាពព័ត៌មាន និងទិន្នន័យទៅក្នុងគេហទំព័ររបស់ក្រសួង
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរជាតិទទួលបន្ទុកព័ត៌មានវិទ្យា និងទូរគមនាគមន៍ និងដៃគូអភិវឌ្ឍន៍លើការងារព័ត៌មានវិទ្យា
- ធ្វើការអភិវឌ្ឍផ្នែកព័ត៌មានវិទ្យា

- ផ្សព្វផ្សាយសមិទ្ធផលសកម្មភាពការងាររបស់ក្រសួង និងតាមដានព័ត៌មាន
- ផ្សព្វផ្សាយសមិទ្ធផលសកម្មភាពតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ កាសែត)
- បោះពុម្ព និងចែកផ្សាយទស្សនាវដ្ដី។

### គោលដៅ 3.1.6. ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 20 | ប្រព័ន្ធត្រួតពិនិត្យវាយតម្លៃត្រូវបានបង្កើត | ឯកសារ | គ្មាន | សិក្សា/ រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| 21 | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបានការបណ្ដុះបណ្ដាលស្ដីពីការត្រួតពិនិត្យ និងវាយតម្លៃ | នាក់ | គ្មាន | 20 | 40 | 20 | 20 | 20 |

**សកម្មភាពអនុវត្ត:**

- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំ និង៥ឆ្នាំ និងរបាយការណ៍នៃការអនុវត្តផែនការជាតិ និងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣
- រៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ចុះត្រួតពិនិត្យ វាយតម្លៃសកម្មភាពការងារ តាមខេត្ត និងអង្គភាពក្រោមឱវាទ។

### គោលដៅ 3.1.7. បន្តអនុវត្តកំណែទម្រង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការផ្ទេរមុខងារ និងធនធានជាជំហានៗ ពីក្រសួងទៅថ្នាក់ក្រោមជាតិ និងការដាក់បញ្ចូលការងារសង្គមកិច្ចទៅក្នុងអភិវឌ្ឍន៍នៅគ្រប់កម្រិត

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 22 | មុខងារដែលត្រូវផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | មុខងារ | សិក្សា[17] | សាកល្បង | 5 | 4 | 7 | បន្តអនុវត្ត |
| 23 | មន្ត្រីថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តមុខងារ | នាក់ | គ្មាន | 112 | 120 | 120 | 120 | 120 |

**សកម្មភាពអនុវត្ត:**

- រៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ
- រៀបចំផែនការផ្ទេរមុខងារ និងបណ្តុះបណ្តាលអំពីមុខងារដែលត្រូវបានជ្រើសសម្រាប់ការផ្ទេរ និងត្រួតពិនិត្យការអនុវត្តមុខងារ។

### គោលដៅ 3.1.8. ពង្រឹងការងារសវនកម្មផ្ទៃក្នុង

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 24 | ចុះធ្វើសវនកម្មនៅតាមអង្គភាពចំណុះ | ដង | 18 | 51 | 51 | 51 | 51 | 51 |
| 25 | មន្ត្រីសវនកម្មផ្ទៃក្នុងទទួលបានការបណ្តុះបណ្តាល | នាក់ | គ្មាន | 20 | 20 | 20 | 20 | 20 |
| 26 | មន្ត្រីសនវកម្មផ្ទៃក្នុងដែលត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលខាងក្រៅ | នាក់ | គ្មាន | 4 | 4 | 4 | 4 | 4 |
| 27 | ផ្សព្វផ្សាយរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ | ដង | គ្មាន | 1 | 1 | 1 | 1 | 1 |

[17] របាយការណ៍ស្តីពីរៀបចំបញ្ជីវិភាគមុខងារ និងរបាយការណ៍ស្តីពីការត្រួតពិនិត្យមើលមុខងារ

**សកម្មភាពអនុវត្ត:**

- រៀបចំផែនការយុទ្ធសាស្រ្តសវនកម្ម និងចុះធ្វើសវនកម្មនៅតាមអង្គភាពចំណុះ
- ធ្វើការដោះស្រាយតាមអនុសាសន៍របស់ថ្នាក់ដឹកនាំ
- តាមដានការអនុវត្តតាមអនុសាសន៍របស់សវនករ
- បណ្តុះបណ្តាលសវនករឲ្យមានជំនាញច្បាស់លាស់
- ធ្វើរបាយការណ៍ស្តីការអនុវត្តអនុសាសន៍របស់សវនករជូនថ្នាក់ដឹកនាំ
- រៀបចំប្រជុំផ្សព្វផ្សាយរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ផ្ញើជូនអាជ្ញាសវនកម្មជាតិ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ។

**គោលដៅ 3.1.9. ពង្រឹងការងារអធិការកិច្ច**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ( ព្យាករណ៍ ) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 28 | ការធ្វើអធិការកិច្ចនៅតាមអង្គភាពចំណុះដែលបានអនុវត្ត | អង្គភាព | 24 | 48 | 48 | 48 | 48 | 48 |
| 29 | មន្ត្រីអធិការកិច្ចដែលទទួលបានការបណ្តុះបណ្តាលជំនាញ | នាក់ | គ្មាន | 20 | 20 | 20 | 20 | 20 |

**សកម្មភាពអនុវត្ត:**

- រៀបចំនីតិវិធី និងគោលការណ៍ណែនាំស្តីពីអធិការកិច្ច
- ទទួលដោះស្រាយវិវាទ និងពាក្យបណ្តឹងដែលកើតឡើងតាមអង្គភាពចំណុះក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រី
- ធ្វើអធិការកិច្ចជាប្រចាំលើចំណូល ចំណាយរដ្ឋជាមួយនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- រៀបចំយុទ្ធសាស្រ្ត និងឧបករណ៍បណ្តុះបណ្តាល
- បណ្តុះបណ្តាលមន្ត្រីអធិការកិច្ចឲ្យចេះធ្វើអធិការកិច្ចតាមនីតិវិធីច្បាប់ ធ្វើរបាយការណ៍ពីលទ្ធផលធ្វើអធិការកិច្ច។

**គោលដៅ 3.1.10. រៀបចំបណ្ដាញការងារអធិការកិច្ច**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 30 | បណ្ដាញអធិការកិច្ចដែលត្រូវបានបង្កើតឡើង | បណ្ដាញ | គ្មាន | 4 | 5 | 5 | 5 | 5 |
| 31 | មន្ត្រីបណ្ដាញអធិការកិច្ចដែលទទួលបានការបណ្ដុះបណ្ដាលជំនាញ | នាក់ | គ្មាន | 15 | 15 | 15 | 15 | 15 |
| 32 | ពង្រឹងសមត្ថភាពមន្ត្រីបណ្ដាញដែលបានទទួលការបណ្ដុះបណ្ដាល | នាក់ | គ្មាន | 12 | 15 | 15 | 15 | 15 |

**សកម្មភាពអនុវត្ត:**

- បង្កើតបណ្ដាញអធិការកិច្ចនៅតាមមន្ទីររាជធានី ខេត្ត
- បណ្ដុះបណ្ដាលមន្ត្រីបណ្ដាញអធិការកិច្ចរាជធានី ខេត្ត
- ពង្រឹងសមត្ថភាពមន្ត្រីបណ្ដាញឲ្យទទួលខុសត្រូវលើការងារអធិការដោយខ្លួនឯងនៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត។

**គោលដៅ 3.1.11. រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងារអធិការកិច្ច**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 33 | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងារអធិការកិច្ចដែលបានបង្កើតឡើង | អង្គភាព | គ្មាន | ចងក្រង | 4 | 6 | 9 | 5 |

**សកម្មភាពអនុវត្ត:**

- សិក្សាពីទម្រង់នៃការងារអធិការកិច្ចតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំចងក្រងកម្មវិធីគ្រប់គ្រងការងារអធិការកិច្ច
- រៀបចំដំឡើងប្រព័ន្ធព័ត៌មានវិទ្យាតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត
- បណ្ដុះបណ្ដាលមន្ត្រីព័ត៌មានវិទ្យា ។

**គោលដៅ 3.1.12. បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| | **ក. កម្រិតឧត្តមសិក្សា** | | | | | | | |
| 34 | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររង | នាក់ | 187 | 344 | 506 | 646 | 676 | 676 |
| 35 | និស្សិតដែលបានចុះឈ្មោះចូលរៀនជំនាញ សង្គមកិច្ច | នាក់ | 50 | 50 | 50 | 50 | 50 | 50 |
| 36 | និស្សិតដែលបានកំពុងសិក្សាជំនាញសង្គមកិច្ច | នាក់ | 73 | 120 | 170 | 200 | 200 | 200 |
| 37 | និស្សិតដែលបានបញ្ចប់ជំនាញសង្គមកិច្ច | នាក់ | គ្មាន | គ្មាន | 20 | 70 | 120 | 170 |
| 38 | និស្សិតដែលបានចុះឈ្មោះចូលរៀនជំនាញគ្រប់គ្រងកិច្ចគាំពារសង្គម | នាក់ | 50 | 50 | 50 | 50 | 50 | 50 |
| 39 | ស្សិតដែលបានកំពុងសិក្សាជំនាញគ្រប់គ្រងកិច្ចគាំពារសង្គម | នាក់ | 50 | 100 | 150 | 200 | 200 | 200 |
| 40 | និស្សិតដែលបានបញ្ចប់គ្រប់គ្រងកិច្ចគាំពារសង្គម | នាក់ | គ្មាន | គ្មាន | គ្មាន | 50 | 100 | 150 |
| 41 | និស្សិតចុះឈ្មោះចូលរៀនជំនាញសង្គមវិទ្យា | នាក់ | 30 | 30 | 30 | 30 | 30 | 30 |
| 42 | ស្សិតដែលបានកំពុងសិក្សាជំនាញសង្គមវិទ្យា | នាក់ | 30 | 60 | 90 | 120 | 120 | 120 |
| 43 | និស្សិតដែលបានបញ្ចប់ជំនាញសង្គមវិទ្យា | នាក់ | គ្មាន | គ្មាន | គ្មាន | 30 | 60 | 90 |
| 44 | និស្សិតដែលបានចុះឈ្មោះចូលរៀនជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប | នាក់ | 14 | 14 | 14 | 14 | 14 | 14 |
| 45 | និស្សិតដែលបានកំពុងសិក្សាជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប | នាក់ | 36 | 36 | 36 | 36 | 36 | 36 |
| 46 | និស្សិតដែលបានបញ្ចប់ជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប | នាក់ | 185 | 199 | 213 | 227 | 241 | 255 |
| 47 | និស្សិតដែលបានចុះឈ្មោះចូលរៀនជំនាញវិទ្យាសាស្ត្រព្យាបាលដោយចលនា | នាក់ | គ្មាន | 15 | 15 | 15 | 15 | 15 |
| 48 | និស្សិតដែលបានកំពុងសិក្សាជំនាញវិទ្យាសាស្ត្រព្យាបាលដោយចលនា | នាក់ | គ្មាន | 15 | 30 | 45 | 60 | 60 |
| 49 | និស្សិតដែលបានបញ្ចប់ជំនាញវិទ្យាសាស្ត្រព្យាបាលដោយចលនា | នាក់ | គ្មាន | គ្មាន | គ្មាន | គ្មាន | 15 | 30 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 50 | និស្សិតដែលបានចុះឈ្មោះចូលរៀនជំនាញវិស្វកម្មឧបករណ៍ជំនួយចលនា | នាក់ | គ្មាន | 15 | 15 | 15 | 15 | 15 |
| 51 | និស្សិតដែលបានកំពុងសិក្សាជំនាញវិស្វកម្មឧបករណ៍ជំនួយចលនា | នាក់ | គ្មាន | 15 | 30 | 45 | 60 | 60 |
| 52 | និស្សិតដែលបានបញ្ចប់ជំនាញវិស្វកម្មឧបករណ៍ជំនួយចលនា | នាក់ | គ្មាន | គ្មាន | គ្មាន | គ្មាន | 15 | 30 |
| | **ខ.កម្រិតវិញ្ញាបនបត្រ** | | | | | | | |
| 53 | សិក្ខាកាមដែលបានសិក្សាជំនាញសង្គមកិច្ច | នាក់ | គ្មាន | 100 | 200 | 250 | 250 | 250 |
| 54 | សិក្ខាកាមដែលបានសិក្សាជំនាញផ្សេងៗ | នាក់ | គ្មាន | 200 | 400 | 400 | 400 | 400 |

**សកម្មភាព:**

- រៀបចំសិក្ខាសាលា និងសន្និសិទដល់និស្សិត
- ផ្តល់អាហារូបករណ៍ដល់និស្សិត
- រៀបចំការប្រឡងបញ្ចប់ឆមាសរបស់និស្សិត
- រៀបចំផែនការយុទ្ធសាស្ត្រ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- អភិវឌ្ឍកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ និងសង្គម
- រៀបចំប្រលងជ្រើសរើសនិស្សិតឲ្យចូលរៀន
- រៀបចំដំណើរការសិក្សា និងបង្រៀន និងរៀបចំឲ្យមានការចុះកម្មសិក្សារបស់និស្សិត។

**គោលដៅ 3.1.13. ជំរុញ និងលើកកម្ពស់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយ**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ(ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 55 | ការសិក្សាស្រាវជ្រាវលើជំនាញសង្គមកិច្ចដែលបានធ្វើឡើង | អត្ថបទ | 1 | 2 | 5 | 5 | 6 | 7 |
| 56 | ការសិក្សាស្រាវជ្រាវលើជំនាញគ្រប់គ្រងកិច្ចគាំពារសង្គមដែលធ្វើឡើង | អត្ថបទ | គ្មាន | 1 | 2 | 3 | 5 | 5 |
| 57 | ការសិក្សាស្រាវជ្រាវលើជំនាញសង្គមវិទ្យាដែលបានធ្វើឡើង | អត្ថបទ | គ្មាន | 1 | 2 | 2 | 3 | 5 |
| 58 | ការសិក្សាស្រាវជ្រាវលើជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណបដែលបានធ្វើឡើង | អត្ថបទ | គ្មាន | 1 | 2 | 3 | 3 | 3 |
| 59 | ការសិក្សាស្រាវជ្រាវលើជំនាញវិទ្យាសាស្ត្រព្យាបាលដោយចលនាដែលបានធ្វើឡើង | អត្ថបទ | គ្មាន | គ្មាន | 1 | 1 | 1 | 1 |
| 60 | ការសិក្សាស្រាវជ្រាវលើជំនាញវិស្វកម្មឧបករណ៍ជំនួយចលនាដែលបានធ្វើឡើង | អត្ថបទ | គ្មាន | គ្មាន | 1 | 1 | 1 | 1 |

**សកម្មភាពអនុវត្ត:**

- រៀបចំការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយ
- អភិវឌ្ឍបណ្ណាល័យ និងរៀបចំកម្មវិធីបង្ហាត់បង្រៀនឲ្យនិស្សិតចេះប្រើប្រាស់បណ្ណាល័យ ។

**គោលដៅ 3.1.14. ពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច**

| ល.រ | សូចនាករ | ឯកតា | មូលដ្ឋាន | ចំណុចដៅ (ព្យាករណ៍) | | | | |
|---|---|---|---|---|---|---|---|---|
| | | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
| 61 | បុគ្គលិកសិក្សាដែលមានសញ្ញាបត្រកម្រិតឧត្តមសិក្សា | នាក់ | 25 | 25 | 25 | 25 | 25 | 25 |
| 62 | បុគ្គលិកសិក្សាដែលមានសញ្ញាបត្រកម្រិតក្រោយឧត្តមសិក្សា | នាក់ | 25 | 26 | 30 | 35 | 40 | 45 |

**សកម្មភាពអនុវត្ត:**

- រៀបចំលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រងវិទ្យាស្ថាន
- ពង្រឹង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ និងសណ្តាប់ធ្នាប់ (បង្កើតបន្ទប់ពិសោធន៍ អនុវត្ត ថ្នាក់រៀន ឧបទ្ទេសសិក្សា អាហាដ្ឋាន ទីលានកីឡា ចំណតយានយន្ត និងជួសជុលថែទាំ ។ល។)

- ពង្រឹងសមត្ថភាពបុគ្គលិក និងសាស្ត្រាចារ្យ តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ផ្តល់អាហារូបករណ៍ក្នុង និងក្រៅប្រទេស
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការរៀន និងបង្រៀន របស់និស្សិត និងសាស្ត្រាចារ្យ
- ពង្រឹងកិច្ចសហ ប្រតិបត្តិការជាតិ និងអន្តរជាតិ
- ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារ
- ពង្រឹងការគ្រប់គ្រងថវិកា គ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុ និងការគៀងគរប្រភពធនធាន
- អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ តាមរយៈការរៀបចំ (គេហទំព័រ អ៊ិនធឺណែត ទូរស័ព្ទ ទូរសារ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិកសាស្ត្រាចារ្យ និងនិស្សិត)។

សម្គាល់៖ ( * ) ទិន្នន័យបូកបន្ថែម "Cumulative"